ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៦១**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាត្ទូ គ្រីស្ពារ *(Mr. Matteo Crippa)*

លោក ចេម វ៉ាលតុន*(Mr. Jame WALTON)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent DE WILDE D'ESTMAEL)*

លោក ប៉ាក់ ចន្ទលីណូ

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារេស

*(Marie-Paule CANIZARES)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ *(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-Naprous)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# ឧបសម្ព័ន្ធ

## ដើមបណ្តឹងរដ្ឋប្បវេណី

### លោកស្រី អ៊ឹម ស៊ុន្ធី

ស្តួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ទំព័រ ៣
ស្តួរដោយ លោកស្រី ស៊ីលឃី ស្ទួតហ្សិនស្គី ផ្តើមពី ........ទំព័រ ១៥

### លោកស្រី តឹង ហ្វុតស៊ុនថារី

ស្តួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ទំព័រ ២០
ស្តួរដោយ លោកស្រី ស៊ីលឃី ស្ទួតហ្សិនស្គី ផ្តើមពី ........ទំព័រ ៥១

### លោកស្រី តឹង ហ្វុតស៊ុនថារី

ស្តួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ទំព័រ ៥៨
ស្តួរដោយ លោកស្រី ស៊ីលឃី ស្ទួតហ្សិនស្គី ផ្តើមពី ........ទំព័រ ៦៦

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សាវេស | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោកស្រី អ៊ុំ ស៊ុន្ទី | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវើរ៍ | បារាំង |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោកស្រី ភឹង ហ្គុតស៊ុនថារី | ខ្មែរ |
| លោក ស៊ាង វ៉ានឌី | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី | អង់គ្លេស |
| លោកស្រី ទ្រូស្សូណាព្រូស | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៧:៣៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយថ្ងៃនេះគឺអង្គជំនុំជម្រះនឹងដំណើរការស្តាប់នូវសេចក្តីថ្លៃការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរចំនួនបីរូបតាមកាលវិភាគនៃដំណើរការសវនាការ ដែលបានកែសម្រួលកាលពីម្សិលមិញ ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវកោះហៅមកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អ៊ឹម ស៊ុន្នី, លោកស្រី ភឹង ហ៊ុតស៊ុនថារី, លោក ស៊ាង វ៉ាន់ឌី មានវត្តមាន ។ ខ្ញុំបានត្រួតពិនិត្យអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួចរាល់ហើយ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

សូមមេធាវី អាឡាំង វែនណឺ ។

**លោក អាឡាំង វែនណឺ៖**

ខ្ញុំនឹងមានសំណើខ្លីមួយខ្ញុំបានឮ--

**ប្រធានអង្គជំនុំ៖**

និយាយសាជាថ្មីម្តងទៀត ដោយមិនបានបកប្រែអស់ គឺមានបកប្រែតិចតួចប៉ុណ្ណោះ ។

**លោក អាឡាំង វែនណឺ៖**

សូមគោរពលោកប្រធាន! លោក លោកស្រីចៅក្រម ខ្ញុំមានសំណើខ្លីមួយ ពីម្សិលមិញកូនក្តីចុងក្រោយរបស់ខ្ញុំឈ្មោះ នេត ផល្លី ដែលបានជម្រាមជូនដែលនិយាយអំពីដៃឆ្វេងរបស់គាត់ដែលពិការ ។ ហើយខ្ញុំគប្បីតែបញ្ជាក់ខ្ញុំមិនបានសួរលោកចៅក្រម ដើម្បីឲ្យកត់ត្រាដែលថា ដៃឆ្វេងរបស់គាត់បានពិការពីព្រោះដោយសារតែគាត់មិនបានស្បថ ហើយគាត់មកថ្ងៃនេះដែរ ។ ហើយខ្ញុំសូមអនុញ្ញាតពីលោកចៅ

ក្រុម ដើម្បីឲ្យគាត់ក្រោកឈរ ដើម្បីការកត់ត្រាបានត្រឹមត្រូវដូចដែលគាត់បានជម្រាបអង្គជំនុំជម្រះ ថាដៃខាងឆ្វេងរបស់គាត់ត្រូវបានពិការរហូតមកដល់ត្រឹមកែងដៃ ដើម្បីឲ្យកត់ត្រាឆ្លុះបញ្ចាំងពីអ្វីដែលគាត់បញ្ជាក់ពីម្សិលមិញ ។ សូមអរគុណ ។

[០៩:១០:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ។ អញ្ជើញលោក នេត ផល្លី អញ្ជើញក្រោកឈរ ។

ហើយលោកបង្ហាញនូវដៃពិការរបស់លោក ។ អ៊ីចឹង គឺលោកមានពិការភាពដៃខាងឆ្វេង ហើយម្សិលមិញគឺលោកបាននិយាយរៀបរាប់ អំពីមូលហេតុនៃការពិការដៃហ្នឹងសព្វគ្រប់ហើយ ហើយប្រហែលជាអាចមានការខ្វះចន្លោះនូវការបង្ហាញជាក់លាក់ប៉ុណ្ណោះ ។

អរគុណ សូមអញ្ជើញលោកអង្គុយចុះ ។

**លោក អាឡាំង វែនណឺ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ស្ទូតហ្សីនស្គី ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ខ្ញុំសូមអនុញ្ញាតធ្វើសំណើជូនអង្គជំនុំជម្រះទាក់ទងទៅនឹងលំដាប់លំដោយនៃការបង្ហាញខ្លួននៃដើមបណ្ដឹងរដ្ឋប្បវេណីថ្ងៃនេះ ។ ថ្ងៃនេះ ខ្ញុំសូមឯកភាពទៅលើលំដាប់លំដោយនេះ ប៉ុន្តែតាមពិតយើងត្រូវអញ្ជើញកញ្ញា អ៊ឹម ស៊ុន្ទី ហើយបន្ទាប់មកលោកស្រីភឹង ហ្គុតស៊ុនថារី បន្ទាប់ក្រោយគេ គឺលោក ស៊ាង វ៉ាន់ឌី នេះជាសំណើទីមួយរបស់ខ្ញុំ ។

បន្ទាប់មកពាក់ព័ន្ធទៅនឹងរយៈពេលវេលាដែលបានបែងចែកទៅលោកស្រី អ៊ឹម ស៊ុន្ទី សាមសិបនាទី ហើយនិងកូនស្រីរបស់គាត់ ភឹង ហ្គុតស៊ុនថារី នោះ ខ្ញុំសូមស្នើដល់អង្គជំនុំជម្រះ ដើម្បីអនុញ្ញាតឲ្យយើងខ្ញុំប្រើពេលវេលានេះសម្រាប់ទាំងពីរជាផ្នែករួមជាមួយគ្នា ដើម្បីធ្វើសេចក្ដីពន្យល់ ហើយនិងបង្ហាញអំពីឯកសារដែលខ្ញុំនឹងត្រូវយោង ទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរនេះ ។ ហើយពេលដែលនឹងត្រូវប្រើនឹងបញ្ជាក់ពីលេខERNផងដែរ ។ ហើយខ្ញុំនឹងសូមអនុញ្ញាតដើម្បីយើងប្រើពេលនេះសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរជារួមគ្នា មិនចាំបាច់បែងចែកថាជាសាមសិបនាទីម្នាក់ ឬក៏ម្ភៃនាទីម្នាក់

នោះទេ នេះជាសំណើទីពីររបស់ខ្ញុំ ។

[០៩:១៣:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់មេធាវី ស្វូតហ្សឺនស្តី ដែលជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរលក្ខខណ្ឌ ដែលមេធាវីបានស្នើសុំនេះ ។ ហើយដោយសារបញ្ហាលំដាប់នៃការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីនោះ គឺមិនមានបញ្ហាផ្នែកខាងនីតិវិធីទេ ។ ការលំដាប់លំដោយនៃការស្តាប់អាស្រ័យទៅលើស្ថានភាពជាក់ស្តែងតែប៉ុណ្ណោះ ។

សូមអញ្ជើញលោកស្រី អ៊ឹម ស៊ុន្ទី មកកាន់កៅអីដែលបានរៀបចំទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ ។

*(លោកស្រី អ៊ឹម ស៊ុន្ទី ចូលមកកាន់បន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោកស្រី អ៊ឹម ស៊ុន្ទី តើលោកស្រីមានឈ្មោះ អ៊ឹម ស៊ុន្ទី អ៊ីចឹងពិតមែនដែរឬទេ? លោកស្រី--

**លោកស្រី ស៊ីលឃីស្វូត ហ្សឺនស្តី៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំមិនទទួលបានចម្លើយនៅឡើយទេ ។ សូមអនុញ្ញាតសួរឡើងវិញ ហើយខ្ញុំរង់ចាំចម្លើយពីដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអនុញ្ញាតចាប់ផ្តើមម្តងទៀត ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំគិតថា ខ្ញុំក៏អត់បានចម្លើយដែរ ដោយគាត់អត់ទាន់បាននិយាយ ។ ខ្ញុំយល់ថា គាត់ប្រហែលស្តាប់សំណួរមិនបាន ខ្ញុំរៀបចំសំណួរជាថ្មី ដើម្បីឱ្យគាត់បានស្តាប់ឮ ហើយនិងអាចឆ្លើយនឹងសំណួររបស់ខ្ញុំបាន ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រី អ៊ឹម ស៊ុន្ទី តើលោកស្រីមានឈ្មោះ អ៊ឹម ស៊ុន្ទី អ៊ីចឹងពិតមែនដែរឬទេ?

**លោកស្រី អ៊ឹម សុន្ទី៖**

(មិនឮសំឡេង)

**ប្រធានអង្គជំនុំ៖**

អត់ឮទេ មើល៍មន្ត្រីតុលាការមើលរៀបចំប្រព័ន្ធមីក្រូហ្វូនឲ្យបានល្អ ហើយអាចរំកិលប្រព័ន្ធក្បាលមីក្រូហ្វូន ទៅខាងកើត ដើម្បីឲ្យខ្ញុំអាចមើលឃើញផងនៃការមានភ្លើងសញ្ញា ឬក៏អត់នោះ?

មិនទាន់ទេ កើតបន្តិចទៀតបានទេ? បន្តិចទៀតៗ ។

**ស៖** សូមអញ្ជើញលោកស្រីឆ្លើយនឹងសំណួរ ។

**ឆ៖** សូមគោរពលោកប្រធាន លោកស្រីចៅក្រម ខ្ញុំឈ្មោះ អ៊ឹម ស៊ុន្ទី ។

**ស៖** តើលោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំអាយុ ៧០ឆ្នាំ ។

**ស៖** តើលោកស្រីមានសញ្ជាតិអ្វីដែរ?

**ឆ៖** ខ្ញុំមានសញ្ជាតិខ្មែរ ។

**ស៖** តើលោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ទីកន្លែងកំណើតរបស់ខ្ញុំ គឺនៅក្រុងភ្នំពេញ សង្កាត់លេខ៦ ។

**ស៖** តើសព្វថ្ងៃនេះ លោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំរស់នៅជាមួយកូន នៅទួលគោក ។

**ស៖** ហើយសព្វថ្ងៃនេះ លោកស្រីប្រកបមុខរបរអ្វីដែរ?

**ឆ៖** កាលពីឆ្នាំ១៩៧៩ ខ្ញុំធ្វើការនៅក្រសួងគមនាគមន៍ ឥឡូវនេះខ្ញុំជារាជការចូលនិវត្តន៍ ។

**ស៖** ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៧ ខែមករា ៧៩ តើលោកស្រីរស់នៅទីកន្លែងណា? ហើយធ្វើអ្វីដែរ?

**ឆ៖** កាលពី១៧ មេសា ១៩៧៥ ខ្ញុំក៏ដូចប្រជាជនទូទាំងប្រទេស ត្រូវជម្លៀសចេញពីកន្លែងមួយទៅកន្លែងមួយ ហើយធ្វើការជាទម្ងន់ បំបែកកូនចៅ ហូបចុកក៏គ្មាន ធ្វើការជាធ្ងន់ ដូចលោកប្រធានជ្រាបស្រាប់ហើយ ការងារជំនាន់អាវខ្មៅនេះឃោរឃៅ ។ សូមអស់ ។

**ស៖** តើឪពុករបស់លោកស្រីឈ្មោះអ្វី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ អ៊ឹម ទុយ ជានាយកសាលាអនុគរុវិជ្ជា គឺគេហៅថា *អេកូលអានិកន័រម៉ាល់* ។ គាត់បានទទួលអនិច្ចកម្មហើយ ។

**ស៖** ចុះម្តាយរបស់លោកស្រីវិញ គាត់ឈ្មោះអ្វីដែរ?

**ឆ៖** ម្តាយខ្ញុំឈ្មោះ មុំ ត្រសុស ជាគ្រូបង្រៀននៅសាលាម៉ាលីកា ក្រុងភ្នំពេញ ។

**ស៖** ចុះចំពោះខ្លួនរបស់លោកស្រីផ្ទាល់វិញ តើសព្វថ្ងៃនេះស្ថានភាពគ្រួសាររបស់លោកស្រីយ៉ាងម៉េចដែរ? ថាតើលោកស្រីមានគ្រួសារមានប្តីសី ឬក៏លោកស្រីជាស្ត្រីមេម៉ាយ?

**ឆ៖** នាងខ្ញុំបានរៀបមង្គលការជាមួយនឹងលោកសាស្ត្រាចារ្យ ភឹង តុន នៅថ្ងៃ១៥ ខែមិថុនា ឆ្នាំ ១៩៥៥ ។ គាត់ជាសាស្ត្រាចារ្យ ប៉ុន្តែត្រូវពួក ប៉ុល ពត សម្លាប់ ។ ពេល ១៧ មេសា ១៩៧៥ ខ្ញុំជម្លៀសចេញជាមួយកូន និងបងប្អូន ឯប្តី--

**ប្រធានអង្គជំនុំ៖**

ឥឡូវប៉ុណ្ណឹងសិនបានហើយ ចាំៗរៀបរាប់នៅសេចក្តីថ្លែងការណ៍របស់លោកស្រីចុះ ។ អង្គជំនុំជម្រះសួរព័ត៌មានមួយចំនួន ទាក់ទិននឹងអត្តសញ្ញាណបឋមប៉ុណ្ណោះ ។ ហើយអត្តសញ្ញាណនេះនឹងបំពេញបន្ថែមដោយមេធាវីរបស់លោកស្រី ហើយនិងលោកស្រីនឹងមានឱកាសនៅក្នុងការថ្លែងរៀបរាប់អំពីទុក្ខលំបាក ឬក៏បញ្ហានានាផ្ទាល់ខ្លួនរបស់លោកស្រី ដែលមានការពាក់ព័ន្ធទៅនឹងរឿងហេតុ ឬក៏បទឧក្រិដ្ឋដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ នេះជាក្រោយ ។

ឥឡូវនេះ អង្គជំនុំជម្រះផ្តល់ឱកាសទៅកញ្ញាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរដើម្បីឡើងធ្វើសេចក្តីថ្លែងការណ៍ដោយសង្ខេបបង្ហាញ អំពីអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ អ៊ឹម ស៊ុន្នី បង្ហាញហេតុដែលនាំឲ្យឈ្មោះ អ៊ឹម ស៊ុន្នី បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះ ទំនាក់ទំនងនៃការប្តឹងទាមទារសំណងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អ៊ឹម ស៊ុន្នី ទៅនឹងបទឧក្រិដ្ឋដែលចោទប្រកាន់ទៅលើជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធនឹងអង្គហេតុដែលកើតឡើងនៅមន្ទីរសន្តិសុខស-២១ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ៧៩ ។ សូមអញ្ជើញមេធាវី ។

[០៩:២៤:៤៣]

**លោកស្រី ស៊ីលឃីស្ទត ហ្សីនស្តី៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងធ្វើសេចក្តីផ្តើមជំនួសលោកស្រី អ៊ឹម ស៊ុន្នី ហើយនិងលោកស្រី ភឹង ហ្គុតស៊ុនថាវី ពីព្រោះសំណុំរឿងនេះទាក់ទងគ្នា ។ លោកស្រី អ៊ឹម ស៊ុន្នី បានដាក់ជូននូវឯកសារអត្តសញ្ញាណប័ណ្ណជូនទៅអង្គជំនុំជម្រះ ហើយដូចគ្នាដែរលោកស្រី ហ្គុតស៊ុនថាវី ក៏បានដាក់ជូននូវឯកសារអត្តសញ្ញាណប័ណ្ណរបស់គាត់ផងដែរ ។ ប្រវត្តិរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម សុន្នី

ដែលបានបង្ហាញខ្លួននៅពេលនេះ គឺមានដូចតទៅនេះ៖

លោកស្រី អ៊ឹម ស៊ុន្នី បានបាត់បង់ប្តីរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ហើយក្រោយមកប្តីរបស់គាត់នោះត្រូវបានសម្លាប់ គេសម្លាប់នៅស-២១ ។ គាត់មិនបានដឹងទេនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះថា គ្រាន់តែដឹងថា ការបំបែកក្រុមគ្រួសារប្តីពីប្រពន្ធ ។ ចំពោះកូនស្រីរបស់គាត់ដែលតំណាងឲ្យក្រុមគ្រួសារទាំងមូលផងដែរ រួមទាំងអ្នកស្រី អ៊ឹម ស៊ុន្នី គាត់បានបាត់បង់ឪពុករបស់គាត់ឈ្មោះសាស្ត្រាចារ្យ ភឹង តុន ហើយជានាយកសាកលវិទ្យាល័យភ្នំពេញ មហាវិទ្យាល័យច្បាប់ ។ ហើយ ភឹង ហ្គុតស៊ុនថារី ក៏មិនបានដឹងដែរថា មានរឿងអ្វីកើតឡើងចំពោះឪពុករបស់ខ្លួននោះ ។ ផលប្រយោជន៍ដែលដើមបណ្តឹងរដ្ឋប្បវេណីមកបង្ហាញខ្លួននិងផ្តល់សេចក្តីថ្លែងការណ៍ពេលនេះ គឺដើម្បីរំឭកឡើងវិញអំពីរឿងរ៉ាវប្តីរបស់គាត់ ហើយនិងជាឪពុករបស់គាត់ ហើយដើម្បីស្វែងរកការពិតពាក់ព័ន្ធទៅនឹងជោគវាសនារបស់លោក ភឹង តុន ដែលថារហូតមកដល់ពេលនេះនៅតែជាការអាថ៌កំបាំង ទោះបីជាសាក្សីមួយចំនួនច្រើនបានបំភ្លឺតាមការសួរសំណួរដោយរាប់ទាំងការបំភ្លឺរបស់ជនជាប់ចោទផងដែរ ។ ព័ត៌មាននោះនៅតែមិនទាន់បានបង្ហាញឲ្យច្បាស់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងក្រុមគ្រួសាររបស់គាត់ដែរ ។ ថាតើមិនបានដឹងច្បាស់ថាតើអ្វីបានកើតឡើងពិតប្រាកដទៅលើរូបប្តីរបស់គាត់ និងជាឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតនោះ ។

ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម ស៊ុន្នី ហើយនិង ភឹង ហ្គុតស៊ុនថារី នោះ ហើយខ្ញុំនឹងប្រគល់សិទ្ធិទាមទារសំណងទៅឲ្យមេធាវីជាអ្នកស្នើសុំ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតអង្គជំនុំជម្រះដើម្បីបង្ហាញជូននូវឯកសារមួយចំនួនដែលគាំទ្រពាក្យបណ្តឹងឯកសារហ្នឹង គឺមាននៅក្នុងសំណុំរឿង ។ ហើយអាចនឹងដាក់ចូលជាក្រុមដូចតទៅនេះ ដូចជា បញ្ជីឈ្មោះអ្នកទោសដែល ឈ្មោះរបស់លោក ភឹង តុន បានមាននៅលើបញ្ជីហ្នឹងជាច្រើនកន្លែង ដែលបង្ហាញថា នៅពេលដែលគាត់នៅរស់នៅឡើយនៅពេលឃុំខ្លួននោះ ។ បន្ទាប់មកទៀត យើងមានប្រវត្តិរូបរបស់គាត់អំពីការឃុំខ្លួនដែលមាន-- បន្ទាប់មកមានសំបុត្រមួយចំនួន ដែលគាត់បានសរសេរឆ្លើយឆ្លងក្រុមគ្រួសារ ដែលនៅសេសសល់ ។

[០៩:២៩:១៨]

ហើយខ្ញុំនឹងជូនជាលេខ ERN ខ្ញុំនឹងចាប់ផ្តើមជាមួយឯកសារមុនគេមួយ D25/5/7 ខ្មែរ ។ ERN នោះ 0018847 រហូតដល់ 008850-- ។ ខ្ញុំសូមអានឡើងវិញ ERN ជាភាសាខ្មែរ 00188847 រហូតដល់ 00188850 នៅក្នុងភាសាអង់គ្លេសលេខ 00274957 រហូតដល់ 00234960 ។ ហើយ

លេខ ERN នៅបញ្ជីអ្នកទោសមួយទៀតគឺ D25/5/8 លេខ ERN ភាសាខ្មែរគឺ 00188853 រហូតដល់ 00188856 ។ នៅក្នុងភាសាអង់គ្លេស 00234961 រហូតទៅដល់ 0234962 ។

បញ្ជីអ្នកទោសមួយទៀតឯកសារ D25/5/11 លេខ ERN ភាសាខ្មែរ 00188870 រហូតដល់ 00188875 ។ ភាសាអង់គ្លេសលេខ ERN 00239745 រហូតដល់ 00239750 ។

បញ្ជីអ្នកទោសមួយទៀតគឺ D25/5/9 លេខ ERN ខ្មែរ 00188858 រហូតដល់ 00188859 ។ ភាសាអង់គ្លេស ERN 02339014 រហូតដល់ 00239016 ។

បញ្ជីអ្នកទោសមួយទៀតគឺD25/5/12 លេខERN ជាភាសាខ្មែរ មានតែភាសាខ្មែរទេ0018887 រហូតដល់ 00188879 ។

ហើយបញ្ជីអ្នកទោសចុងក្រោយមួយទៀតដែលមានឈ្មោះលោក ភឹង តុន ដែរនៅក្នុងឯកសារ D25/5/13 មានលេខ ERN ភាសាខ្មែរ 00188881 រហូតដល់ 00188882 ភាសាអង់គ្លេស ERN 00335539 រហូតដល់ 00335542 ។

បន្ទាប់មកទៀត ឯកសារមួយទៀតដើម្បីគាំទ្រពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ ប្រវត្តិរូបដែលយកបានពីស-២១ នៅក្នុងឯកសារសំណុំរឿងឯកសារនោះ គឺ D25/5/9 លេខ ERN ភាសាខ្មែរ 00188857 រហូតដល់ 00188859 ។ ក្នុងភាសាអង់គ្លេស 00239013 ។ បន្ទាប់មក នៅក្នុងសំណុំរឿង គឺឯកសារមួយទៀតផងដែរ ឯកសារនេះគឺមិនបានយកមកពីស-២១ទេ ឯកសារនោះគឺរៀបចំឡើងដោយ ឬក៏សរសេរនៅក្នុងអំឡុងពេលឃុំខ្លួនក្រៅកន្លែងមួយផ្សេងពីស-២១ ។ ហើយយើងអាចឃើញនៅក្នុងអត្ថបទភាសាបារាំង ERN 00188817 រហូតទៅដល់ 00188822 ។ ERN ភាសាខ្មែរ 00188832 រហូតទៅដល់ 0188838 ។

[០៩:៣៩:៥១]

ហើយមានឯកសារផ្សេងទៀត ដែលមានសំបុត្រមួយចំនួនដែលសរសេរដោយលោក ភឹង តុន ពេលដែលគាត់នៅបរទេស ដែលដើមបណ្ដឹងរដ្ឋប្បវេណីនឹងយោងនៅទៅរកសំបុត្រទាំងនោះនៅពេលក្រោយនៅក្នុងឯកសារហ្នឹង D25/5/1 ដែលមានលេខ ERN ជាភាសាបារាំងជាឯកសារដើម ជាភាសាបារាំងទេសំបុត្រហ្នឹង 00188811 រហូតទៅដល់ 00188812 អត្ថបទបកប្រែទៅជាភាសាខ្មែរ គឺលេខ ERN 00224277 រហូតដល់ 00224278 ។ ហើយសំបុត្រមួយទៀតសរសេរមកពីបរទេស នៅក្នុងឯកសារ D25/5/2 ហើយសរសេរជាភាសាបារាំង ជាច្បាប់ដើម លេខ ERN គឺ00188813 រហូត

00188814 ។ ហើយបន្ទាប់មកទៀត ឯកសារចុងក្រោយដែលនឹងយោងដែរ គឺD25/5/3 ដែលសរសេរនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៥ សរសេរមកពីបរទេស ។ អត្ថបទភាសាដើមជាភាសាបារាំងលេខ ERN 00188815 ហើយនៅក្នុងភាសាខ្មែរ 00284318 ។

ដល់ពេលនេះឯកសារទាំងនេះមានគ្រប់គ្រាន់ ហើយត្រូវបានប្រើជាឯកសារមូលដ្ឋានគ្រាំទ្រពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រី អ៊ឹម ស៊ុន្នី ហើយនិង ភឹង ហ្គុនស៊ុនថារី ។ បន្ទាប់ទៅនេះលោកស្រី អ៊ឹម ស៊ុន្នី នឹងធ្វើសេចក្ដីថ្លែងការណ៍ទាក់ទងទៅនឹងការឈឺចាប់ ឬក៏ទុក្ខសោកផ្ទាល់ខ្លួនរបស់គាត់ ដោយសារការបាត់បង់ស្វាមីឈ្មោះ ភឹង តុន ។ ហើយគាត់នឹងធ្វើសេចក្ដីថ្លែងការណ៍នេះ ដើម្បីរំឭកឡើងវិញនូវវិញ្ញាណក្ខន្ធរបស់ប្ដីគាត់ ។ ហើយសេចក្ដីថ្លែងការណ៍របស់គាត់នឹងខ្លី ហើយនិងមានសេចក្ដីលម្អិតអាចនឹងសម្ដែងដោយកូនរបស់គាត់ឈ្មោះ ភឹង ស៊ុនថារី ។

ដូច្នេះខ្ញុំចង់ជម្រាបអង្គជំនុំជម្រះថា លោកស្រី អ៊ឹម ស៊ុន្នី គាត់មានសុខភាពខ្សោយ ហើយដូចដែលអង្គជំនុំជម្រះអាចបានជ្រាប ជ្រាបបានខ្លះហើយ កាលណាគាត់មកដល់សាលសវនាការនេះ គាត់ចង់បញ្ជាក់អំពីសេចក្ដីការណ៍របស់គាត់ហើយនិងត្រូវអាន ។ គាត់ដូចជាមិនមានអារម្មណ៍ថា អាចឆ្លើយតបទៅនឹងសំណួរមួយចំនួនបានទេ ។ អ៊ីចឹង ខ្ញុំសូមស្នើថា ទុកឱកាសហ្នឹងដើម្បីឲ្យកូនស្រីរបស់គាត់មកធ្វើសេចក្ដីថ្លែងការណ៍ មកជាតំណាងឲ្យក្រុមគ្រួសារ ហើយអាចនឹងសាក្សីសួរទៅគាត់នោះបាន ។

អ៊ីចឹងជម្រាបដល់អង្គជំនុំជម្រះផងដែរថា លោកស្រី ភឹង ស៊ុនថារី គាត់ក៏បានរៀបចំសេចក្ដីថ្លែងការណ៍របស់គាត់ ហើយនិងអានជូនអង្គជំនុំជម្រះ ពេលនោះ គឺថាអាចនឹងអនុញ្ញាតឲ្យសួរបាន ។ លោកស្រី ភឹង ស៊ុនថារី ក៏អាចនឹងស្នើសុំសួរសំណួរទៅជនជាប់ចោទនៅពេលចុងបញ្ចប់តាមរយៈលោកប្រធាន ឬក៏អាចនឹងសួរផ្ទាល់បើសិនជាមានការអនុញ្ញាតពីលោកប្រធាន ។ នេះជាផ្នែកមួយនៃសេចក្ដីផ្ដើមបញ្ជាក់របស់ខ្ញុំ ។ អ៊ីចឹង គឺថាមានការឯកភាពទៅលើពេលវេលា ដើម្បីប្រើរួមគ្នា ដើម្បីសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរនេះ ។ ជាសេចក្ដីផ្ដើមដំបូងរបស់ខ្ញុំ គឺថាដែលខ្ញុំបញ្ជាក់ជូននូវឯកសារមួយចំនួនដែលយើងបានយោង ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតប្រគល់វេទិកានេះជូនទៅលោកស្រី អ៊ឹម ស៊ុន្នី ដើម្បីថ្លាថ្លែងសេចក្ដីថ្លែងការណ៍របស់គាត់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រី អ៊ឹម ស៊ុន្ធី ។ សូមថ្លែងរៀបរាប់ជូនដល់អង្គសវនាការទាំងមូលអំពីហេតុទាំងឡាយ ដែលលោកស្រីបានសម្រេចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះ ដែលមានការទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋ ដែលត្រូវចោទប្រកាន់ចំពោះជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។

សូមអញ្ជើញ ។

**លោកស្រី អ៊ឹម ស៊ុន្ធី៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យពេទ្យមកអង្គុយជិតខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញគ្រូពេទ្យមកអង្គុយជិតដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

**លោកស្រី អ៊ឹម ស៊ុន្ធី៖**

ឆ្នាំ១៩៧៥ ខ្ញុំនិងកូនបានជម្លៀសចេញ ជម្លៀសចេញពីផ្ទះកំណើត ធ្វើដំណើរទៅជាមួយនឹងឪពុកម្តាយរបស់ខ្ញុំ ដូចប្រជាជនទាំងអស់គ្នាទូទាំងប្រទេសនេះដែរ ។ ប្តីខ្ញុំគាត់ទៅបំពេញការងារក្រៅប្រទេស គឺនៅប្រទេសស្វីស ។ គាត់ជាអ្នក-- គាត់ជាគ្រូ គាត់ជាអ្នកច្បាប់ ផ្នែកខាងច្បាប់អន្តរជាតិ *ដ្រ័រ អាំងទែណាស្យូណាល់* (Droit International) ហើយ គឺជាអ្នកច្បាប់ពិសេស គឺច្បាប់សមុទ្រ *ដ្រ័រ ម៉ារីទីម* (Droit Maritime) នេះឯង ។

នៅថ្ងៃ១៦ ខែមីនា ១៩៧៥ ពេលនោះគ្រាប់ផ្លោងៗ ច្រើនណាស់ គឺធ្លាក់នៅចោមចៅ នៅពោធិចិនតុង ។ ដូច្នេះខ្ញុំមិនអាចជូនគាត់ដល់ពោធិចិនតុងទេ ។ កូនខ្ញុំពីរនាក់តូចៗ ជូនគាត់ត្រឹមតែកន្លែងក្រុមហ៊ុន *អ៊ែរកាំបូដស៍* (Air Cambodge) គឺនៅខាងត្បូងផ្សារថ្មី នៅវេលាម៉ោងបី សាមសិបនាទី ។ ដូចថាពេលនុ៎ងគ្រាប់ផ្លោងចូលអឺចឹង ច្រើន ខ្ញុំច្រាស់ច្រាលក្នុងចិត្តណាស់ ។ ហើយក្នុងឆ្នាំ១៩៧៥ នេះខ្ញុំគ្មានទូរស័ព្ទដៃ គឺខ្ញុំអង្គុយតែនៅប៊ុយរ៉ូគាត់ហ្នឹង អង្គុយចាំស្តាប់អាទូរស័ព្ទនៅលើតុហ្នឹង ដើម្បីតើការដែលគាត់ទៅដល់ពោធិចិនតុងហ្នឹងយ៉ាងណាទៅហើយ? ពីព្រោះនៅទីណាក៏ដោយ គ្រាប់ផ្លោងប្រសេចប្រសាចខ្លាំងណាស់ ។

[០៩:៤៣:២៣]

ខ្ញុំរង់ចាំគាត់ទាល់តែម៉ោង-- គាត់ធ្វើដំណើរចេញពីខ្ញុំទៅដល់ម៉ោងប្រាំពីរ ប្រាំពីរយប់ៗ គាត់ទូរស័ព្ទមក ។ ទូរស័ព្ទ គឺនៅថ្ងៃ១៦ ខែមីនា ហ្នឹង គាត់ទៅដល់បាងកក ។ គាត់និយាយប្រាប់យ៉ាងយូរឲ្យខ្ញុំរក្សាសុខភាព ព្រោះខ្ញុំឈឺ ខ្ញុំមានការកៀបសង្កត់ មានបញ្ហា ។ ដូច្នេះ ខ្ញុំមានសុខភាពមិនល្អ គាត់ៗ

ទូរស័ព្ទមកនិយាយហើយនិយាយទៀតឲ្យខ្ញុំគិតគូរសុខភាព កុំឲ្យខ្ញុំបង្ខំឲ្យកូនទៅរៀនពេក ពីព្រោះខ្ញុំខ្លាចខាតពេល ខ្ញុំបង្ខំកូនឲ្យខំរៀន ឲ្យធ្វើអី គាត់យល់ចិត្តខ្ញុំ គាត់និយាយនិយាយទៀត អង្វរខ្ញុំថា ឲ្យគិតគ្រាប់ផ្លោងជាធំ កុំឲ្យភ័យរឿងកូនចេះមិនចេះ ។ ហើយខ្លួនខ្ញុំហ្នឹងទៀត គឺថាធ្វើយ៉ាងឲ្យបានសុខ ពីព្រោះមើលហេតុការណ៍សិន កុំចេះបង្ខំកូនពេក គាត់ស្រឡាញ់ប្រពន្ធកូន ។ ដូច្នេះគាត់យកចិត្តទុកដាក់និយាយយូរៗ ខ្ញុំថាកុំនិយាយយូរពេកខ្លាចអស់លុយ ។ ពីព្រោះការចំណាយលុយកាក់ គឺក្រិតក្រមណាស់លោកប្រធាន ។ ខ្ញុំរៀបចំជីវិតជាមួយគ្រួសារមានក្រិតក្រម ធ្វើអ្វីក៏ដោយ គឺខ្លាចខុស ។

ពេលធ្វើដំណើរចេញទៅ ជម្លៀសចេញទៅម៉ោងប្រាំបួនព្រឹក ម៉ោងប្រាំបួនកន្លះព្រឹក គេឲ្យចេញពីផ្ទះ ខ្ញុំប្រមូលកូន បែកកូនខ្លះ ឯកូនធំ កូនប្រុសទីពីរបែក ។ ប៉ុន្តែ គេបង្ខំខ្លាំងពេក ខ្ញុំដើរចេញទៅ គេថាឲ្យទៅត្រឹមវត្ត ក៏ចេញៗទៅទៀត ។ ពេលនុ៎ងខ្ញុំបានទទួលសំបុត្រមួយនៅមុនថ្ងៃបែកហ្នឹង តាមរយៈក្រសួងការបរទេស គាត់ផ្ញើពីហ្សឺណែវ មក ។ គាត់ប្រាប់ថា គាត់ផ្ដាំឲ្យខ្ញុំគិតគូរសុខភាព គាត់មិនអីទេ គាត់នៅក្រៅប្រទេស គាត់សុខស្រួល ហើយកុំបង្ខំកូនពេក គាត់ស្រឡាញ់កូន គាត់ថាបង្ខំកូន មិនខាតពេល ព្រោះស្រុកសង្គ្រាម ធ្វើយ៉ាងណាឲ្យមានសុខភាពល្អជាចម្បង គឺថាឲ្យគិតសុខភាព ។

ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំមានកូនមួយ ដោយសារការធ្វេសប្រហែស និងដោយសារមិនទាន់ពេលវេលា គឺមានកូនប្រុសមួយ *ប៉ូលីយ៉ូ* គឺមានជម្ងឺស្វិតជើងមួយចំហៀង ។ ពេលជម្លៀសចេញទៅលោកប្រធាន គឺវេទនាណាស់ កូនអូសជើង គ្មានប្ដីនៅជាមួយ បងប្អូនគេមានគេ កូនគាត់ មានរៀងៗខ្លួន ។ កូនពៅខ្ញុំអាយុប្រាំមួយឆ្នាំឃ្លាន ដើរចេញ ។ ពេលចេញទៅខ្ញុំបានយកសំបុត្រគាត់ចុងក្រោយហើយសំឡេងទូរស័ព្ទ ដែលគាត់តេពីតេឡេហ្វូនពីថៃមក គឺជាជាសំឡេងចុងក្រោយរបស់ប្ដីខ្ញុំដែរ ។

សំឡេងនិយាយឲ្យខ្ញុំគិតគូរមែនទែន ហើយសំបុត្រនេះ គឺនិយាយដូចគាត់ទូរស័ព្ទអ៊ីចឹង ប្រាប់ថាឲ្យខ្ញុំកុំបង្ខំកូនពេក ប្រយ័ត្នកូនឃើញសៀវភៅវាទៅជាគ្រុន ពីព្រោះគាត់មើលខ្ញុំហ្នឹង បង្ខំខ្លាំង ។ គាត់និយាយៗ ហើយខ្ញុំក៏លាក់ចេញទៅ ខ្ញុំទទួលសំបុត្រហ្នឹង ហើយខ្ញុំយក មានរូបថតគាត់ រូបថតគ្រួសារនៅក្នុងកាបូបហ្នឹងដាក់ទៅជាមួយ ។ ដល់ជម្លៀសទៅកន្លែងមួយ ហើយទៅកន្លែងមួយទៀត គឺទៅកន្លែងមួយកន្លែងមួយទៀត គេឆែកឆេរ ឆែកឆែរចុះឆែកឆេរឡើងសូម្បីតែរូបថតសំបុត្រហ្នឹង ក៏គេយកដែរ យកអស់រលីងខ្ញុំគ្មានសល់រូបថតអីទេ ។

រូបថតដែលមានមួយចំនួននោះ គឺកូនខ្ញុំទៅរៀននៅប្រទេសអាល្លឺម៉ង់ ទៅ *ឡេបទិក* ហ្នឹង គាត់មានមិត្តភក្ដិគាត់នៅ *ឡេបទិក* កាលគាត់ជានិស្សិតរៀននៅវិទ្យាល័យនៅទីក្រុងប៉ារីស គាត់មានមិត្តភក្ដិ

អាល្លឺម៉ង់ ។ ហ្នឹងមានរូបថតហ្នឹង ពេលកាលនុ៎ង លោក អ៊ឹង ប៊ិច ទៅឧទ្ទេសនាមអំពីគុកទួលស្លែងហ្នឹង កូនប្រុសខ្ញុំហ្នឹងក៏លើកឡើងនិយាយ ។

លោក អ៊ឹង ប៊ិច និយាយថា លោក ភឹង តុន អីចេះមួយអីចេះពីរទៅ ហើយកូនប្រុសខ្ញុំក៏ក្រោយរឡើង និយាយថា កូនខ្ញុំហ្នឹង គឺជាឪពុកខ្ញុំហើយ ហើយពេលហ្នឹង គឺគេមានអ្នកចូលរួមហ្នឹង ជាស្រីៗមនុស្សចាស់ហើយ ក៏លើកឡើងថា ជាមិត្តភក្តិ ហើយគាត់បានឲ្យរូបថត រូបថតខ្ញុំ និងគ្រួសារខ្ញុំហ្នឹង ។ ខ្ញុំបានរូបថតមួយសន្លឹកហ្នឹងមក ពេលដែលកូនត្រឡប់មកពីរៀនវិញ ។ គឺជំនាន់ហ្នឹង គ្មានសល់អីទេ ។

[០៩:៤៩:១៣]

ខ្ញុំសូមអនុញ្ញាតជម្រាបលោកប្រធាន លោកស្រីចៅក្រម! ប្ដីខ្ញុំគាត់មានចរិត គឺថាចូលចិត្តអានសៀវភៅ ស្រាវជ្រាវរកឯកសារ ។ រកឯកសារ គឺថាធ្វើយ៉ាងណា គាត់មិនឲ្យពេលវេលាខាតទេ គឺធ្វើដាក់ពេលវេលា គាត់រៀបចំលក្ខណៈធ្វើយ៉ាងណាឲ្យមានលក្ខណៈជឿនលឿន ។ មានពេលខ្លះហ្នឹង គាត់ឲ្យខ្ញុំអានៗសៀវភៅជាភាសាបារាំងហ្នឹង ដូចជាខ្ញុំមើល *លិចទារ(lecture)* អីចឹង ខ្ញុំមើលអីចឹងទៅតែខ្ញុំ អត់បានស៊ីជម្រៅលើអត្ថបទហ្នឹងទេ ពីព្រោះកម្រិតវប្បធម៌ខ្ញុំខ្សោយ គ្មានចេះដឹងជ្រៅជ្រះនឹងគេទេ ។ ដូច្នេះ គាត់បង្រៀនៗ ឧទាហរណ៍ថា គាត់ឲ្យមើលច្បាប់ គាត់មើលសៀវភៅច្បាប់ ជាភាសាបារាំងឲ្យខ្ញុំអាន ខ្ញុំអានហើយ គាត់ពន្យល់ នេះគឺជាច្បាប់អី *ដ្រ័រ ម៉ាកស្យាល់* អានេះ *ដ្រ័រ* អីៗ គាត់ពន្យល់ជាខ្មែរលម្អិត ដើម្បីបង្កើនកម្រិតយល់ដឹងឲ្យខ្ញុំចេះដឹងនឹងគេ ឲ្យខ្ញុំមានការលូតលាស់ បង្កើនការយល់ដឹងដល់ខ្លួនខ្ញុំ ហើយដើម្បីខ្លួនខ្ញុំទៅអប់រំកូនខ្ញុំទៀត ឲ្យបានទៅជាមនុស្សល្អ ។

ខ្ញុំមាន-- ជួយទៅតាមលទ្ធភាព គឺថាខ្ញុំចេះប៉ុនណា ខ្ញុំជួយប្ដីខ្ញុំ ដូចជាគាត់កែកូពីសិស្ស ឬក៏ធ្វើអ្វីដែលខ្ញុំអាចធ្វើបាន ខ្ញុំ *វីលីវេណ្សត* កូនសិស្សអីចឹង ហើយខ្ញុំ *ក្លាសសេជីវ័រ* ហ្នឹង ដូចជា កក A, B, C, D អីហ្នឹង គឺជួយទៅតាមលទ្ធភាពដែលយើងរួមរស់ជាមួយគ្នា ។ យើងខ្ញុំទាំងពីរនាក់ មួយម្ភៃឆ្នាំ មិនដែលមានទំនាស់ ពីព្រោះមានចំណុចណាដែលខ្វះខាតខ្ញុំ ខ្ញុំក៏សុំឲ្យគាត់និយាយ គាត់មានបច្ចេកទេស ឬក៏ហៅថា ចិត្តសាស្ត្រយល់ៗ គឺគាត់រកនិយាយ ធ្វើឲ្យខ្ញុំហ្នឹងមានចរិត គាត់មានចរិតត្រឹមត្រូវស្លូតបូត គោរពនៅពាក្យសម្ដីរបស់គាត់។ គឺថាគាត់ធ្វើអី គាត់និយាយអី គឺគាត់ធ្វើហ្នឹង អ្វីដែលជាស គឺគាត់ថានឹងស ។ គាត់ថា គាត់និយាយថា បើឲ្យគាត់ថាខ្មៅ គាត់សុទ្ធចិត្តស្លាប់ គាត់និយាយអីចឹង គាត់និយាយពាក្យអីចឹងឲ្យច្បាស់ ។

ហើយមួយចំណុចទៀត គឺកាលដែលគាត់នៅធ្វើការហ្នឹង គឺមានការទាក់ទងក្នុងស្ថានទូតចុះឡើង

មានទូតបារាំង មានទូតអីហ្នឹង ដូចមានកាសែត*ឡឺម៉ុងឡ៍, អុបសែវ៉ាទ័រ, អ៊ិចប្រេស* អ៊ីចឹង ត្រង់ណាដែលវាជាការចាំបាច់ គឺគាត់គូស គូសមក ហើយខ្ញុំកាត់ ហើយ *ក្លាសេ* ដាក់ជូនគាត់ទៅតាម គឺថាក្នុងការជួយគ្នាទៅវិញទៅមក ។ ហើយគាត់ក៏រៀបចំជីវិតឲ្យខ្ញុំហ្នឹង ឲ្យស្គាល់ខុស ឲ្យស្គាល់ត្រូវ ឲ្យស្គាល់អ្វីដែលជឿនលឿន ។ គឺថាក្នុងជីវិតពេលនោះ គឺខ្ញុំបានទទួលនៅការកក់ក្ដៅលោកប្រធាន គឺថាខ្ញុំមានសំណាងដែលបានប្ដីផ្ដល់ចំណេះដឹង ផ្ដល់ការធ្វើអ្វីឲ្យតែបានជឿនលឿន ខ្ញុំមានការកក់ក្ដៅជាទីបំផុត ។

ខ្ញុំសូមជម្រាបថា ការងារដែលខ្ញុំអាចធ្វើបាន ខ្ញុំជួយគាត់ តែគាត់ គឺជា គាត់ចង់ឲ្យខ្ញុំចេះធ្វើការងារក្នុងការងារហ្នឹង ហើយអី ដល់ពេលខ្ញុំទៅស្នងជំនាន់អាពតហ្នឹង រែកទឹក ឡើងច្រាំង ចុះច្រាំងហ្នឹង ខ្ញុំចេះតែនឹកថា គ្រួសារខ្ញុំនៅអឺរ៉ុប នៅហ្សឺណែវ ឬក៏គាត់មកស្រុកបារាំង គាត់មានសំណាង មិនវេទនា។ ខ្ញុំរែកទឹកដួលធ្លាក់ពីលើច្រាំង ដួលត្រឡប់ត្រឡិនពីរបីសា ច្រាំងចោត ដងទឹកទន្លេ រែកទឹកដាក់ផ្ទះបាយផង រែកទឹកម្ដាយចាស់ ។ ខ្ញុំធ្វើគ្រប់វិធី ពីព្រោះកូនៗធំទៅនៅអង្គភាពគេ បែកអស់នៅតែកូន*ប៉ូលីយ៉ូ*មួយ ចុះទឹកពិបាក ។ ផ្ទះបាយគេ មួយថ្ងៃយ៉ាងតិចពីរជើង ខ្ញុំរែក ។ សូមជម្រាបលោកប្រធានថា ច្រាំងហ្នឹងចោទតណាស់ ច្រាំងចោត ខ្ញុំរែកបណ្ដើរយកឈើដោល ដោលឡើងមួយកាំ បន្តិចម្ដងៗ ។ កូនស្រីធំទៅនៅរែកដីនៅកន្លែងអង្គការសម្រាប់យុវនារី កូនប្រុសទៅនៅកន្លែងចាញ់ ។

[០៩:៥៥:១២]

ហើយពេលដែលពេលក្នុងរបបហ្នឹងទៀត ខ្ញុំសូមជម្រាបថា ខ្ញុំរងគ្រោះច្រើន សូម្បីតែចែករបបបាយ ខ្ញុំសូមបើកវង្វង់ក្រចកត្រង់ហ្នឹង (ដែលអង្គការជួយឧបត្ថម្ភបាយ បាយហ្នឹងគេវេចដូចអន្សមអ៊ីចឹងស្លឹកចេក ក្នុងហ្នឹងមានបាយ ហើយនិងអំបិលតិចៗ តែមួយចំនួនហ្នឹង គឺស្មៅ និងភក់) លោកប្រធាន គេខ្ចប់ដូចអន្សម បើក គឺអត់មានរបប គឺអត់មាន ធ្វើដំណើរទៅ គឺអត់មាន គឺវេទនាបំផុត បេះចែកកូនបន្តិចម្នាក់ ។ ហើយមានកន្លែងខ្លះ ខ្ញុំសូមជម្រាបថា គេធ្វើបាប គេធ្វើបាបខ្ញុំណាស់ គ្រួសារខ្ញុំ ។ មានកន្លែងខ្លះ ម្ដាយខ្ញុំគាត់ធ្លាប់ឆ្លងកាត់សង្គ្រាមថៃ គាត់ដឹងល្បិចពីសង្គ្រាម វាមានហេតុការណ៍អ៊ីចេះមួយអ៊ីចេះពីរ គាត់ប្រាប់ថា ឲ្យខ្ញុំដាំបាយទៅ ដើម្បីគ្រាន់ព្រលឹមឡើង គេចែកអង្ករបន្តិចបន្តួចហ្នឹង ក៏ដាំទៅដើម្បីយើងកាច់ កាច់ដុំបាយហ្នឹងចែកកូន ចែកកូនខ្ញុំឲ្យបាន កុំឲ្យវាឈឺ ។

សូមជម្រាបលោកប្រធានថា ដាំបាយពីល្ងាច ព្រឹកឡើងរៀបចេញ ចែកបាយកូន គេបត់ជើងដាក់ក្នុងឆ្នាំងបាយ លោកប្រធានវេទនា មិនដែលឃើញអ្នកណាទៅបត់ជើងធំដាក់ក្នុងឆ្នាំងបាយ។ ហើយខ្ញុំខ្លាចបំផុត ម្ដាយខ្ញុំថា ម្ដាយខ្ញុំថា ប្រយ័ត្នគេថា យកអង្ករចាក់ចោល ។ ម្ដាយខ្ញុំសើរស្មៅតិចៗ យកដៃ

ខ្វះកកាយ ហើយជាន់ពង្រាប ទៅបានដាក់ស្មៅពីលើ អត់ប៊ានចោលឲ្យគេឃើញ ។ ឪពុកខ្ញុំចេញទៅទៅកាប់ឫស្សី ខ្ញុំសូមលើកឡើងនិយាយក្នុងការវេទនាឈឺៗ ត្រមែងឫស្សីវែងទៅកាប់ ហើយពេលភ្លៀងមកវិញហ្នឹង គឺពិបាកវែកឫស្សីមក អាយុជាង៦០ វែកឫស្សីភ្លៀងក្តៅ ក្តៅខ្លាំង ខ្ញុំទៅសុំពេទ្យ ថាហៅពេទ្យ ពេទ្យគេនៅកន្លែងហ្នឹង ហៅពេទ្យឃុំ គេឲ្យថ្នាំ ឲ្យថ្នាំមកគាត់ប្រកាច់រៀចមាត់ ថ្នាំគ្រាប់ស្លែង ។ លោកប្រធាន គឺគ្រាប់ស្លែងដែលសម្លាប់មនុស្ស ឲ្យថ្នាំហ្នឹង ខ្ញុំទៅសុំទៀត ទៅជាមួយប្អូនប្រុសពៅថាបងប្រធាន ក្មេងទេ ប៉ុនហៅដោយគោរពអង្គការថ្នាក់លើនោះ ។

ខ្ញុំថាលោកប្រធាន សូមលោកមេត្តាឲ្យឪពុកខ្ញុំបានទៅពេទ្យតំបន់ ដើម្បីបានព្យាបាលផង គាត់ខ្លាំង គាត់អត់ដឹងខ្លួនទេ ឪពុកខ្ញុំមាំណាស់ លោកប្រធាន គាត់មាំណាស់ ។ គាត់ជាគ្រូដែរ គាត់ជាអ្នកគាត់ធ្វើអ្វីគាត់គិតវែងឆ្ងាយណាស់ គាត់ជាគ្រូ ។ ដូច្នេះគាត់អត់មាត់ទេ និយាយលែងកើតហើយ គឺរឹងថ្នាំហ្នឹង វាធ្វើឲ្យប្រកាច់ ។

ខ្ញុំថា ដល់ក្រោយ ខ្ញុំសុំ សុំប្រធានភូមិហ្នឹង គាត់ថា ថាឲ្យខ្ញុំថា “ទុកមិនចំណេញ យកចេញមិនខាត” មិត្តឯង ពេទ្យអី វេជ្ជបណ្ឌិតអី បានដឹងថា គាត់ជិតងាប់ ជិតរស់ ចំណាស់ប៉ុណ្ណឹង ស៊ីនាំតែខាតបាយ ខាតអង្ករ ។ គ្មានសីលធម៌អីបន្តិចទេ លោកប្រធាន លោកស្រីចៅក្រម ខ្ញុំមិនដែលឮទេ ខ្ញុំមិនដែលជួបប្រទះសោះ ខ្ញុំមិនដែលដឹងដល់មនុស្សខ្មែរ គ្មានមនុស្សធម៌ដល់ថ្នាក់ហ្នឹង ខ្ញុំមិនដែលដឹងសោះ ។ គេថា ខ្ញុំក្តៅពេក ក្តៅអាណិតឪពុកផង ។ ខ្ញុំខឹងពេក ខ្ញុំក៏និយាយថា បងឯងមានឪពុកម្តាយអ៊ីចឹង ដែលគិតថាឪពុកម្តាយយ៉ាងម៉េចដែរទេ? ខ្ញុំថាឲ្យ ទុកមិនចំណេញ អ៊ីចឹងបងឯងមិនបាច់ចិញ្ចឹមឪពុកទេយ៉ាងម៉េច បើឪពុកឈឺប៉ុណ្ណឹងហើយ? ប្អូនប្រុសខ្ញុំខ្លាចៗ គេយកខ្ញុំទៅសម្លាប់ ។ ប្អូនប្រុសពៅខ្ញុំហ្នឹង អូសខ្ញុំអូសខ្ញុំពីហ្នឹងមកថា អង្វរគេថា បងប្រធាន បងស្រីខ្ញុំស្រឡាញ់ឪពុកពេក និយាយខុសឆ្គង កុំប្រកាន់នឹងគាត់ ខ្ញុំដើរបន្តិចមក ប្អូនខ្ញុំថា បើគេយកទៅសម្លាប់បានអ្នកណាចិញ្ចឹមកូន កូនដល់ប្រាំពីរនាក់ បានអ្នកណាចិញ្ចឹមកូន ។

[១០:០០:១៥]

ខ្ញុំខឹងអាណិតឪពុកខ្ញុំ ហើយគេឲ្យផ្អើ គេឲ្យផ្អើៗ ភ្លើង ផ្អើភ្លើងហើយឲ្យថ្នាំ លោកប្រធានឡើងពងរលួយ គឺប្រតិកម្មគ្រាប់ស្លែងហ្នឹង ស្លាប់ឪពុកខ្ញុំទៅ ។ ក្នុងរយៈពេលពី១៧ មេសា មកថ្ងៃ៩ ខែធ្នូ ៧៥ ខ្ញុំស្លាប់អស់បីនាក់ ខ្ញុំស្លាប់បាត់បង់អស់បីនាក់ ។ ម្តាយក្មេកខ្ញុំគាត់ជរា ពេលធ្វើដំណើរទៅស្លាប់បាត់បង់ ម្តាយមីងខ្ញុំ ម្តាយខ្ញុំជាគ្រូខ្ញុំ នៅម្តាយមីងហ្នឹងដូចម្តាយបង្កើតអ៊ីចឹង គាត់ថែទាំងតាំងពីខ្លួនខ្ញុំនៅ

តូច រហូតដល់កូនខ្ញុំទៀត ខ្ញុំទៅណាទៅណីតាមគ្រួសារ គឺគាត់ថែទាំកូនហ្នឹង ត្រូវស្លាប់បាត់បង់ជំនាន់ហ្នឹងទៀត ។ វេទនាជាទីបំផុត គឺគេឲ្យថ្នាំហ្នឹង ថ្នាំហ្នឹង-- ឥឡូវហ្នឹងបានដឹងថាថ្នាំគ្រាប់ស្លែង គឺថាទទួលទានទៅញាក់ដូចសត្វអ៊ីចឹង ខ្ញុំសូមជម្រាបលោកប្រធាន ។ និយាយលំបាកណាស់ ។

ហើយខ្ញុំចេះតែនឹកក្នុងចិត្តថា ប្តីខ្ញុំហើយ បានរស់ស្រួលយ៉ាងណា យ៉ាងណាៗ បើរបបហ្នឹងធ្វើតែអ៊ីចឹង វាមិនឋិតថេរទេ ខ្ញុំនឹកក្នុងចិត្តថា វាមិនឋិតថេរទេ ។ ប៉ុន្តែ ខ្ញុំមិននិយាយ ហើយកូនខ្ញុំតូចហ្នឹងឃ្លានហ្នឹង ឃ្លានទៅនិយាយៗប្រាប់បងប្អូន ព្រោះនៅពីរនាក់បងប្អូនថា ចង់ញ៉ាំ*នំប៉័ងហ្សាំងបុង* ដល់ហើយ និយាយជជែកថា ខ្ញុំចង់*នំប៉័ងហ្សាំងបុង* ដល់ហើយ ខ្ញុំចង់ញ៉ាំសាច់មាន់ជ្រលក់ទឹកជ្រលក់ខ្ទិះអីនិយាយគ្នានឹកឃើញ ។ គេហៅខ្ញុំទៅកសាង គេហៅខ្ញុំទៅប្រៀនប្រដៅ ឲ្យប្រដៅកូន នឹកឃើញតែរបស់ចក្រពត្តិ ស៊ីរកតែឆ្ងាញ់ ថាឲ្យខ្ញុំប្រយ័ត្នបន្តិចទៅ ស៊ីៗជិះជាន់គេ ស៊ីរកតែឆ្ងាញ់ ។ ក្មេងទេ លោកប្រធានគឺគ្មានមនុស្សធម៌ ពាក្យសម្តីហ្នឹង គឺគ្មានចិត្តមេត្តាបន្តិចសោះ ។ ខ្ញុំមានអីបន្តិចបន្តួច ខ្ញុំដូរៗ ដើម្បីចង់ឃើញកូនពៅ ។ គេប្រាប់ថា មុននឹងឆ្លងកាត់ពីភូមិហ្នឹង ទៅដល់កន្លែងអង្គភាពកូនហ្នឹង មានកន្លែងឆ្កែចចក មានឆ្កែចចក ខ្ញុំភ័យខ្លាចព្រោះកូនខ្ញុំហ្នឹង ឪពុកហ្នឹងចេះលើកកុំឲ្យមានភាពខ្លាចគេ កុំឲ្យព្រហើនអីអ៊ីចឹង គឺចេះប្រដៅកូនហ្នឹងឲ្យយល់អ្វី មានសិទ្ធិនិយាយ មានសិទ្ធិថា ព្រោះគ្នាប្រាំមួយឆ្នាំកាលនុំង ខ្ញុំដូរខោអាវឲ្យគេខ្លះ ដើម្បីយកពោតស្ងោរ ពោតស្ងោរកំបោរហ្នឹង យកទៅឲ្យកូនហើយចង់ដឹងកន្លែងកូនយ៉ាងម៉េច? ទៅដល់ឃើញកូនទីប្រាំមួយហ្នឹង ឈឺ ឈឺនៅលើរនាបៗហ្នឹង ខ្ញុំលើកដៃសំពះថា មិត្តអើយកូនខ្ញុំអត់ស្រួលខ្លួនទេ ស្ទាបទៅក្តៅខ្លួន ឲ្យសុំយកទៅនេះ ។ ហើយកូនប្រុសខ្ញុំពៅនោះ ចេះលត់ដំខ្លួនហើយចេះមើលគេ គេធ្វើចន្លុះរបៀបម៉េច ធ្វើចន្លុះមកផ្ញើម្តាយ ។ គេកាយធ្វើជ័រយ៉ាងម៉េច រួចនៅភូមិណា លោកប្រធានសំឡេង តុងសំឡេងហ្នឹង គឺបត់បែនតាមគេ គេធ្វើពាក្យសម្តីហ្នឹងដូចគេ ។ វាចេះចាប់ត្រី ខ្ញុំចេះតែថា អឺ! ប្រយ័ត្នរុនពស់ខ្ញុំ ចាប់ចាញ់គេក្នុងស្រែហ្នឹង ។ វាអាណិតឃើញខ្ញុំអត់អ៊ីចឹង វាចេះចាប់ត្រី អាយុ៦ឆ្នាំហ្នឹង ដោតត្រដោតយកមកឲ្យខ្ញុំ ។ រួចទៅគេកសាង ព្រោះយើងទៅចាប់ក្នុងស្រែ វាខូចស្រូវ វាពត់ពេនខូច គេហៅឲ្យឈរហាលថ្ងៃ ។

រួចអាកូនមួយទៀតហ្នឹង អត់យល់ឃើញធ្វើការរែកដី រែកដី វាឃ្លាន មិនដឹងបានអីទទួលទានគេមកប្រាប់ព្រោះខ្ញុំអត់ដឹងកិច្ចការហ្នឹង គេមកប្រាប់ ។ វាឃ្លានពេក វាទៅវៃដូងឲ្យគេឈប់ គេចងនៅកន្លែងហ្នឹងទៀត ។ វាលំបាក ដល់នេះពេលកូនធ្វើខុសហ្នឹងហើយគេហៅម៉ែមកប្រជុំ ខ្ញុំច្រូត ច្រូតយប់ខែភ្លឺហ្នឹង ខ្ញុំច្រូតស្រូវហើយហ្នឹង គេហៅបងឲ្យទៅកសាង ។ មុនដំបូងខ្ញុំមិនយល់អាពាក្យកសាងហ្នឹងផង

ខ្ញុំមិនដឹងមានន័យយ៉ាងម៉េច ទៅកសាង ទៅដល់ គេអង្គុយនៅភ្លឺស្រែហ្នឹង គេស្តី គេថាសេរីណាស់ ធ្លាប់នៅភ្នំពេញជិះជាន់គេ មកដល់កន្លែងនេះជិះជាន់ ។ គ្នាឃ្លានម៉ោងដប់ពីរជាង គ្នាឃ្លានហើយ មិនដឹងបានស្តី នោះកូនអ្នកធ្វើ ម្តាយនេះក៏ទទួលគេស្តីបន្ទោសដែរ ។ ខ្ញុំជម្រាបលោកប្រធាន គឺថារងកម្មណាស់ ។

រហូតដល់ឆ្នាំ ១៩៧៩ ខ្ញុំចូលមកភ្នំពេញវិញហ្នឹង គឺខ្ញុំនិយាយកាត់ៗ ពីព្រោះវាហត់ ដូច្នេះខ្ញុំសូមមេត្តាអនុគ្រោះខ្ញុំនិយាយកាត់ៗ ដល់ខ្ញុំមកភ្នំពេញ ចាប់១៩៧៩ ហ្នឹងខ្ញុំដឹងថា ប្តីខ្ញុំត្រឡប់ចូលមកវិញហ្នឹងហើយ--

**សួរដោយលោកស្រី ស៊ីលឃើស្ទូត ហ្សីនស្តុះ**

**ស៖** ខ្ញុំសូមឲ្យលោកស្រី ឆ្លើយធ្វើសេចក្តីថ្លែងឲ្យមានលក្ខណៈងាយស្រួលនៅពេលដែលលោកស្រីបាន ដឹងថាតើមានអ្វីកើតឡើងចំពោះស្វាមីរបស់លោកស្រី? ដូច្នេះ ខ្ញុំសូមអនុញ្ញាត និងសូមអញ្ជើញលោកស្រីឲ្យធ្វើការពិព័រណ៌នាទៅលើចំណុចនេះ ។ ហើយបន្ទាប់មក លោកស្រីអាចរៀបរាប់អំពីទុក្ខ-សោករបស់លោកស្រី ដោយសារបញ្ហានោះមកទល់ថ្ងៃនេះ ។

**ឆ៖** សូមអរគុណ ខ្ញុំចូលមកក្នុងឆ្នាំ១៩៧៩ ខ្ញុំដឹងថាប្តីខ្ញុំគាត់ត្រឡប់ចូលមកភ្នំពេញវិញ ហើយទទួលទារុណកម្មនៅស-២១ហ្នឹង ។ ខ្ញុំសូមជម្រាបលោកប្រធាន ទុក្ខព្រួយឪពុកខ្ញុំស្លាប់ខ្ញុំ ទុក្ខមធ្យមស្រលាញ់ ឪពុកហើយ ប៉ុន្តែ ទុក្ខមធ្យម ។ ដល់ប្តីស្លាប់ខ្ញុំទុក្ខធំៗ បាត់បង់ៗប្តីខ្ញុំទុក្ខសោកៗហ្នឹង គឺថាទុក្ខសោកធំធេងមិនដឹងនិយាយជម្រាបលោកប្រធានថាម៉េចទេ។ ប្តីហ្នឹងហើយដែលផ្តល់គ្រប់បែបយ៉ាងឲ្យខ្ញុំ ។ តាំងពីកិត្តិយសសេចក្តីថ្លៃថ្នូរ ការយល់ដឹង រៀនសូត្របន្តបន្ទាប់ ខ្ញុំរៀនសូត្ររហូត គឺថាគាត់ពន្យល់រៀនសូត្ររហូត។ សាមសិបប្លាយឆ្នាំហើយ ខ្ញុំសូមជម្រាបខ្ញុំមិនដែលសប្បាយចិត្តម្តងណាឡើយ ខ្ញុំមិនដែលរីករាយអីហ្នឹងគេ ហ្នឹងឯង ។ ខ្ញុំតក់ស្លុតបំផុត ដែលមកសង្កត់សង្កិនជីវិតខ្ញុំ ដែលក្នុងក្រុមគ្រួសារខ្ញុំទទួលគ្រប់ពេលគ្រប់វេលាទាំងយប់ទាំងថ្ងៃ ខ្ញុំនឹកឃើញទាំងយប់ ខ្ញុំព្រួយទាំងយប់ទាំងថ្ងៃទុក្ខសោកហ្នឹងញ៉ាំញ៉ីរហូត ។ ពីមួយថ្ងៃៗខ្ញុំគិតៗអង្គុយស្តុងអ៊ីចឹងទៅ ធ្វើការៗមកគិតៗ ដើម្បីរកច្រកណាដើម្បីចិញ្ចឹមកូន កូនដល់ទៅប្រាំពីរនាក់ ។ ធ្វើអ្វីខ្លះ? ត្រូវធ្វើអ្វីខ្លះ? ចិញ្ចឹមកូនម្នាក់ឯង ។ រៀបចំលក្ខណៈយ៉ាងណាពីមុនមានប្តីជួយប្រាប់ឲ្យធ្វើនេះធ្វើនោះ គាត់ទៅធ្វើការទៅមកវិញគាត់ជួយប្រាប់ថាធ្វើអ៊ីចេះ ដោះស្រាយអ៊ីចេះ ដល់ឥឡូវម្នាក់ឯង ត្រូវធ្វើម៉េចដើម្បីឲ្យកូនបានរៀនសូត្រចេះដឹងតាមចំណង់ចិត្តកូនចង់រៀនពីព្រោះកូនខ្ញុំចូលចិត្តរៀនសូត្រតាមឪពុកដែរ ។ ព្រោះកាលគាត់អប់រំពីក្មេងគាត់បង្ហាញ

គាត់គូររូបអីឲ្យមើល ហើយគាត់និយាយរឿង ប្រាប់អីចេះអីចុះ កូនហ្នឹងវាមានចរិតមួយ គឺថាស្រលាញ់ការចេះដឹងហ្នឹងដែរពេលនោះ ។

ខ្ញុំគិតថាធ្វើម៉េច បើយើងគ្មានផ្ទះនៅផ្ទះមក ពីមុននៅខាងត្បូងវិមានឯករាជ្យដល់ត្រឡប់មកវិញគេបែងចែកអីចឹង ខ្ញុំគ្មានផ្ទះ គ្មានអ្វីៗទាំងអស់ កូនដល់ទៅប្រាំពីរនាក់ ។ កូនចង់រៀនថាធ្វើម៉េច? ម៉្វៗគិតចុះគិតឡើង លំបាកៗនោះក្រៃណា សុញចុះសុញឡើង ខ្ញុំសូមជម្រាបលោកប្រធាន ។ ខ្ញុំចង់សម្លាប់ខ្លួន ខ្ញុំចង់ឲ្យស្លាប់ផុតកុំឲ្យដឹងឮ ពិបាកទៅៗ ។

ណាទឹកឃើញគាត់វេទនាហ្នឹងៗ វេទនាប៉ុនណាទៅ? ព្រោះខ្ញុំ ខ្ញុំគិតគូរសុខភាពគាត់ណាស់ ខ្ញុំថ្នមគាត់ ខ្ញុំជម្រាបលោកប្រធាន ខ្ញុំស្រលាញ់គាត់ ខ្ញុំថ្នមគាត់ ខ្ញុំគិតគូរសព្វបែបយ៉ាងមិនឲ្យប៉ះទង្គិចប្ដីខ្ញុំទេ ។ ខ្ញុំការពារទោះមានអាសន្នលំបាកប៉ុនណា ខ្ញុំសុំថាបងនៅរស់ ខ្ញុំគ្មានចេះអី បងនៅរស់ដើម្បីមើលកូន ។ អាសន្នយ៉ាងម៉េចក៏ខ្ញុំជួយគាត់ ដើម្បីយើងបានជួបជុំគ្នាយើងបានរស់តទៅមុខទៀត ។

ខ្ញុំនឹកចុះនឹកឡើងខ្ញុំសុញៗណាស់ កូនវាគ្មានស្អីទម្លាប់ គេហៅថាខ្វះខាត គឺវាស្មុគស្មាញណាស់លោកប្រធាន មានចំណុចក្រ ហើយគឺលំបាកហ្នឹងនិយាយណាស់ ។ កូនប្រុសប្រាំមួយ ខ្ញុំជម្រាបលោកប្រធាន កូនប្រុសប្រាំមួយ កូនស្រីមួយ, ប្រាំពីរនាក់ ។ ហើយកូនឪពុកអប់រំអីចឹង វាមានសិទ្ធិនិយាយអ្វីដែលវាយល់ដឹង គឺនិយាយតែម្ដង និយាយបើខ្មែរយើងថាព្រហើនដាក់ម៉ែឪ ប៉ុន្តែមិនមែនទេ ពីព្រោះទស្សនៈរបស់គេ គេយល់អីចេះ គាត់យល់អីចេះគាត់ប្រាប់មក គាត់ប្រាប់មកត្រង់ៗអីចឹងតែម្ដង គាត់ចង់អីគាត់និយាយអីចឹងតែម្ដង។

ខ្ញុំរស់នៅដោយលំបាកៗដោះស្រាយផុតមុខផុតក្រោយ រកវិធីពិបាកចិត្ត ពិបាកនោះពិបាកហើយ យំមិនឲ្យកូនឃើញទេ ខ្ញុំពួនយំ ជួនណាកូនទៅបាត់ខ្ញុំស្រែកក្នុងបន្ទប់ទឹក វាពិបាកពេក វាពិបាកខ្លាំងពេក ។

ខ្ញុំជម្រាបដោយស្មោះ គឺថាពេលនុ៎ងចេញមកវិញហើយ គ្មានអីទទួលទានគ្រប់គ្រាន់ទេ ព្រោះយើងគ្មានអី គ្មានអ្វីនេះ គឺឲ្យកូនទទួលទានមុន ហើយឲ្យទៅរៀនទៅហ្នឹង តិចតួចសម្រាប់ចិញ្ចឹមខ្លួនខ្ញុំ ខ្ញុំទទួលទានចួនណា ជាមួយបានទឹកត្រី ញ៉ុចម្ទេសអីទៅ ។ ឲ្យកូនមានម្ហូបពីព្រោះយើងវាខ្វះខាត ប្រាក់ខែដែលខ្ញុំធ្វើការក៏វាតិច កាលខ្ញុំធ្វើការនៅក្រសួងគមនាគមន៍ពេលនោះ ហើយកូនកំពុងតែរៀនត្រូវការទិញសៀវភៅទិញអីវាមានខ្វះខាត ។ ប្អូនខ្ញុំមានដែរ ប៉ុន្តែ ខ្ញុំមិនចង់រំខាន ពីព្រោះគេមានប្រពន្ធគេ គេមានអីត្រូវដោះស្រាយក្នុងគ្រួសារគេ ខ្ញុំមិនដែលនិយាយឲ្យពិបាក ឲ្យបងប្អូនខ្វាយខ្វល់នឹងខ្ញុំទេ ។ ខ្ញុំទទួលទាន

បាយជាមួយទឹកត្រីក៏មានដែរ ខ្ញុំជម្រាបលំបាក ។ ហើយឲ្យកូនទៅមុន ធ្វើម៉េចឲ្យកូនបានរៀន ។

បានសេចក្តីថា ដូចខ្មែរនិយាយអ៊ីចឹងថា លក្ខណៈជាស្ត្រីមេម៉ាយ គឺធ្វើជាស្រីផងធ្វើជាប្រុស លោកប្រធានគឺធ្វើជាប្រុស ។ ហើយក្នុងការងារខ្ញុំនៅក្រសួងហ្នឹង គេឲ្យខ្ញុំចុះខេត្តទៀត ហើយមកកូននេះត្រូវរៀន ហើយខ្ញុំគេឲ្យទៅរៀនទៀត រៀនការងារ រៀនរហូតមានពេលខ្លះគេហៅរៀនវគ្គធំ វគ្គតូច ខ្ញុំគេបញ្ជូនទៅរៀនអ៊ីចឹងទៅ ហើយកូននេះឲ្យចេះធ្វើយ៉ាងណាឲ្យត្រឹមបានអ្នកណាមកមុនចូលមកដាំបាយទៅ គឺថាបង្រៀនកូនហ្នឹង ឲ្យចេះតស៊ូនឹងជីវិតទៀត ។

[១០:១៥:00]

គឺថាខ្ញុំធ្វើជាស្រីផង ប្រុសផង ដួលហើយប្រឹងដោលងើបៗអង្គុយ ដើម្បីពុះពារគ្រប់ឧបសគ្គទាំងឡាយលោកប្រធានវេទនាណាស់ ទុក្ខវេទនា ។ ពេលខ្ញុំមកចូលរួមសវនាការនេះ ខ្ញុំចូលរួមស្តាប់សវនាការ សវនាការហ្នឹងឃើញភាព ស្តាប់ទៅវា ឃោរឃៅ ហើយឃើញរូបថតគេបង្ហាញ រ៉ូបើត ហាមីល នឹងបង្ហាញរូបថតវ៉ើ ខ្ញុំរន្ធត់ ខ្ញុំយល់ថាប្រហែលប្តីខ្ញុំគេចងមុខ ចងដៃ បង្អត់បាយធ្វើបាបយ៉ាងណាទេ ខ្ញុំទៅផ្ទះវិញ ខ្ញុំលេបថ្នាំសសៃប្រសាទ ។ លេបៗថ្ងៃមុនខ្ញុំមកសន្លប់នៅហ្នឹង ខ្ញុំសន្លប់នៅសាលាក្តី ។ វេទនាផ្លូវចិត្តណាស់ រហូតដល់ពេលនេះខ្ញុំមានជំងឺរីកបេះដូង ស្ទះថ្ងៃខ្លះខ្ញុំស្ទះ ។ ខ្ញុំត្រូវរស់រាល់ថ្ងៃហ្នឹងទទួលទានថ្នាំ លោកប្រធាន ដោយសារជំងឺ អាជំងឺដែលខ្វល់ខ្វាយខ្លោចផ្សាថ្ងៃមុនខ្ញុំចង់ស្ទះពេលគេបញ្ចាំងៗការធ្វើទារុណកម្មជាប់ខ្នោះ ខ្ញុំគេចមុខអត់ហ៊ានមើល ខ្ញុំអត់ហ៊ានមើលពីព្រោះស្លុតពេក ។

**សៈ** លោកស្រី ស៊ុន្ទី ខ្ញុំចង់សួរសំណួរមួយជូនលោកស្រី ប្រហែលជាលោកស្រីអាចបញ្ចប់ ហើយថាតើវាមានការពិបាកយ៉ាងណាដែលចិញ្ចឹមកូនដោយគ្មានប្តី ស្វាមីនេះ ។ ហើយលោកស្រីបានឡើងតស៊ូ ប្រឆាំងទៅនឹងឧបសគ្គទាំងអស់នេះ ប្រហែលជាលោកស្រីនៅពេលនេះ នៅចំណុចចុងក្រោយនេះអាច ធ្វើការសង្ខេបថាតើលោកស្រីមានបំណង និងមានប្រាថ្នាអ្វីនៅចំពោះមុខតុលាការនេះ? ហើយហេតុអ្វីបានជាលោកស្រីមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី? ហើយតើលោកស្រីមានប្រាថ្នាចង់បានអ្វីពី តុលាការមួយនេះ? លោកស្រីអាចធ្វើការសង្ខេបនៅពេលនេះ ហើយបន្ទាប់មកខ្ញុំសូមអនុញ្ញាតឲ្យវេទិកានេះទៅឲ្យ ស៊ុនថារី ម្តង ។

**ឆៈ** ចាស, អរគុណលោកស្រី ។ ខ្ញុំសុំដោយសារការនិយាយបើកកកាយនេះឡើង គឺថាធ្វើឲ្យរង្គោះរង្គើផ្លូវចិត្តខ្ញុំណាស់។ ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំមកតុលាការនេះ គឺដើម្បីគោរពដល់វិញ្ញាណក្ខន្ធប្តី ខ្ញុំ បងប្អូនខ្ញុំ ប្អូនស្រីខ្ញុំដែលបាត់បង់ ។ ហើយខ្ញុំសូមបញ្ជាក់ជូនថា គឺមានពាក្យខ្លះថាខ្ញុំមកតុលាការ

នេះដើម្បីសងសឹក គេនិយាយនៅក្នុងសាលនេះឯងថាជា *វង់ហ្សង់* ។ ខ្ញុំថាមិនមែនទេ ខ្ញុំមកតុលាការនេះដើម្បីផ្តល់យុត្តិធម៌ ។ ទីមួយឲ្យប្តីខ្ញុំ តើគេធ្វើគេកាប់សម្លាប់មនុស្សហ្នឹង គឺថាវែកមុខឲ្យឃើញច្បាស់ តើគេធ្វើអំពើព្រៃផ្សៃទាំងអស់នេះ ដើម្បីបំបាត់ពូជសាសន៍ខ្មែរឬយ៉ាងណា? ដើម្បីអ្វី? ដើម្បីបុណ្យស័ក្តិខ្លួនឯង ឬដើម្បីតំណែងនាទីរបស់ខ្លួនយ៉ាងណាខ្លះ? ហើយកន្លងមកខ្ញុំសុំអនុញ្ញាតតាមរយៈលោកប្រធាន គឺថាខ្លួនជាសាស្ត្រាចារ្យមួយរូបដែរ គឺត្រូវយល់អំពីចិត្តសាស្ត្រគរុកោសល្យ ត្រូវមានព្រហ្មវិហារធម៌ ត្រូវគោរព គឺថាគោរពនូវពាក្យសម្តី ត្រូវមានវិហារធម៌ ត្រូវមានសម្បជញ្ញៈ ដើម្បីយើងធ្វើយ៉ាងណាឲ្យប្រទេសជាតិមាតុភូមិរបស់ខ្លួនថ្កុំថ្កើង មិនមែនដើម្បីតំណែងនាទីដើម្បីអំណាចនោះទេ ។

ខ្ញុំសូមបញ្ចប់ត្រឹមនេះ ។ សូមលោកប្រធាន លោកស្រីចៅក្រម មេត្តាអនុគ្រោះនូវពាក្យឆ្គាំឆ្គងដែលខ្ញុំអចេតនាដោយការឆេះឆួលទុក្ខព្រួយពេក ។ សូមអរគុណលោកប្រធាន ។

[១០:១៩:២៧]

**ប្រធានអង្គជំនុំ៖**

កញ្ញា ស្ទួតហ្សិនស្តី តើមានសំណួរអ្វីសួរដល់ដើមបណ្តឹងរដ្ឋប្បវេណី នេះដើម្បីបញ្ជាក់បន្ថែម ឬក៏គាំទ្រដល់ការទាមទាររបស់គាត់ដែរឬទេ?

**លោកស្រី ស៊ីលឃី ស្ទួតហ្សិនស្តី៖**

អត់ទេ លោកប្រធាន ខ្ញុំពុំមានសំណួរបន្ថែមទៀតទេ នៅពេលនេះ ។ ប៉ុន្តែខ្ញុំសូមថ្លែងអំណរគុណលោកស្រី ស៊ុន្ទី យ៉ាងច្រើនដែលលោកស្រីបានមកថ្ងៃនេះ នៅក្នុងតុលាការរបស់យើងដើម្បីរំឭកវិញ្ញាណក្ខន្ធទៅដល់ស្វាមីរបស់លោកស្រី ហើយនិងសមាជិកគ្រួសារទាំងអស់ និងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស។ ហើយខ្ញុំសូមថ្លែងអំណរគុណលោកស្រីយ៉ាងច្រើនដែលលោកស្រីមានលទ្ធភាពហើយខិតខំអង្គុយនៅចំពោះមុខតុលាការ ហើយប្រឈមមុខទៅលើព្រឹត្តិការណ៍មួយនេះ ។

ដូច្នេះ គឺខាងខ្ញុំពុំមានសំណួរនោះទេ ។ ហើយបន្ទាប់មកប្រសិនបើភាគីផ្សេងមិនមានសំណួរទេ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានផ្តល់វេទិកានេះទៅដល់ លោកស្រី ស៊ុនថារី ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា តើមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ?

**លោក វាំងសង់ វាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន ដូចដែលបានស្នើឡើង គឺយើងខ្ញុំពុំមានសំណួរនៅពេលនេះទេ ប្រសិន

បើយើងមាន យើងនឹងសួរទៅកាន់កូនរបស់លោកស្រី ។ ហើយយ៉ាងណាក៏ដោយខ្ញុំសូមថ្លែងអំណរគុណចំពោះលោកស្រីដែលមកចូលរួមនៅក្នុងព្រឹកនេះ ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី តើមានសំណួរត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន យើងខ្ញុំជាមេធាវីការពារគ្មានសំណួរអ្វីសួរទៅលោកស្រី ស៊ុន្នី ទេ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

លោកស្រី ដំណើរការនៃការស្តាប់សេចក្តីថ្លែងការណ៍របស់លោកស្រី ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីឃើញថាដល់ទីបញ្ចប់ហើយ ។ ហើយតាមពេលវេលាដែលបានគ្រោងទុកឃើញថាពេលវេលាជាច្រើន គឺបានផ្តល់ទៅកូនស្រីរបស់លោកស្រី ដែលគាត់នឹងធ្វើការសេចក្តីថ្លែងការណ៍ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ពីលោកស្រី ។ អ៊ីចឹង លោកស្រីអាចសម្រាកបាន សូមអញ្ជើញទៅកន្លែងសម្រាកចុះ ទាំងគ្រូពេទ្យផង ។

ហើយដោយសារពេលវេលាក៏សមរម្យនឹងអាចសម្រាកដែរគឺអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទីចូលវិញដើម្បីបន្តកិច្ចដំណើរការនីតិវិធី ចៀសវាងដើមបណ្តឹងរដ្ឋប្បវេណីគាត់ឡើងធ្វើសេចក្តីថ្លែងការណ៍ហើយមានការសម្រាកកណ្តាលទី ។

អ៊ីចឹងសម្រាកតាំងពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សឹមអញ្ជើញចូលវិញ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:២៣នាទី ដល់ម៉ោង ១០:៤៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សេក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយជាបន្តនេះ ដល់ពេលវេលាដែលត្រូវស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេនី ភីង ហ្គុតស៊ុនថារី ។

សូមអញ្ជើញលោកស្រី ភឹង ហ្គុតស៊ុនថារី អញ្ជើញមកកាន់កៅអីរៀបចំទុកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ ។

*(លោកស្រី ភឹង ហ្គុតស៊ុនថារី ចូលមកកាន់បន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្រីមានឈ្មោះ ភឹង ហ្គុតស៊ុនថារី អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** ចាស, ជម្រាបលោកប្រធាន យើងខ្ញុំឈ្មោះ ភឹង ហ្គុតស៊ុនថារី ។

**ស៖** លោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ចាស, នាងខ្ញុំមានអាយុ៥៣ ឆ្នាំ ។

**ស៖** លោកស្រីមានសញ្ជាតិអ្វីដែរ?

**ឆ៖** នាងខ្ញុំមានសញ្ជាតិបារាំង តែជាជនជាតិកំណើតខ្មែរ ។

**ស៖** ទីកន្លែងកំណើតរបស់លោកស្រីនៅទីណា?

**ឆ៖** នាងខ្ញុំកើតនៅសង្កាត់លេខ៦ ក្រុងភ្នំពេញ ។

**ស៖** ហើយសព្វថ្ងៃនេះ តើលោកស្រីមានទីលំនៅនៅឯណា? ហើយលោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** សព្វថ្ងៃនេះ នាងខ្ញុំនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ នាងខ្ញុំជាអតីតអ្នកបណ្ដុះបណ្ដាលគរុនិស្សិតផ្នែកភាសាបារាំងក្នុងវគ្គពីរឆ្នាំ ដែលត្រូវបំពេញការងារជាសាស្ត្រាចារ្យភាសាបារាំង នៅតាមបណ្ដាខេត្តនានានៃព្រះរាជអាណាចក្រកម្ពុជា ។

[១០:៤៧:៥៦]

**ស៖** តើឪពុកលោកស្រីមានឈ្មោះអ្វី?

**ឆ៖** ឪពុកនាងខ្ញុំឈ្មោះ ភឹង តុន ។

**ស៖** ចុះម្ដាយរបស់លោកស្រី គាត់មានឈ្មោះអ្វី?

**ឆ៖** ម្ដាយនាងខ្ញុំឈ្មោះ អ៊ឹម ស៊ុន្ធី ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅលោកស្រី ដើម្បីលោកស្រីមានឱកាសក្នុងថ្លែងរៀបរាប់ជូនដល់អង្គសវនាការ អំពីរឿងហេតុទំនាក់ទំនងរបស់លោកស្រីទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងពេលបង្កើត និងប្រតិបត្តិការមន្ទីរសន្តិសុខស-២១ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ ដែលនាំឲ្យលោកស្រីសម្រេចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកស្រីជាអាទ៍ផ្នែកខាងរាងកាយសម្ភារៈ ឬផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ ដែលកើតមានពីបទឧក្រិដ្ឋជាព្យសនកម្មផ្ទាល់ ខ្លួនហើយកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ។ សូមអញ្ជើញ ។

**លោកស្រី ភីង ហ្គុតស៊ុនថារី៖**

ចាស, សូមអរគុណលោកប្រធាន និងសូមអរគុណអង្គជំនុំជម្រះ ដែលបានអនុញ្ញាតឲ្យនាងខ្ញុំបានមកអង្គុយដើម្បីធ្វើសេចក្តីថ្លែងការណ៍នៅថ្ងៃនេះ ។ ជាដំបូង នាងខ្ញុំពិពណ៌នាអំពីអនុស្សាវរីយ៍ពីមនោសញ្ចេតនារវាងឪពុកនាងខ្ញុំនិងរូបនាងខ្ញុំតាំងពីកុមារភាព រហូតដល់យុវភាព និងនាងខ្ញុំមានបំណងឧទ្ទិសចំពោះវិញ្ញាណក្ខន្ធក្នុងនាមជាមនុស្សត្រឹមត្រូវ និងសុច្ចរិតម្នាក់ដល់ឪពុកនាងខ្ញុំ ។ នាងខ្ញុំពិពណ៌នានៅពេលដែលនាងខ្ញុំបានឃើញគាត់ជាចុងក្រោយបង្អស់ ។ បន្ទាប់មកៗក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ដែលពេលនោះនាងខ្ញុំពុំបានដឹងថាគាត់ត្រឡប់មកនៅប្រទេសខ្ញុំវិញទេ ។ នាងខ្ញុំនឹងធ្វើការពិពណ៌នាពីការឈឺចាប់និងភាពក្តុកក្តួលដែលកើតមានឡើងបន្ទាប់ពីបានដឹងថា គាត់ត្រូវគេសម្លាប់នៅមន្ទីរស-២១។ ជាបន្ទាប់មកទៀត នាងខ្ញុំនឹងរៀបរាប់ពីលទ្ធផលនៃការស្រាវជ្រាវដែលបានធ្វើឡើង ព្រមទាំងសំណួរដែលនាងខ្ញុំបានទទួលពីជនជាប់ចោទ ប៉ុន្តែជាចម្លើយដែលមិនជាក់លាក់រហូតដល់ថ្ងៃនេះ ។

[១០:៥១:២២]

លោកប្រធាន តាមរយៈនៃសេចក្តីថ្លែងការណ៍នេះ នាងខ្ញុំសូមឧទ្ទិសដល់វិញ្ញាណក្ខន្ធឪពុកនាងខ្ញុំ និងផ្តល់ជូនទៅគាត់ឋានៈគាត់ជាអ្នកទោសនៅស-២១ ដែលពាក់ស្លាកលេខ១៧ នូវភាពរស់រវើករបស់គាត់ឡើងវិញ ។ នាងខ្ញុំសុំការអនុញ្ញាតពីលោកប្រធាននិងអង្គជំនុំជម្រះបង្ហាញពីរូបថតដែលនៅសេសសល់ជាអនុស្សាវរីយ៍រវាងគាត់និងគ្រួសារខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីតុលាការយករូបថតពីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយដាក់បញ្ចាំងនៅម៉ាស៊ីនស្លាយ ដើម្បីបង្ហាញរូបភាពនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

មើលមន្ត្រីខាងសោតទស្សន៍មើលស្លាយមើល ដូចមានពន្លឺខ្លាំងមើលមិនច្បាស់ទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញថ្លែងការណ៍បន្តលោកស្រី ។

[១០:៥៨:១២]

**លោកស្រី ភីង ហ្គុតស៊ុនថារី៖**

ចាស,អរគុណលោកប្រធាន ។ លោកប្រធាន ជាបឋមនាងខ្ញុំសូមបំពាក់ទៅលើរូបថតពាក់ស្លាកលេខ១៧ ដែលយើងទាំងអស់គ្នាបានឃើញអម្បាញ់មិញនេះឲ្យមានជីវិតរស់រវើកឡើងវិញ ។ រូបពាក់ស្លាកលេខ១៧ ដែលដៃជាប់ខ្នោះ និងដែលបានក្លាយជាសំរាម ពេលដែលស-២១ ចងមុខរុញឡើងលើឡាននៅម៉ោង១០ព្រឹកនាថ្ងៃទី១២ ខែធ្នូ ៧៦ នៅផ្សារដើមថ្កូវ និងនាំយកមកឃុំឃាំងធ្វើទារុណកម្មនៅទីនោះជាទីដែលគាត់ត្រូវបានគេមើលងាយ ប្រមាថ និងទទួលរងបទឧក្រិដ្ឋទាំងអស់ ដែលស-២១ប្រព្រឹត្តទៅលើគាត់ ។ ទីបញ្ចប់គាត់ត្រូវបានពួកគេកម្ទេចចោល ។

លោកប្រធាននិងអង្គជំនុំជម្រះ! នាងខ្ញុំមានបំណងប្រាថ្នាពិពណ៌នាពីបុគ្គលិកលក្ខណៈ អត្តចរិត និងរបៀបប្រកាន់ខ្ជាប់ខ្លួនប្រកបដោយគុណធម៌របស់គាត់ក្នុងឋានៈជាឪពុក និងជាមនុស្សដែលរស់នៅក្នុងសង្គមកម្ពុជាម្នាក់ធ្លាប់បានគេគោរព ឲ្យមានភាពរស់រវើកឡើងវិញ ។ ឪពុកនាងខ្ញុំមានចរិតអំណត់ព្យាយាម ពេញមួយជីវិតរបស់គាត់ គាត់ជាមនុស្សនឹងន ពោរពេញដោយគតិបណ្ឌិត យកចិត្តទុកដាក់ និងមិនក្រអើតក្រទម ។ គាត់តែងតែស្តាប់កូនៗទោះជារឿងតូចតាចយ៉ាងណាក្តី ជាមួយនឹងការយកចិត្តទុកដាក់ និងមិនក្រអឺតក្រទម ។ គាត់តែងតែស្តាប់កូនៗ ទោះជារឿងតូចតាចយ៉ាងណាក្តីជាមួយនឹងការយកចិត្តទុកដាក់ និងតែងតែមានពេលវេលាជានិច្ចសម្រាប់កូនៗ ទោះបីជាខ្លួនគាត់មមារញឹកយ៉ាងណាក៏ដោយ ។ កុំថាឡើយដល់តែលើករំពាត់វាយកូន សូម្បីតែសម្តីរបស់គាត់ក៏ខ្ញុំពុំដែលឮគាត់ស្រែក ឬគំហកកំហែងម្តងណាសោះឡើយ ។ ជានិច្ចកាលគាត់តែងតែបង្រៀនយើងជាកូនគាត់ កូនៗ ឲ្យស្គាល់អ្វីដែលជាតម្លៃមនុស្សជាតិ ដែលរូបគាត់ផ្ទាល់តែងតែការពារតម្លៃនេះរហូតដល់ចុងបញ្ចប់នៃជីវិតរបស់គាត់ ។

ឪពុកខ្ញុំបានបង្ហាញកូនៗ ឲ្យយល់ឃើញថា តើយើងត្រូវធ្វើដូចម្តេច ដើម្បីដោះស្រាយជម្លោះ

និងធ្វើយ៉ាងម៉េចកុំឲ្យមានការគុំកួនគ្នា ។ គាត់បានបង្រៀនពួកយើងឲ្យមានការសន្តោសប្រណីដាក់គ្នា ។ បង្ហាញឲ្យយើងដឹងអ្វីដែលហៅថា ភាពថ្លៃថ្នូររបស់មនុស្ស អ្វីៗដែលគាត់បង្រៀនយើងនេះ គឺមិនត្រឹមតែថាឲ្យតែរួចពីមាត់ទេ គឺវាស្តែងចេញឡើងពីសកម្មភាពដែលកើតមានឡើងជារាល់ថ្ងៃ ។ គាត់គឺជាឪពុកគំរូម្នាក់ចំពោះកូនៗទាំងអស់គ្នា ដែលប្រកបទៅដោយគុណធម៌ ហើយគុណធម៌របស់គាត់នៅដក់ជាប់ជានិច្ចក្នុងចិត្តកូនៗទាំងអស់ ។ យើងនៅតែគោរពនិងស្រលាញ់គាត់ជាប់ជានិច្ច ។ នៅពេលដែលកូនៗកាន់តែធំដឹងក្តីឡើង យើងយល់និងដឹងថា មនុស្សម្នាផងទាំងពួកគោរពកោតសរសើរគាត់ក្នុងក្របខ័ណ្ឌនៃគោលគំនិតមួយប្រកបដោយមនុស្សធម៌ ។ កូនៗតែងតែបានទទួលការថ្នាក់ថ្នម ការយកចិត្តទុកដាក់ពីគាត់គ្រប់ពេលវេលា តាមរយៈពាក្យសម្តី កាយវិការ ការស្រលាញ់យ៉ាងជ្រាលជ្រៅរបស់គាត់ និងចំណងមនោសញ្ចេតនា ដែលចងភ្ជាប់ពីឪពុកទៅកូនពីកូនទៅឪពុកដែលធំធេងណាស់លោកប្រធានមនោសញ្ចេតនានេះមិនអាចកាត់ថ្លៃបានទេ ។

ជានិច្ចកាល គាត់បានការពារពួកយើង គាត់គឺជាជម្រករបស់យើងទាំងអស់គ្នាទប់ទល់ជាមួយនឹងពិភពខាងក្រៅ ធ្វើឲ្យយើងជាកូនៗទទួលបាននូវភាពកក់ក្តៅ ទំនុកចិត្តពីគាត់ជាឪពុក ។ ព្រឹត្តិការណ៍ខ្លីៗដែលកើតមានឡើងកាលពេលនោះ នឹងបញ្ជាក់ពីអ្វីដែលនាងខ្ញុំទើបនឹងបានរាយរ៉ាប់ ។

មានថ្ងៃមួយភ្លៀងធ្លាក់យ៉ាងខ្លាំង កាលនោះខ្ញុំអាយុប្រហែលជា៥-៦ឆ្នាំ ម្តាយខ្ញុំមើលមិនទាន់ខ្ញុំលួចចេញពីបន្ទប់ខ្ញុំទៅលោតលេងក្រោមទឹកភ្លៀងនៅរានហាល ខ្ញុំក៏រអិលដួលហើយបែកចង្កា ។ ម្តាយខ្ញុំបានប៉ង់ស៊ីម៉ង់ត៍ឲ្យខ្ញុំ ។ នៅពេលដែលឪពុកខ្ញុំមកដល់ផ្ទះភ្លាម គាត់បានលួងលោមខ្ញុំ រួចពខ្ញុំទៅផ្ទះដុកទ័រ ជួន ជឿន ដើម្បីឲ្យគាត់ដេរចង្កាខ្ញុំ ។ រឿងទាំងនេះ បានកន្លងផុតទៅក្នុងអតីតកាលមួយដ៏យូរលង់ ក៏ប៉ុន្តែនាងខ្ញុំនៅតែចងចាំនូវអារម្មណ៍និងសញ្ចេតនាយកចិត្តដាក់របស់គាត់ ដែលបានសម្រាលការឈឺចាប់របស់ខ្ញុំ ។ ហើយដែលខ្ញុំនៅតែចងចាំរហូត ទោះបីជារឿងនេះបានកន្លងផុតជិតហាសិបឆ្នាំក៏ដោយ ក៏នាងខ្ញុំនៅតែចាំបាន ។

នាពេលមួយក្នុងថ្ងៃអាទិត្យ ខ្ញុំនិងគាត់នាំគ្នាដើរលេងតែពីរនាក់តាមមាត់ទន្លេ នាងខ្ញុំនៅតូចនៅឡើយ ពេលចុះពីលើឡាន គាត់តែងតែហុចដៃឲ្យខ្ញុំកាន់ដៃគាត់ ។ គាត់បានដាក់ដៃគាត់ពេលនោះទៅក្នុងមាត់តោ គឺរូបតោដែលតាំងនៅមុខព្រះអង្គដងកើ ហើយគាត់និយាយថា អូលេ តោខាំដៃប៉ា ។

សូមជម្រាបទៅលោកប្រធាននិងអង្គជំនុំជម្រះថា ឈ្មោះនៅផ្ទះឪពុកម្តាយខ្ញុំហៅ អូលេ ពីព្រោះជាការបូកបញ្ចូលនៃសម្បុរពីរ ឪពុកខ្ញុំមានសម្បុរខ្មៅ ឯម្តាយខ្ញុំសម្បុរស ដូច្នេះពួកគាត់តែងតែហៅខ្ញុំថា

កាហ្វេអូលេ ។ គាត់និយាយថា អូលេ តោខាំដៃប៉ា ខ្ញុំស្រែកយំ ព្រោះខ្ញុំភ័យខ្លាចគាត់ឈឺ ។ ប៉ាស្ទុះមកឱបខ្ញុំ និងលួងខ្ញុំ ។

អនុស្សាវរីយ៍នៃកុមារភាពរបស់នាងខ្ញុំបានបង្ហាញឲ្យដឹងថា ខ្ញុំជិតដិតនឹងឪពុកខ្ញុំថាខ្ញុំចង់ការពារឪពុកខ្ញុំប៉ុនណា តាំងពីខ្ញុំនៅតូចម្ល៉េះ ។ ទាំងអស់នេះហើយជាហេតុផលមួយដែលវាជាកាតព្វកិច្ចរបស់នាងខ្ញុំ ដែលត្រូវឡើងថ្លែងការណ៍នៅចំពោះអង្គសវនាការនៅថ្ងៃនេះ ដើម្បីឧទ្ទិសទៅដល់វិញ្ញាណក្ខន្ធគាត់ទៅដល់សេចក្តីថ្លៃថ្នូររបស់គាត់ ដែលស-២១ បានប្លន់យកសេចក្តីថ្លៃថ្នូរនេះពីគាត់ នៅក្នុងអំឡុងពេលចុងក្រោយនៃជីវិតរបស់គាត់ ។ ភាពកក់ក្តៅនិងសប្បុរសធម៌របស់គាត់ដែលផ្តល់ទៅឲ្យកូនៗ បានធ្វើរូបគាត់ឲ្យក្លាយទៅជាសរសរទ្រូងយ៉ាងរឹងមាំ និងជាចំណុចកណ្តាលរបស់គ្រួសារយើង ។ គាត់តែងតែធ្វើឲ្យអស់លទ្ធភាពដែលគាត់ធ្វើបានសម្រាប់កូនៗ ដើម្បីឲ្យយើងរស់នៅបានក្នុងលក្ខណៈមួយសមរម្យរីករាយនិងរាបសារ ។

គាត់ធ្វើការច្រើនណាស់ក្នុងមួយសប្តាហ៍ក្នុងឋានៈជាសាកលវិទ្យាធិការ ជាប្រធាននាយកដ្ឋានឧត្តមសិក្សានិងជាសាស្ត្រាចារ្យច្បាប់។ ជាធម្មតា ឪពុកម្តាយខ្ញុំទទួលទានបាយ ប្រហែលជាម៉ោងប្រាំពីរកន្លះ ឬប្រាំបីយប់ ។ កូនៗ បរិភោគមុន ព្រោះប្រញាប់រៀន បន្ទាប់មកគាត់ពិនិត្យមើលកិច្ចការរៀនសូត្រយើងនៅក្នុងបន្ទប់រៀន ។ គាត់តែងតែស្តាប់ពាក្យពេចន៍របស់យើង រឿងរ៉ាវយើង អ្វីៗដែលបានកើតឡើងនៅសាលា នៅផ្ទះ និងបានបង្ហាញឲ្យយើងដឹងថា គាត់យកចិត្តទុកដាក់លើយើង ។

រៀងរាល់ថ្ងៃអាទិត្យ គឺជាថ្ងៃដែលគាត់ទុកសម្រាប់ពួកយើង នៅពេលដែលម្តាយខ្ញុំកំពុងតែរៀបចំធ្វើម្ហូបពិសេសប្រចាំថ្ងៃអាទិត្យ ឪពុកខ្ញុំនាំកូនៗដើរលេងជាមួយគាត់ ។ នាំកូនៗនិយាយពីនេះពីនោះអប់រំយើង គាត់អប់រំយើងឲ្យចេះគោរពអ្នកដទៃ អោយឲ្យតម្លៃនៃជីវិតសញ្ញាណនៃអំពើល្អ និងអំពើអាក្រក់ ។ គាត់បានផ្តល់ដំបូន្មានលើការរស់នៅប្រចាំថ្ងៃ ។ គាត់ចង់ឲ្យនាងខ្ញុំដែលជាកូនស្រីតែមួយរបស់គាត់បានរៀនសូត្រឲ្យវែងឆ្ងាយ និងបានជ្រៅជ្រះ គាត់តែងតែស្រលាញ់ និងយកចិត្តទុកដាក់ចំពោះខ្ញុំជានិច្ច ។

ឪពុកនាងខ្ញុំ មានឧត្តមគតិទូលំទូលាយ មានគំនិតបើកចំហទៅលើពិភពខាងក្រៅ ដោយនៅតែផ្សារភ្ជាប់ជានិច្ចនូវការការពារបេតិកភណ្ឌវប្បធម៌ជាតិខ្មែរ លើសពីការងារប្រចាំថ្ងៃរបស់គាត់រូបគាត់ក៏ជាគណៈកម្មាធិការដាក់ពិន្ទុ លើការប្រឡងប្រជែងដណ្តើមជ័យលាភីលើផ្នែកអក្សរសាស្ត្រខ្មែរ ។ នាងខ្ញុំនៅចាំបានថា នៅក្នុងទសវត្សរ៍ឆ្នាំ៦០ ប្រហែលលោកមួយត្រូវបានជាប់ជ័យលាភីលេខមួយ ក្រោម

ចំណងជើងថា “ជាតិស្ត្រី” ។ ខ្សែភាពយន្តដែលមានចំណងជើងដូចខាងលើនេះ បានប្រសូត្រឡើង និងបានដាក់បញ្ចាំងនៅរោងភាពយន្តសូរិយា ។ នាងខ្ញុំអង្គុយជិតគាត់ ខ្សែភាពយន្តនេះ បានធ្វើឱ្យនាងខ្ញុំនៅចងចាំពីព្រោះក្នុងសាច់រឿង អ្នកនិពន្ធបានលើកតម្កើងការតស៊ូ ការព្យាយាមកំណត់របស់ម្តាយម្នាក់ដែលមួយជីវិតរបស់គាត់ចងភ្ជាប់ទៅលើកូនឈ្មោះ សំនៀង ។ ទោះបីជាម្តាយបានរសាត់អណ្តែតផុតបាត់ពីកូនក៏ដោយ ។ ពេលត្រឡប់មកពី--ចេញពីរបបខ្មែរក្រហមវិញ ខ្ញុំខំដើររកប្រលោមលោកនេះ តែរកមិនឃើញសោះរហូតទល់សព្វថ្ងៃនេះ ។

ឪពុកនាងខ្ញុំតែងតែព្យាយាមយកចិត្តទុកដាក់លើគ្រួសារ ព្រមទាំងជួយដឹកនាំឱ្យយើងមានគំនិតទូលំទូលាយ បើកទៅរកពិភពលោក ជាពិសេសទៅលើវប្បធម៌បារាំង ។ យើងបានប្រើប្រាស់ពេលវេលារបស់យើងជាមួយក្រុមគ្រួសារយើង ហើយជួនកាលក៏បានទទួលមិត្តភក្តិរបស់ឪពុកម្តាយយើងផងដែរ។ ឪពុកនាងខ្ញុំជាញឹកញាប់ ត្រូវបានចេញទៅបំពេញបេសកកម្មនៅប្រទេសក្រៅដូចជា បារាំង ស្វីស ចិន អាមេរិកខាងត្បូង និងសហរដ្ឋអាមេរិក ។ រាល់លើកគាត់តែងតែផ្ញើជាវត្ថុអនុស្សាវរីយ៍ពីប្រទេសដែលគាត់បានទៅនោះមកចែកឱ្យយើង ។ គាត់តែងតែព្យាយាមធ្វើការងាររបស់គាត់ក្នុងនាមជាអ្នកជំនាញដូចជាសាស្ត្រាចារ្យច្បាប់ ជាសាកលវិទ្យាធិការ និងជាអ្នកច្បាប់ ។ គឺនៅក្នុងមុខងារនេះហើយដែលគាត់បានដឹកនាំគណៈកម្មាធិការតាក់តែងរដ្ឋធម្មនុញ្ញថ្មីក្នុងឆ្នាំ១៩៧៣ ។

ដូចគ្នានេះដែរ គាត់បានព្យាយាមការពារផលប្រយោជន៍ប្រទេស ក្នុងការការពារកោះពូលូវ៉ៃដែលក្នុងពេលនោះសាធារណរដ្ឋខ្មែរកំពុងមានទំនាស់ជាមួយរដ្ឋាភិបាលវៀតណាមខាងត្បូង ។ ថ្ងៃមួយ នាឆ្នាំ១៩៧៤ ក៏បានចេញដំណើរទៅមើលកោះនោះជាមួយកងនាវាចរជាតិ ។ ថ្ងៃនោះ យើងទាំងអស់គ្នាមានការជ្រួលច្របល់បារម្ភជាខ្លាំង ពីព្រោះប្រទេសក៏កំពុងស្ថិតក្នុងសង្គ្រាម និងជម្លោះចេះតែមានជាមួយនឹងរដ្ឋាភិបាល លន់ នល់ និងសាធារណរដ្ឋវៀតណាមខាងត្បូង ។ ខ្ញុំនៅរៀនមិនសុខទេ ការធ្វើដំណើរចុះឡើងរបស់គាត់ប្រកបដោយគ្រោះថ្នាក់ និងប្រថុយប្រថាននេះ អារម្មណ៍ខ្ញុំមិននឹងថ្កល់ឡើយ ។

[១១:១១:៣២]

ខ្ញុំចាំរហូតតែគាត់បានមកដល់ផ្ទះវិញទើបបានខ្ញុំធូរចិត្ត ។ ដើម្បីបញ្ចប់ភាគទីមួយនេះ នាងខ្ញុំអាចនិយាយជម្រាបអង្គសវនាការបានថា កុមារភាពនិងយុវភាពរបស់នាងខ្ញុំ ពោរពេញទៅដោយសុភមង្គលរីករាយជាមួយឪពុក ដែលផ្តល់ការកក់ក្តៅ ភាពត្រឹមត្រូវ និងការយកចិត្តទុកដាក់យ៉ាងពេញលេញ ។

កាលខ្ញុំមានវ័យ១៨ឆ្នាំ ខ្ញុំមានទិសដៅទៅរកការសិក្សាផ្នែកច្បាប់ ដូចឪពុកនាងខ្ញុំដែរ ដែលជានិច្ច

កាល នាងខ្ញុំតែងតែកោតសរសើរគាត់ ។ ឪពុកនាងខ្ញុំ គឺជាគំរូរបស់ខ្ញុំ គាត់គឺជាគំរូដែលពោរពេញទៅដោយភាពត្រឹមត្រូវ ឧត្តមគតិ ដែលរូបខ្ញុំជាកូនចង់ធ្វើតាម ។ ឪពុកនាងខ្ញុំមិនបដិសេធ ការជ្រើសរើសនេះទេ នាងខ្ញុំរង់ចាំការប្រឡងបាក់ឌុបឆ្នាំ៧៥រួច ទើបចាំការផ្តល់អាហារូបករណ៍ ដើម្បីបន្តការសិក្សារបស់ខ្ញុំ ។ ក៏ប៉ុន្តែ ប៉ុន្មានខែកន្លងមកនេះ ម្តាយខ្ញុំបានប្រាប់ខ្ញុំថា តាមការពិតគម្រោងការរបស់ខ្ញុំកាលពីឆ្នាំនោះបានធ្វើឲ្យឪពុកខ្ញុំខ្វល់ខ្វាយ គាត់បាននិយាយជាមួយម្តាយខ្ញុំថា ខ្លាចគេធ្វើបាបខ្ញុំ ប្រហែលជាពេលនោះគាត់មានការភ័យខ្លាចដល់ខ្ញុំពីព្រោះច្បាប់ ជួនកាលវាចិតនៅក្បែរគ្នា និងក្បែរគ្នាពេកនឹងនយោបាយ។

ខ្ញុំសូមរៀបរាប់បន្តទៅទៀត ការប៉ះទង្គិចជាលើកទីមួយ នៅថ្ងៃ១៦ សីហា ឆ្នាំ៦៨ ។ ប្រមាណជាម៉ោងដប់យប់ ក្រុមនគរបាលមួយក្រុមបានចូលមកផ្ទះខ្ញុំ ។ ខ្ញុំបានឮសម្រិបជើងពួកនគរបាលទាំងនោះហើយគេក៏បានចាបផ្តើមឆែកឆេរបន្ទប់ឪពុកម្តាយខ្ញុំ ខ្ញុំភ្ញាក់សើងមមើងបានមើលឃើញមនុស្សម្នាច្រើន ដែលក្នុងនោះមានជីដូនជីតាខ្ញុំនិងមាខ្ញុំម្នាក់ផងដែរ ។ ខ្ញុំភ័យស្រឡាំងកាំង ខ្ញុំស្ទុះទៅជិតឪពុកខ្ញុំ ជនចម្លែកទាំងអស់នោះ បានបន្តការឆែកឆេរតទៅទៀតយ៉ាងយូររហូតដល់ពេលមួយនោះ ពួកគេ និងឪពុកម្តាយខ្ញុំបានចុះទៅដល់សាឡុងខ្ញុំក៏នៅក្បែរឪពុកនោះដែរ តែម្តាយខ្ញុំបានប្រាប់ថា ឲ្យខ្ញុំឡើងទៅមើលប្អូនខ្ញុំវិញ ។ ខ្ញុំចង់នៅជិតឪពុកខ្ញុំ ប៉ុន្តែខ្ញុំត្រូវស្តាប់បង្គាប់ម្តាយខ្ញុំ ខ្ញុំក៏ឡើងទៅមើលប្អូនខ្ញុំដែលអាយុទើបតែបានប្រាំខែ ។ ព្រឹកឡើងខ្ញុំភ្ញាក់ដឹងខ្លួន ដោយសារមានបងស្រីដែលនៅជួយមើលខុសត្រូវផ្ទះខ្ញុំនោះ ចូលទៅលើកប្អូនខ្ញុំយកទៅងូតទឹក ខ្ញុំក៏ដឹងខ្លួនឡើង ។ ខ្ញុំមិនឃើញម្តាយខ្ញុំ ក៏ស្ទុះទៅរកគាត់នៅផ្ទះជីដូនជីតាខ្ញុំ ។

នាងខ្ញុំចង់ជម្រាបអង្គសវនាការថា ផ្ទះជីដូនជីតាខ្ញុំ និងផ្ទះឪពុកម្តាយខ្ញុំនៅជាប់គ្នា ។ ពេលឡើងទៅដល់ផ្ទះជីដូនខ្ញុំ ខ្ញុំឃើញម្តាយខ្ញុំកំពុងអង្គុយយំ ។ ចំណែកឯជីដូនជីតាខ្ញុំមានទឹកមុខស្រពាប់ស្រពោន។ ខ្ញុំយល់ថាឪពុកខ្ញុំត្រូវគេចាប់ខ្លួនហើយ ។ ខ្ញុំភ័យខ្លាចណាស់ ខ្ញុំស្រែកយំភ្លាម ព្រោះខ្ញុំខ្លាចគេចាប់គាត់យកទៅបាញ់ចោលនៅត្រពាំងក្រឡឹង ដូចខ្ញុំបានឃើញអ្នកទោសនានានៅសម័យដែលគេបាញ់ចោលតាមទូរទស្សន៍ និងតាមរោងភាពយន្ត ។ ជីតាខ្ញុំចាប់ដៃខ្ញុំចេញ ដើម្បីកុំឲ្យឃើញ និងបានស្តាប់ ឃើញដឹងឮព្រឹត្តការណ៍អស់ទាំងនេះ គាត់លួងខ្ញុំ ។ ពេលនោះខ្ញុំអាយុ១២ឆ្នាំ ។

អស់រយៈជាច្រើនសប្តាហ៍មក កូនៗក៏ត្រូវបានអនុញ្ញាតឲ្យទៅសួរសុខទុកឪពុក ។ នាងខ្ញុំនៅរង់ចាំព្រឹត្តិការណ៍ដ៏រំជួលចិត្តនេះ ពេលទ្វារបើកឡើង ខ្ញុំនិងប្អូនខ្ញុំរត់ស្រទៅរកគាត់ ។ ម្តាយខ្ញុំ ហុចប្អូនពៅខ្ញុំ

ដែលកាលនោះអាយុប្រាំបីខែទៅឲ្យឪពុកខ្ញុំបី ។ ខ្ញុំយំ កូនទាំងអស់គ្នាឱបគាត់ យំទាំងអស់គ្នា ។ ជាលើកទីមួយហើយ ដែលខ្ញុំឃើញឪពុកខ្ញុំស្រក់ទឹកភ្នែក ខ្ញុំក៏ឃើញអ្នកយាមនៅក្បែរនោះស្រក់ទឹកភ្នែកដែរ ។ ក្រលៀសភ្នែកឃើញមានកូនគ្រែមួយនៅកៀនជញ្ជាំង ក្បែរគ្រែមានតសរសេរធំមួយដែលនៅពីលើតុនោះខ្ញុំឃើញមានក្រដាសនិងអក្សរដែលគាត់សរសេរ ។ គ្មានអ្នកណាម្នាក់និយាយអ្វីរួចឡើយ ពេលវេលាក៏ដល់ទីបញ្ចប់ គ្រួសារខ្ញុំក៏ត្រូវកាត់ផ្តាច់ចេញពីគាត់ ។ ខ្ញុំក្រឡេកមើលម្តងទៀត ទ្វារបន្ទប់ឃុំគាត់ក៏បិទទៅវិញ ។

[១១:១៧:០៨]

ប្រហែលមួយខែក្រោយមក ពេលបរិភោគអាហារថ្ងៃត្រង់ ម្តាយខ្ញុំពុំមានវត្តមានទេ ពីព្រោះរៀងរាល់ថ្ងៃ គាត់យកម្ហូបទៅជូនឪពុកខ្ញុំនៅមន្ទីរឃុំឃាំងដែលមានទីតាំងនៅទួលគោក ។ ខ្ញុំអង្គុយញ៉ាំបាយជុំគ្នាជាមួយប្អូនៗខ្ញុំ ខ្ញុំក៏ឮសូរសំឡេងឪពុកខ្ញុំ ។ ខ្ញុំរត់ទៅមើលតាមបង្អួចបន្ទប់បាយ ខ្ញុំបានឃើញឪពុកខ្ញុំមកដល់ផ្ទះ គាត់ស្លៀកខោខៀវចាស់ និងពាក់អាវសដៃវែង ហើយនៅពីក្រោយគាត់មាននរគបាលបីនាក់ស្លៀកពាក់ស៊ីវិលដើរតាមពីក្រោយមក ។ កូនៗ ទាំងអស់រត់ចេញពីតុបាយប្រញាយទៅទទួលគាត់ ។ រីករាយដែលបានឃើញគាត់ត្រឡប់មកផ្ទះវិញ ។ ឪពុកនាងខ្ញុំស្ថិតនៅក្នុងការឃុំឃាំង នៅក្នុងផ្ទះចំនួនបីខែថែមទៀត ដែលមានអ្នកយាមល្បាតនៅជាប់ជាមួយ ហូបបាយជាមួយ និងស្នាក់នៅក្នុងផ្ទះជាមួយ ។

ព្រឹត្តិការណ៍នេះ នៅចង់ចាំជាប់ជានិច្ចក្នុងចិត្តខ្ញុំ ។ ហេតុដូចម្តេចបានជាមនុស្សត្រឹមត្រូវដូចគាត់ឧស្សាហ៍ព្យាយាមនិងហ្មត់ចត់ក្នុងការងារដូចគាត់ ។ គាត់ដែលជាឪពុកដ៏ល្អម្នាក់ បែរជាបានចោទប្រកាន់ថាជាខ្មែរក្រហម ។ គាត់គ្រាន់តែជាមនុស្សម្នាក់ ដែលព្យាយាមការពារយុត្តិធម៌ សេចក្តីទៀងត្រង់ សេរីភាព និងចង់ផ្តល់លទ្ធភាពឲ្យកូនចៅអ្នកក្រទាំងអស់មានសិទ្ធិបានចូលការសិក្សា ។

[១១:១៨:៥៣]

នាងខ្ញុំសូមបន្តមកដល់ព្រឹត្តិការណ៍ថ្ងៃទី១៦ មីនា ឆ្នាំ៧៤ ។ ការចេញដំណើររបស់ឪពុកនាងខ្ញុំឆ្ពោះទៅហ្សឺណែវ។

នៅរសៀលថ្ងៃទី១៦ មីនា ឆ្នាំ៧៥ នាងខ្ញុំនៅផ្ទះកំពុងតែរំឭកមេរៀនឡើងវិញ ពីព្រោះចាប់តាំងពីឆ្នាំ៧០មក ការរៀនសូត្រក៏ត្រូវបែងចែកជាពីរពេល ។ មានសិស្សរៀនតែមួយ គឺពេលព្រឹក និងសិស្សរៀនមួយពេលគឺពេលល្ងាច ។ ពីព្រោះមនុស្សចេះតែរត់ពីតំបន់រំដោះខ្មែរក្រហមចូលភ្នំពេញកាន់ច្រើនឡើងៗ ។ ខ្ញុំបានដឹងថា ឪពុកខ្ញុំត្រូវចេញដំណើរទៅស្វីស ដើម្បីចូលរួមក្នុងសន្និសីទផ្នែកច្បាប់សមុទ្រ

ដែលត្រូវលើកឡើងពីបញ្ហាកោះពូលូវៃ ។ ប្រហែលជាម៉ោងបី ម្តាយខ្ញុំស្រែកហៅខ្ញុំ ខ្ញុំក៏ចេញពីបន្ទប់ឃើញឪពុកខ្ញុំនៅឈរចំពោះមុខចំពោះមុខខ្ញុំ ។ គាត់មើលមុខខ្ញុំ ប្រុងប្រៀបនឹងចេញដំណើរ គាត់សម្លឹងមុខខ្ញុំដោយមិននិយាយអ្វីមួយម៉ាត់សោះ ។ ការចេញដំណើរនេះមានសភាពចម្លែកខុសពីពេលមុនៗ ។

ពេលដែលខ្ញុំនឹកឃើញសភាពនេះក្នុងពេលបច្ចុប្បន្ន ខ្ញុំជឿជាក់ថា ឪពុកនាងខ្ញុំដឹងថាព្រឹត្តិការណ៍អាក្រក់ៗនឹងត្រូវកើតមានឡើង ។ នាងខ្ញុំមានការរឿងឆ្លល់នូវសភាពដែលបានកើតឡើងយ៉ាងឆាប់រហ័ស។ ម្តាយខ្ញុំនិងប្អូនៗពីរនាក់បានជូនដំណើរទៅដល់ស្នាក់ការ *អ៊ែរកាំបូជស៍* ឯខ្ញុំនៅចាំផ្ទះជាមួយនឹងអ្នកដាំបាយខ្ញុំ ។ ថ្ងៃនោះខ្ញុំរៀនពុំចូលទេ នៅរសាប់រសល់ ។

ច្រើនឆ្នាំកន្លងមក ក្រោយពីដឹងថា គាត់ស្លាប់បាត់ទៅ ខ្ញុំបានសួរម្តាយខ្ញុំថា "ម៉ាក់និយាយឡើងវិញឲ្យខ្ញុំបានដឹងផង តើមានរឿងកើតឡើងយ៉ាងម៉េចពេលដែលប៉ាបានបែកចេញពីពួកយើងជាចុងក្រោយបង្អស់នោះ?" ម្តាយខ្ញុំក៏បាននិយាយប្រាប់ខ្ញុំថា "គាត់ស្លៀកពាក់រួចហើយ ព្រោះលេខាផ្ទាល់របស់គាត់នឹងជិតដល់ពេលហ្នឹងនាំគាត់ជូនគាត់ឡើងកប៉ាល់ហោះ ។ តែគាត់ដោះអាវធំចេញវិញ ហើយប្រះខ្លួនទៅលើគ្រែ ។ ម្តាយខ្ញុំឃើញដូច្នោះ ក៏ដោះស្បែកជើង និងជួយម៉ាស្សាគាត់។" គាត់មានសភាពប្រែប្រួលចិត្តគាត់មិនចង់ចេញទៅសោះ នៅអល់ឯក ។ ក៏ប៉ុន្តែ វាជាភារកិច្ចដែលត្រូវទៅធ្វើបេសកម្មនេះ ដោយខានមិនបាន ។

ថ្ងៃនេះ គឺជាថ្ងៃចុងក្រោយដែលខ្ញុំបានឃើញគាត់ ។ ទឹកមុខរបស់គាត់ស្ថិតនៅជាប់ជានិច្ចក្នុងអារម្មណ៍របស់ខ្ញុំ ។ ទុក្ខព្រួយកង្វល់របស់គាត់កប់យ៉ាងជ្រៅនៅក្នុងក្រសែភ្នែកគាត់ ដែលជាទុក្ខកង្វល់របស់មនុស្សម្នាក់ របស់ឪពុកម្នាក់ ដែលកំពុងតែស្ថិតក្នុងសភាពមួយដែលពុំអាចមានលទ្ធភាពធ្វើអ្វីបាននិយាយមួយម៉ាត់ក៏មិនបាន និយាយអ្វីក៏មិនចេញ ។

[១១:២២:១១]

យប់នោះប្រហែលជាម៉ោងប្រាំពីរ យើងទាំងអស់គ្នាអង្គុយចាំទទួលទូរស័ព្ទគាត់ ដែលគាត់បានសន្យាថា នឹងតេឡេហ្វូនពីបាងកកមក ។ ពីព្រោះយើងនាំគ្នាខ្វាយខ្វល់ដោយសារ *ពីស* នៅពោធិចិនតុងត្រូវគ្រាប់ផ្លោងពីពួកខ្មែរក្រហមជាញឹកញយ ។ ខ្ញុំគ្រាន់តែឮស្នូរតេឡេហ្វូន រោទ៍ឡើងខ្ញុំស្ទុះទៅជិតទូរស័ព្ទពេលដែលគាត់តេឡេហ្វូនមកម្តាយខ្ញុំ ។ ខ្ញុំធូរស្រាលក្នុងចិត្តដោយដឹងថា គាត់បានទៅដល់បាងកកហើយ។ នេះជាសំឡេងចុងក្រោយដែលខ្ញុំបានឮជាសំឡេងឪពុកខ្ញុំ ដែលខ្ញុំបានឮនៅក្នុងតេឡេហ្វូន ។

យប់ថ្ងៃទី១៦ មីនា នេះ វិទ្យុភ្នំពេញបានប្រកាសបិទគ្រឹះស្ថានសិក្សាទាំងអស់ ខ្ញុំក៏ត្រេកអរបាន

នៅផ្ទះ ពីព្រោះការចេញទៅរៀនវាជាគ្រោះថ្នាក់មួយណាស់ គ្រាប់ផ្លោងប្រសេចប្រសាចមិនដឹងជាធ្លាក់ត្រូវចំកន្លែងណាខ្លះទេ ។ វាស្ថិតនៅក្នុងការប្រហុយប្រថានក្នុងការរស់នៅជាអចិន្ត្រៃយ៍ ។ បួនប្រាំថ្ងៃមុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ ម្តាយនាងខ្ញុំបានទទួលសំបុត្រមួយពីក្រសួងការបរទេស ដែលក្នុងនោះគាត់បានសរសេរប្រាប់យើងថា នឹងឆាប់បានវិលត្រឡប់មកផ្ទះវិញ ។

នាងខ្ញុំសូមនិយាយទៅដល់ថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ដែលជាការជម្លៀសដោយបង្ខំប្រជាជនពីទីក្រុងភ្នំពេញ ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ នាងខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំងនៅពេលជម្លៀសប្រជាជនពីភ្នំពេញ។ ក្នុងការជម្លៀសនេះ សភាពការណ៍ផ្លាស់ប្តូរក្រឡាប់ចាក់ ច្របូកច្របល់ និងភ័យខ្លាច ហើយពុំមានវត្តមានឪពុកនាងខ្ញុំទេ ដើម្បីជួយគ្រួសារខ្ញុំ ។ ជាសំណាងល្អដែរ ជីតារបស់ខ្ញុំបានជួយពួកយើងទាំងអស់គ្នា ក៏ប៉ុន្តែទោះជាយ៉ាងណាក៏គាត់ពុំអាចជំនួសឪពុកខ្ញុំបានដែរ ។ យើងក៏បានទៅដល់ទៅតាមទិសដៅរបស់អង្គការ ពីព្រោះគ្នាច្រើនមិនអាចទៅដល់កំពង់ឆ្នាំងបានទេ ។ ជីតាខាងម្តាយរបស់នាងខ្ញុំមានដើមកំណើតនៅកំពង់ឆ្នាំង ។ គាត់ចង់កូនចៅគាត់ទៅកំពង់ឆ្នាំងដើម្បីទៅធ្វើស្រែដូចអង្គការ គេបានលើកទិសដៅថាឲ្យទៅធ្វើស្រែដូច្នោះ ។

ដោយសារយើងគ្មានមធ្យោបាយដើម្បីធ្វើដំណើរទៅដល់កំពង់ឆ្នាំងបាន យើងក៏បានចុះឈ្មោះឲ្យអង្គការដាក់ទិសយើងឲ្យទៅដល់ណាក៏ទៅចុះ ។ នាងខ្ញុំក៏បានទៅដល់តំបន់២១ បន្ទាប់មកតំបន់២០ និងជាទីចុងក្រោយ គឺតំបន់៥០៥ ។ ក៏ដូចជាយុវនារីឯទៀតដែរ នាងខ្ញុំត្រូវបានបញ្ជូនទៅក្រុមកងចល័តដែលធ្វើការពីកន្លែងមួយទៅកន្លែងមួយតាមការចាត់តាំងរបស់អង្គការ ។

[១១:២៥:៣៨]

ភាពអត់ឃ្លាន ភ័យខ្លាច និងការជៀសផុតពីការរំលោភ និងការចាប់បង្ខំឲ្យរៀបការ ត្រូវបានឆ្លងផុតនៅរបបខ្មែរក្រហមនោះ ។ នាងខ្ញុំបានរួចខ្លួនពីការចាប់រំលោភ និងការចាប់បង្ខំឲ្យរៀបការ ហើយខ្ញុំបានរស់រានមានជីវិតឡើងវិញ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំនឹកឪពុកខ្ញុំណាស់នៅក្នុងសម័យនោះ ។ ខ្ញុំចង់ឲ្យពួកគាត់ជួយចែករំលែកភាពលំបាកវេទនា តែខ្ញុំក៏ត្រេកអរផងដែរ ដែលនឹកស្មានថារូបគាត់រួចផុតពីភាពអមនុស្សធម៌នៃរបបខោអាវខ្មៅ ។ គឺគាត់រស់នៅស្រុកបារាំងបានស្រុកស្រួលហើយ ចំណែកខ្ញុំទោះបីជាលំបាកយ៉ាងណាក៏ខ្ញុំនៅមានឪពុកម្នាក់នៅប្រទេសក្រៅ គាត់នៅតែជាបង្អែកមួយយ៉ាងសំខាន់របស់ខ្ញុំដដែល ។

នៅខែកក្កដា ឆ្នាំ៧៧ នៅតំបន់៥០៥ មានទឹកជំនន់យ៉ាងខ្លាំង ។ ខ្ញុំចាំបានយ៉ាងច្បាស់ថា ក្នុងពេលនោះខ្ញុំមានអារម្មណ៍រសេបរសប់ឡេះឡះក្នុងចិត្តនឹកតែឪពុកខ្ញុំ ។ ខ្ញុំយល់សប្តិយ៉ាងចម្លែកដោយឃើញគាត់តែពីក្រោយខ្នង ខ្លួនហើមយ៉ាងឡើងខ្មៅ គាត់មិនបង្ហាញមុខឲ្យខ្ញុំឃើញទេ ហើយក៏មិនបានឮគាត់និយាយអ្វីសោះដូចជាមនុស្សស្លាប់ ។ ខ្ញុំមិនអស់ចិត្តនៅតែរសាប់រសល់ ខ្ញុំក៏បានសុំមេកងមកផ្ទះមួយភ្លែត។ ខ្ញុំក៏ជិះទូកមកដល់ផ្ទះពុំជួបម្តាយខ្ញុំទេ គាត់ចេញទៅធ្វើការបាត់ហើយ ជួបជីដូនខ្ញុំ ។ ខ្ញុំក៏បាននិយាយរឿងយល់សប្តិនោះប្រាប់ជីដូនខ្ញុំ ។ ខ្ញុំថាខ្ញុំខ្លាចតែប៉ាស្លាប់ មើលទៅយល់សប្តិអាក្រក់ណាស់ ។ ជីដូនខ្ញុំខឹងខ្ញុំណាស់ គាត់គម្រាមខ្ញុំ ហើយស្រែកឲ្យខ្ញុំភ្លាម ឯខ្ញុំឈប់និយាយ ។

ជាច្រើនឆ្នាំក្រោយមក ខ្ញុំបានយល់ដឹង តើក្នុងយល់យល់សប្តិនេះ វាបង្ហាញជាសញ្ញាណឲ្យខ្ញុំដឹងអ្វីខ្លះ?

ក្នុងរបបខ្មែរក្រហម ពេលដែលខ្ញុំឃើញមនុស្សចំណាស់ៗឪពុកខ្ញុំ ដែលត្រូវធ្វើការក្រោមកំដៅថ្ងៃ ឬភ្លៀង ទាំងខ្វះខាតម្ហូបចំណី ។ ខ្ញុំគិតថា ប៉ាមានសំណាងដែរ ដែលស្ថិតនៅអឺរ៉ុប ជៀសផុតពីរឿងអស់នេះ ហើយខ្ញុំត្រេកអរណាស់ ។ ថ្ងៃមួយប្រធានភូមិបានឲ្យខ្ញុំទៅធ្វើត្រីប្រហុកនៅក្រគរ កន្លែងដែលគេតម្រូវឲ្យខ្ញុំសរសេរប្រវត្តិរូប ។ នាងខ្ញុំក៏សរសេរប្រវត្តិរូបថ្លែងពីការពិតទាំងអស់ ពីខ្លួនខ្ញុំផ្ទាល់ពីឪពុកម្តាយខ្ញុំ ក្នុងគោលបំណងចង់ជួបបណ្តាលថ្នាក់ដឹកនាំស្រុក ឬខេត្តក្រចេះ ក្រែងលោមានអ្នកណាម្នាក់ស្គាល់ឪពុកខ្ញុំ និងចង់ឲ្យថ្នាក់ដឹកនាំខ្មែរក្រហមអាចធ្វើអ្វីឲ្យបាន ដើម្បីឲ្យគ្រួសារខ្ញុំបានជួបជុំគ្នា ។ ប៉ុន្តែខ្ញុំមិនដឹងថា ប្រវត្តិរូបនោះធ្លាក់នៅដល់ដៃអ្នកណាទេ គ្មានអ្នកណាហៅខ្ញុំសួរសោះឡើយ ។ ខ្ញុំក៏បានរួចផុតពីគ្រោះថ្នាក់ដែលនឹងអាចកើតមានឡើង ដោយសារការសរសេរប្រវត្តិរូបនេះ ។ ហើយរហូតដល់សព្វថ្ងៃ ខ្ញុំក៏នៅតែមិនដឹង តើអ្នកណាខ្លះ ដែលកាន់ប្រវត្តិរូបខ្ញុំនោះ? លាក់ប្រវត្តិរូប ឬក៏ហែកប្រវត្តិរូបខ្ញុំចោល សរសេរថ្មីជួសឲ្យខ្ញុំ? ខ្ញុំនៅតែមិនដឹង ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលខ្ញុំជួបភាពអាសន្ន ភាពអត់ឃ្លាន និងការភ័យខ្លាចពីព្រោះអ្នក១៧ មេសា ត្រូវគេចាត់ទុកថា ឈ្លើយសឹក ។ ខ្ញុំតែងតែនឹកទៅរកឪពុកខ្ញុំ ដូចជាខ្មែរទូទៅដែលគេរកគុណម៉ែ គុណឪឲ្យជួយ ដូចជាគេបោះបង់ខ្ញុំចោលទៅក្នុងការដកសំណាបនៅក្នុងជើងភ្នំ ហើយប្រជាជនចាស់គេនាំគ្នាជិះទូកមកអស់ ចោលខ្ញុំឲ្យនៅក្នុងព្រៃ ។

ខ្ញុំជាសំណាងល្អបានស្គាល់យាយៗដែលគេទៅចាំចម្ការនោះ បានសុំគាត់ជិះទូកត្រឡប់មកភូមិវិញ ។ នៅពេលចុងក្រោយ នៅពេលដែលខ្មែរក្រហមបាក់ទ័ព ពេលនោះ នាងខ្ញុំកំពុងតែរែកដីនៅលើ

ទំនប់ សេដា ស្រាប់តែឃើញហ្វូងមនុស្សបាក់ទ័ពរត់មកប្រសាច ដូចទឹកបាក់ទំនប់ ខ្ញុំទម្លាក់អម្រែកចេញ ហើយរត់ទៅតាមចរន្តមនុស្សព្រោះបើមិនរត់ គេជាន់ខ្ញុំស្លាប់ ខ្ញុំចេះតែរត់ទៅៗក្នុងការភ័យខ្លាច និងរន្ធត់ឥតឧបមា រហូតដល់កន្លែងមួយដែលឃើញមនុស្សកកកុញទៅមុខទៀតលែងរួច ។ ទាំងកណ្ដាលយប់ងងឹត ខ្ញុំដើរចុះ ដើរឡើង វេរាមិនដឹងធ្វើអី សម្ពាយខោអាវខ្ញុំក៏គ្មាន ខ្ញុំនៅតែមួយចង្កេះគត់ ហើយគ្មានស្គាល់អ្នកណាសោះ បាត់បងបាត់ប្អូនអស់ ម្ដាយក៏មិនឃើញ ឃើញតែមនុស្សរត់កកកុញ មកចាំគ្នានៅឃុំបុស្សលាវ ។ យប់កាន់តែជ្រៅទៅ ខ្ញុំចេះតែដើររកតាមក្រុមមនុស្សដែលគេនៅអង្គុយជាដុំៗ ខ្ញុំឮស្វូរសំឡេងម្ដាយខ្ញុំ ខ្ញុំងាកមើល ខ្ញុំងាកមើលតាមសំឡេង ហើយខ្ញុំរត់ទៅតាមសំឡេង ។ ខ្ញុំឃើញគាត់កាន់ចន្លុះ ហើយស្រែករកឈ្មោះប្អូនខ្ញុំពីរនាក់តូចៗ ដែលនៅកងកុមារ ។ ខ្ញុំក៏បានជួបគាត់ ។ គាត់ក៏បាននាំខ្ញុំទៅកន្លែងក្រុម មនុស្សមួយដុំដែលនៅក្នុងនោះ មានប្អូនខ្ញុំ ប៉ូលីយូ និងជីដូនខ្ញុំ ។

ហើយខ្ញុំក៏បានចេញដំណើរដោយឆ្លងកាណូតទៅត្រើយម្ខាងទៀតនៃទន្លេមេគង្គ និងបន្តការរត់ទៅតាមបញ្ជារបស់ខ្មែរក្រហម ដែលកៀរមនុស្សយកទៅឡើងភ្នំបឹងកេត ។ បន្ទាប់មកដោយសារនៅក្បែរយើង មានប្រធានភូមិដែលកូនគេជាគណៈ គេមានវិទ្យុមួយ គាត់ចេះតែបើកចុះឡើង ចុះឡើងដើម្បីរកសំឡេងកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ះទៅនឹងសំឡេងវិទ្យុសហរដ្ឋអាមេរិក ទើបពួកខ្ញុំបានដឹងថាភ្នំពេញបែកហើយ ។ ក៏នាំគ្នាចុះពីលើភ្នំបឹងកេតមកវិញ ពេលចុះមកដល់ ក៏បានជួបម្ដាយមីងខ្ញុំ ដែលអង្គការបានរៀបការឲ្យ ហើយក៏បាននាំគ្នាធ្វើដំណើរត្រឡប់មកក្រចេះវិញ ពីព្រោះដាច់ស្បៀងហើយ ដាច់ពោះហើយ មិនដឹងជារត់ទៅណាទៀត ត្រូវរត់មកដល់ភូមិដែលខ្ញុំរស់នៅចុងក្រោយនេះ ។ ក៏ប៉ុន្តែពេលដែលមកដល់ភូមិដែលរស់នៅនោះ គឺយើងក៏ពុំមានសិទ្ធិអ្វីទៅរកស្រូវអង្ករដែរ ។

នាងខ្ញុំចង់ជម្រាបអង្គសវនាការ និងលោកប្រធានថា នៅពេលណាដែលអង្គការជម្លៀសយើងនៅថ្ងៃទី១៧មេសា ឲ្យចេញទៅស្រុកកំណើត ពីព្រោះភ្នំពេញគេខ្លាចមានការទម្លាក់គ្រាប់បែក ។ ស្រុកកំណើតរបស់នាងខ្ញុំ គឺភ្នំពេញ ប៉ុន្តែយើងគ្មានសិទ្ធិនៅស្រុកកំណើតយើងនេះទេ ក៏ដាក់ខ្លួន ដាក់កាយឲ្យអង្គការបញ្ជូនទៅតាមទិសដៅចុះ ។

[១១:៣៣:៤៣]

នៅពេលដែលខ្មែរក្រហមបាក់ទ័ព យើងបានរត់ទៅរកភូមិដែលយើងធ្លាប់រស់នៅ និងបានជួយធ្វើការនៅទីនោះ គេពុំមានបានឲ្យអ្វីយើងទេ ពីព្រោះអ្វីៗដែលជាសម្ភារភាពនៅពេលនោះ បានក្លាយទៅជាកម្មសិទ្ធិឯកជនរបស់អ្នកស្រុកទាំងអស់ គ្មានអ្វីហូបទេ ។ យើងក៏គិតសញ្ជឹងចុះឡើង ក៏សម្រេចចិត្ត

ធ្វើដំណើរមកភ្នំពេញវិញ ។ ការធ្វើដំណើរដោយផ្លូវឆ្ងាយតាំងពីក្រចេះរហូតដល់ភ្នំពេញពុំអាចធ្វើដោយថ្មើរជើងបានទេ វាឆ្ងាយណាស់ ហើយក៏ពុំមានសេសសល់មាសពេជ្រអ្វី ដើម្បីដោះដូរ និងដើម្បីបានយានជំនិះជួយសម្រាលក្នុងការដឹកជញ្ជូននេះដែរ ។

ពួកខ្ញុំក៏សម្រេចចិត្តធ្វើក្បូនឬស្សី និងទម្លាក់ក្បូនចុះមកតាមដងទន្លេមេគង្គ ពីក្រចេះ មកភ្នំពេញនៅដំណាច់ខែ២ ឆ្នាំ៧៩ ។ បន្ទាប់មក យើងក៏ឈប់នៅព្រែកតាគង់ហើយក៏បានប្តូរក្បូនជាមួយនិងអង្ករ ២០គីឡូ ហើយក៏បានទៅស្នាក់នៅក្នុងកុដិលោកមួយនៅក្នុងវត្តព្រែកតាគង់នោះឯង ។ ដើម្បីដោះស្រាយជីវភាព ប្អូនប្រុសខ្ញុំធ្វើជាអ្នកចែវទូក ដើម្បីដូរអង្ករ គឺចែវទូកពីព្រែកតាគង់ មកគីឡូម៉ែត្រលេខ៦ ។

ថ្ងៃមួយ ម្តាយខ្ញុំបានទៅគីឡូម៉ែត្រលេខ៦ ដើម្បីចង់ដឹងដំណឹងពីឪពុកខ្ញុំ ពីបងប្អូនរបស់គាត់ ដែលបែកឆ្ងាយអស់រយៈពេលជិតបួនឆ្នាំហើយ ។ គាត់បានជួបប្អូនជីដូនមួយគាត់ ហើយបានប្រាប់គាត់ថា ឮគេថាប៉ាខ្ញុំមកស្រុកខ្មែរ ។ ហើយត្រូវគេសម្លាប់ ។ ក៏ប៉ុន្តែ គ្មានអ្នកណាជឿសោះ ពួកខ្ញុំនៅតែមានជំនឿថា ឪពុកខ្ញុំរស់នៅស្រុកបារាំង ហើយពួកខ្ញុំនឹងបានជួបគាត់ ។ ពួកខ្ញុំមិនដឹងថា វិសាលភាពនៃការកាប់សម្លាប់នៃរបបកម្ពុជាប្រជាធិបតេយ្យធំធេងដល់ម្លឹងនោះទេ ។ ហើយខ្ញុំតែងតែគិតថា ទោះជាយ៉ាងម៉េចក៏មិនអីដែរ ព្រោះប៉ាមិនដែលធ្វើបាបអ្នកណាផង មានអ្នកណាត្រូវស្អប់គាត់ ។

បន្ទាប់មកទៀត យើងទទួលដំណឹងថា មាខ្ញុំម្នាក់នៅរស់ ហើយគាត់ក៏បានមកជួបយើងនៅព្រែកតាគង់ ។ នៅពេលដែលមាខ្ញុំ បានឃើញពួកខ្ញុំ គាត់និយាយបានតែចេញតែពីរឃ្លាទេ គាត់ថា “បងតុនចាញ់បោកគេ គាត់ចោលកូនមួយហ្វូង” ។ ខ្ញុំភាំងស្មារតី ខ្ញុំឆ្ងល់ថាតើមាខ្ញុំចង់និយាយពីអ្វីឲ្យប្រាកដ ខ្ញុំក្តុកក្តួលក្នុងចិត្តណាស់ ខ្ញុំក្រឡេកឃើញធុងនិងអម្រែកទឹក ខ្ញុំក៏ធ្វើជាសន្ទុះទៅរែកទឹកដើម្បីចុះទៅរកកន្លែងយំ ដោយស្ងប់ស្ងាត់និងលួចលាក់ ។ ប៉ុន្តែ ពេលទៅដល់មាត់កំពង់ទឹក ខ្ញុំឃើញប្អូនប្រុសខ្ញុំអាយុប្រហែលជាជាង១០ឆ្នាំហើយពេលនោះ កំពុងតែឈរយំម្នាក់ឯង ខ្ញុំខំទប់ទឹកភ្នែក ងាកមុខចេញ មិនឲ្យប្អូនខ្ញុំឃើញទេ ខ្ញុំមិនឲ្យឃើញទឹកភ្នែកខ្ញុំទេ ។ ខ្ញុំក៏ឡើងមកវិញ មាខ្ញុំហាមាត់និយាយអ្វីទៀតមិនរួច ភ្នែកគាត់សម្លឹងមើលយើង ទើបគាត់យល់ ពីព្រោះសមាជិកគ្រួសារមួយចំនួនពុំស្ថិតនៅជាមួយពួកយើងទៀតទេ ។

ពេលដែលចេញថ្ងៃ១៧ មេសា ៧៥ ទាំងអស់គ្នា ហើយពេលដែលយើងជួបគាត់នៅថ្ងៃនោះត្រឡប់មកវិញ គឺបាត់សមាជិកគ្រួសារនោះជាងពាក់កណ្តាលទៅហើយ ។ យើងរស់នៅក្នុងស្ថានភាពមួយពោរពេញទៅដោយការឈឺចាប់និងអស់សង្ឃឹម ដែលពុំមានអ្នកណាម្នាក់ហ៊ានសួរនាំអ្វីថែមទៀត

ឡើយ ។ ខ្ញុំឮតែគេនិយាយពីស្លាប់ បាត់ខ្លួន អត់ឃ្លាន ព្រាត់ប្រាស់ ការស្លាប់ ស្លាប់ និងស្លាប់ ។

[១១:៣៨:២៤]

ដំណឹងអាក្រក់ ក៏ចេះតែលេចឮមកដល់យើង ពីការបាត់បង់សមាជិកគ្រួសារសាច់ញាតិ និងមិត្តភក្តិ ។ យើងរស់នៅបណ្តើរ រកការងារបណ្តើរ រកអ្វីហូបបណ្តើរ ជូតទឹកភ្នែកបណ្តើរ ប៉ុន្តែត្រេកអរព្រោះបានចេញផុតពីរបបអាវខ្មៅហើយ ។ ខ្ញុំនៅតែមម៉ៃនឹកដល់ឪពុកខ្ញុំ ម្តងនឹកថាគាត់ប្រហែលជានៅរស់ទេ ម្តងនឹកថា តិចលំស្លាប់ ដូចគេថាមែនទៅ ។ តែក្តីសង្ឃឹមថា ក្រែងនៅរស់ក៏ត្រូវរលត់ផុតបន្តិចម្តងៗពីក្នុងចិត្តខ្ញុំ ។ ខ្ញុំតក់ស្លុតណាស់ ព្រោះខ្ញុំឃើញម្តាយ និងបងប្អូនខ្ញុំបានរស់រានមានជីវិត តែអភ័ព្វអ្វីតែគាត់នៅក្រៅស្រុកសោះ បែរជាមកស្លាប់ទៅវិញ ។ យើងបានទទួលដំណឹងជាបន្តបន្ទាប់ ខ្លះគេថាបានឃើញគាត់នៅសាលាតិចណូ ខ្លះគេថា បានផ្លាប់រស់នៅជាមួយគាត់នៅបឹងត្របែក ខ្លះថានៅតាឡី ខ្លះឃើញថា ទេពេលបែកថ្ងៃ៧មករា ឃើញគាត់ ដូចជាឃើញគាត់ ស្ពាយបាឡូមួយ ហើយរត់ដូចជាសំដៅទៅខេត្តសៀមរាប ពួកខ្ញុំចេះតែរសាប់រសល់ ចុះយ៉ាងម៉េចអ៊ីចឹង គាត់មកមែន ឬអត់ គាត់នៅរស់ ឬអត់ ឬក៏ស្លាប់យ៉ាងម៉េច តែខ្ញុំមិនឮសួរគេថា និយាយពីស-២១ នៅឡើយទេ ។

ថ្ងៃមួយប្រហែលជាក្នុងខែតុលា ឬវិច្ឆិកា ឆ្នាំ៧៩ ក្រោយរដូវភ្លៀង ខ្ញុំក៏បានទៅផ្ទះបងស្រីជីដូនមួយម្តាយខ្ញុំ ដែលតាំងនៅផ្សារដីហ្គោល គាត់បានចេញពីស្រុកកំណើតគាត់ ខេត្តកំពង់ឆ្នាំង មករស់នៅភ្នំពេញវិញ ។ ខ្ញុំសូមជម្រាបអង្គសវនាការថា នាងខ្ញុំបានរកការងារធ្វើបាននៅកំពង់ផែភ្នំពេញ ហើយតាំងពីខែប្រាំមក ហើយពេលដែលខ្ញុំបានចេញដំណើរជាមួយម្តាយខ្ញុំទៅសួរសុខទុក្ខបងស្រីជីដូនមួយគាត់គឺប្រហែលជាខែ១០ ឬដើមខែ១១ទៅហើយ ។ ខ្ញុំនៅចាំច្បាស់ថា ពេលនោះផុតរដូវភ្លៀង ក៏ប៉ុន្តែយើងនៅចាយអង្ករ ពីព្រោះពុំទាន់បោះពុម្ពលុយបាននៅឡើយ ។ ពេលត្រឡប់ពីផ្ទះបងស្រីជីដូនមួយម្តាយខ្ញុំវិញ ខ្ញុំឃើញមានស្រីអ្នកស្រែម្នាក់ គាត់ទូលស្ករត្នោតលក់ ។ ខ្ញុំក៏ហៅឈប់ ហើយយកអង្ករទៅដូរស្ករត្នោតនោះ ។ មីងអ្នកលក់ស្ករត្នោតក៏យកស្ករត្នោតហ្នឹងខ្ចប់ជាមួយនឹងក្រដាសមួយសន្លឹក ។ ខ្ញុំក៏ដាក់ក្នុងថង់វិញហើយដើរតទៅទៀតទៅ តែមានចិត្តមួយបណ្តាលឲ្យខ្ញុំ នឹកចង់មើល តើមានក្រដាសហ្នឹងយ៉ាងម៉េចខ្ញុំចង់ឃើញ ព្រោះខានឃើញក្រដាសហ្នឹងវាយូរឆ្នាំហើយតាំងពី៧៥មកម្ល៉េះ ពុំមានក្រដាសទេ ឃើញរបៀបដូចជាទស្សនាវដ្តីអីមួយដូច្នេះ ដែលខ្ចប់ស្ករនោះ ។

[១១:៤២:០៤]

នៅតាមផ្លូវសាលដីហ្គោលនោះ ខ្ញុំក៏លាថង់ហើយក៏មើលក្រដាសនៅលើក្រដាសនោះ ខ្ញុំក៏ឃើញ

រូបឪពុកខ្ញុំមួយកំណាត់ខ្លួន ហើយនៅក្បែររូបគាត់នោះ ក៏មានរូបជនរងគ្រោះឯទៀតៗនោះដែរ ។ នៅក្រោមរូបថតរបស់គាត់ ខ្ញុំឃើញមានសរសេរឈ្មោះគាត់ តែខ្ញុំមិនជឿថា ជារូបគាត់ ខ្ញុំស្មានថា គេមានការច្រឡំ ខ្ញុំបដិសេធជាមួយម្ដាយខ្ញុំថាមិនមែនរូបប៉ាទេ ប៉ុន្តែម្ដាយខ្ញុំចាប់យកមកមើល គាត់ថារូបគាត់ហើយ ពិតជារូបគាត់ ។ យើងទាំងពីរនាក់ ម្ដាយខ្ញុំ និងខ្ញុំ មុខឡើងស្លាំង កាំង ហានិយាយអ្វីមិនរួច ធ្វើដំណើរតទៅមុខទៀត ដើម្បីត្រឡប់មកផ្ទះវិញ ។

យើងមិនដឹងសោះថា មានការសម្លាប់មនុស្សគ្រប់ទីកន្លែង ហើយពេលដែលឃើញក្រដាសនោះក៏ដឹងថាស-២១ ពិតជាមានមែន ។ នៅលើរូបថតគាត់ មានសភាពស្គមស្គាំងមើលសឹងតែមិនស្គាល់ភ្នែកអស់សង្ឃឹម និងមានខ្សែចងព្យួរកនៅលើគាត់ ពាក់ស្លាកលេខ១៧ ។ ខ្ញុំចេះតែសួរខ្លួនឯងថា យ៉ាងម៉េចបានជាធ្លាក់ដល់ថ្នាក់នេះ? គាត់ស្គាល់ថ្នាក់ដឹកនាំខ្មែរក្រហម ពួកគេទាំងនោះជាអតីតសិស្សគាត់ ជាសហការីរបស់គាត់ ដូចសុន សេន ឬ ខៀវ សំផន ។ ចំណែក អៀង សារី និងប្រពន្ធ ក៏យើងស្គាល់ដែរ ថែមទាំងផ្ទះនៅមិនឆ្ងាយពីគ្នាប៉ុន្មានផង ។ ចំពោះពួកខ្ញុំវាមិនអាចឲ្យខ្ញុំនឹកស្មានថា ជនបញ្ញវន្តទាំងនោះជាអ្នកទទួលខុសត្រូវនៅលើការស្លាប់របស់ឪពុកខ្ញុំសោះ ។ ខ្ញុំនៅតែមិនអស់ចិត្ត ។

នាងខ្ញុំសុំអង្គសវនាការនិយាយតទៅទៀតចំពោះការរស់ឡើងវិញបន្ទាប់ពីភាពខ្ទេចខ្ទាំ ។ បន្ទាប់មកយើងបានដឹងថា វិទ្យាល័យទួលស្វាយព្រៃបានក្លាយទៅជាគុក ដែលគេឲ្យឈ្មោះថាស-២១នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬបន្ទាប់មកទួលស្លែងសព្វថ្ងៃនេះ ។ ខ្ញុំនិងម្ដាយខ្ញុំបានទៅដល់ទីនោះ ដើម្បីស្វែងរកការពិត ដែលថាឪពុកខ្ញុំបានមកស្លាប់ ។ យើងទាំងពីរនាក់បានដើរទៅតាមផ្លូវចេញពីនាយកដ្ឋានកំពង់ផែ យើងដើរតាមផ្លូវនរោត្តម បន្ទាប់មកទៅតាមផ្លូវមេភ្លើង និងក៏បានឃើញអគារជ្រង ភ្ញាក់ព្រើតនិងឃើញភាពស្ងាត់ជ្រង គួរឲ្យខ្លាចដូចជាផ្ទះសម្រាប់ដាក់ខ្មោច ។ ហើយក៏ចូលទៅក្នុងបរិវេណអគារនោះ ។ ចូលទៅខ្ញុំឃើញមុនគេ គឺអគារឈើដែលពេលនោះ មានមនុស្សប្រហែលជា២០ នាក់ប្ដាយកំពុងតែលហ្វាក ។ ខ្ញុំតក់ស្លុតណាស់ដែលឃើញទិដ្ឋភាពអស់ទាំងនេះ ។ ខ្ញុំមិនទៅក្បែរមនុស្សដែលផ្ដុំៗគ្នាកំពុងតែឆ្លោកមើលនោះទេ ។ ខ្ញុំទៅដល់អគារ“C” ហើយក៏ឃើញក៏រត់ឡើងទៅលើឃើញមាន សែលុយតូចៗដាក់ក្បែរៗគ្នា ម្ដាយខ្ញុំនៅឈរផ្អែកគាត់ដើរទៅមុខ ទៀតលែងរួច ។ ខ្ញុំស្ទុតហ្នឹងឃើញទិដ្ឋភាពអស់ទាំងនេះ វាដូចដែលខ្ញុំស្មានថា ឪពុកខ្ញុំប្រហែលជាមកនៅកន្លែងនោះមែន ។ ខ្ញុំរត់មើលពី សែលុយមួយទៅសែលុយមួយទៀត ពីមួយទៀតទៅមួយទៀត ។ ខ្ញុំស្មានថា បន្ទប់តូចៗដែលឃុំឃាំងនោះមានដាក់តែឪពុកខ្ញុំម្នាក់គត់ ។ ខ្ញុំមិនដឹងថាមុនឪពុកខ្ញុំទៅដល់មានអ្នកទោសផ្សេងទៀត និងក្រៅពីឪពុកខ្ញុំក៏

មានដាក់អ្នកទោសផ្សេងទៀតដែរ ។

ខ្ញុំឈ្ងោកករកមើលទាំងច្របល់ ក្នុងចិត្តក្រែងលោមាននៅសេសសល់អ្វីដែលខ្ញុំអាចចំណាំបានថាឪពុកខ្ញុំទៅដល់ទីនោះមែន ។ តែខ្ញុំមិនឃើញមានអ្វីទាំងអស់ ។ ម្ដាយខ្ញុំស្រែកហៅខ្ញុំ ឃើញខ្ញុំរត់ចុះរត់ឡើង គាត់ថា មកៗមកវិញមក ខ្ញុំក៏ចេញមក អស់សង្ឃឹម ស្រាលខ្លួនដូចសំឡី ។

ខ្ញុំក្រឡេកឃើញមានឃ្នាងខ្នោះ ឃើញហិបសម្រាប់បន្ទោបង់ ឃើញអ្វីៗដែលពុំមានភាពជាមនុស្សធម៌ទេ។ ខ្ញុំឃើញខោអាវអ្នកទោស ឃើញដែករនង ឃើញឧបករណ៍សម្រាប់ធ្វើទារុណកម្ម ។ ច្រើនខែដែលខ្មែរក្រហមបាក់ទ័ពទៅ ក៏ប៉ុន្តែស-២១ នៅធុំក្លិនឈាម នៅឡើយ នៅធុំក្លិនមនុស្សស្លាប់ពុំទាន់ផុតបាត់អស់ទេ ។

ខ្ញុំនិងម្ដាយខ្ញុំបានត្រឡប់ទៅផ្ទះវិញ ហើយនៅតាមផ្លូវរហូតដល់ផ្ទះគ្មានអ្នកណាម្នាក់និយាយអ្វីចេញឡើយព្រោះម្នាក់ៗតក់ស្លុតនិងរន្ធត់ក្នុងចិត្តខ្លាំងណាស់ ។ យប់នោះម្ដាយខ្ញុំ និងខ្ញុំលួចយំរៀងៗខ្លួន។ យើងបែរខ្នងដាក់គ្នា មិនហ៊ានយំឲ្យឮទេ ដើម្បីកុំឲ្យគាត់កាន់តែឈឺចាប់ថែមទៀត ។ គាត់ក៏ដូច្នោះដែរ ។ យើងនៅក្រោមដំបូលមុងតែមួយ លើកន្ទេលតែមួយ ។ ពេញមួយយប់យើងយំនិងអស់សង្ឃឹមរលីង ។ ច្រើនឆ្នាំបានកន្លងទៅ ការឈឺចាប់នៅតែកប់ យ៉ាងជ្រៅក្នុងជម្រៅចិត្តខ្ញុំ ។ ពេលណាដែលខ្ញុំនិយាយពីរឿងនេះ បំពង់កខ្ញុំហាក់ដូចជាមានអ្វីមកខ្ទាស់និយាយមិនរួច ហើយខ្ញុំយំក៏មិនឆ្អែតដែរ ។ ទើបតែថ្មីៗនេះទេ ដែលខ្ញុំអាចនិយាយជាហូរហែបាន ។ អារម្មណ៍ភ័យខ្លាចនៅតែតាមលងខ្ញុំ ។ ភាពតក់ស្លុតនៅពេលដែលដឹងថា ខ្ញុំបាត់បង់ឪពុកខ្ញុំនៅស-២១ ខ្ញុំបានលែងឃើញគាត់ទៀតហើយ គាត់ស្លាប់ហើយ ។ គាត់ត្រូវបានស-២១ វាយកម្ទេច ធ្វើទារុណកម្ម ប្រមាថមើលងាយ ។ សូម្បីតែសាកសពគាត់ក៏មិនដឹងជានៅឯណា? ស្លាប់របៀបម៉េចក៏ខ្ញុំមិនដឹង តើវាធ្វើឲ្យខ្ញុំទទួលយកបានយ៉ាងម៉េច? ខ្ញុំដែលជាកូនគាត់ និងដែលនៅតែគោរពស្រលាញ់គាត់ ។

[១១:៤៩:១៩]

ច្រើនខែកន្លងមក លោក អ៊ឹង ប៉ិច អ្នករស់រានមានជីវិតនៅស-២១បានមកផ្ទះម្ដាយខ្ញុំ និងបានសុំរូបថតឪពុកខ្ញុំដែលមានពាក់អាវ តូស (អាវជាផ្លូវការសម្រាប់បណ្ឌិតផ្នែកច្បាប់) ដើម្បីយកទៅដាក់នៅមន្ទីរទួលស្លែង ។ ហើយនៅក្បែរនោះក៏មានរូបថតគាត់ជាអ្នកទោសពាក់ស្លាកលេខ១៧ ។ ច្រើនអាទិត្យកន្លងមកទៀតលោក ប៉ិច ក៏បានមកផ្ទះ ហើយប្រាប់ថា គេបានរកឯកសារឪពុកខ្ញុំឃើញហើយ គឺជាឯកសារសួរចម្លើយបឋមដែលមានបួនសន្លឹក គឺឯកសារដែលមានលេខ ERN00188839- 00188843

ជាភាសាខ្មែរ និងជាភាសាបារាំង 00188444-00188846 ជាភាសាបារាំង ។

ប្អូនប្រុសខ្ញុំម្នាក់បានទៅយកកូពី ឯកសាររអស់នេះ ។ ឯកសាររអស់នេះហើយដែលវាធ្វើឲ្យយើងដឹងថា ប៉ាបានចូលមកស-២១ មែន ។ ហើយខ្ញុំក៏បានមើលទៅក្នុងចម្លើយរបស់ជនជាប់ចោទ លេខ ERN00204303-00204310 ដែលជនជាប់ចោទបានប្រាប់ថា គឺជា ម៉ម ណៃ ដែលជាអ្នកសួរចម្លើយឪពុកខ្ញុំ ។ ហើយដែលខ្លួន ម៉ម ណៃ ផ្ទាល់បានទទួលស្គាល់នៅពេលធ្វើសក្ខីកម្មពីថ្ងៃមុននៅមុខអង្គជំនុំជម្រះ ។

បន្ទាប់ពីដឹងថាឪពុកស្លាប់ទៅ ពូខ្ញុំម្នាក់បានជួយចិញ្ចឹមប្អូនតូចៗពីរនាក់ និងពូម្នាក់ទៀតបានយកប្អូនខ្ញុំពីរនាក់ទៀតដើម្បីជួយសម្រាលបន្ទុកម្តាយខ្ញុំ ហើយនិងដើម្បីផ្តល់ការរៀនសូត្រដល់ពួកគេទាំងបួននាក់ ។ ចំណែកឯ ប្អូនខ្ញុំពីរនាក់រស់នៅបែកពីខ្ញុំ ។ ខ្ញុំនិងម្តាយខ្ញុំ រស់ជាមួយគ្នា ។ ឯម្តាយខ្ញុំអស់លទ្ធភាពចិញ្ចឹមកូនទៀតហើយ ។ ពេលនោះខ្ញុំនឹកឪពុកខ្ញុំណាស់ ។ យើងបាត់បង្គោលជាបង្អែករឹងមាំរបស់យើងហើយយើងហាក់ដូចជាក្មេងដែលវង្វេងវង្វាន់ គ្មានអ្នកណាជួយដោះស្រាយ ។ ម្តាយខ្ញុំគិតតែពីចង់សម្លាប់ខ្លួន។ គ្រួសារខ្ញុំបានធ្លាក់ទៅក្នុងសោកនាដកម្មមួយថ្មីទៀត ។ គឺថាត្រូវធ្វើយ៉ាងណាដើម្បីប្រឈមមុខនឹងការរស់នៅប្រចាំថ្ងៃ ។ ម្តាយខ្ញុំមានប្រតិកម្មយ៉ាងខ្លាំងបន្ទាប់ពីការបាត់បង់ឪពុកខ្ញុំ ។ គាត់មិនដឹងថាតើត្រូវធ្វើយ៉ាងម៉េច? កូនតូចៗបែកពីខ្លួន ហើយធ្លាក់ជាស្ត្រីមេម៉ាយ ពីព្រោះពីមុនកូនៗរស់នៅដោយពឹងផ្អែកលើឪពុកខ្ញុំទាំងស្រុង ។ ជាញឹកញាប់គាត់ចង់តែសម្លាប់ខ្លួន វិបត្តិផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរពេលមានវិបត្តិម្តងៗ ពុំមានអ្នកណាចេញមុខនិយាយ ឬពន្យល់គាត់ទេ ។ វាពិបាកណាស់ទាំងចំពោះគាត់ និងចំពោះខ្ញុំជាកូនៗ មិនដឹងដោះស្រាយយ៉ាងម៉េច? មិនដឹងអារកាត់យ៉ាងម៉េច មុឹងមុាំងៗងាកទៅម្តាយជាក៏មិនជាឲ្យពេញលក្ខណៈ ក៏មិនពេញលក្ខណៈ ។ ប្អូនប្រុសខ្ញុំធំៗពីរនាក់រស់នៅធ្វើការផ្សេងដើម្បីចិញ្ចឹមជីវិតខ្លួនឯង ។ ឯខ្ញុំនៅតែបន្តការរស់នៅជាមួយម្តាយខ្ញុំទៀត ។ ខ្ញុំក្តុកក្តួលក្នុងជីវិតដែលត្រូវប្រឈមមុខនឹងការរស់នៅក្នុងសង្គមមួយដែលម្នាក់ៗគិតពីរឿងប្រឹងធ្វើយ៉ាងម៉េចឲ្យតែបានរស់ ព្រោះម្នាក់ៗគេបានគេចផុតពីការស្លាប់ហើយ ។

[១១:៥៣:២៩]

គ្មានអ្នកណាម្នាក់ក្រៅពីមាខ្ញុំទាំងពីរនាក់នេះទេដែលបានជួយពួកខ្ញុំ ។ ពេលនោះ មានផ្នែកកិច្ចការសង្គម ឬពេទ្យចិត្តសាស្ត្រជួយឡើយ ព្រោះពុំទាន់មាន ។ តែជីដូនខ្ញុំនិងពូខ្ញុំ បានជួយគាំទ្រផ្លូវចិត្តដើម្បីឲ្យម្តាយខ្ញុំប្រឹងរស់ និងដើម្បីគាំទ្រដល់កូនៗឲ្យកូនៗបានរៀនសូត្រតទៅទៀត ។ នេះគឺជាសក្ខីកម្ម

មួយដើម្បីឆ្លើយតបទៅនឹងកាតព្វកិច្ច និងការលះបង់របស់ឪពុកខ្ញុំក្នុងការស្វែងរកជួបជុំប្រពន្ធកូនវិញ ។ យើងត្រូវតែឆ្លើយតបនៅក្នុងការប្រឹងរៀនសូត្រ ជូនទៅឪពុកខ្ញុំវិញ ។ ប្រហែលជាចុងឆ្នាំជិត៨០ ខ្ញុំបានទទួលអាហាររូបករណ៍ទៅរៀននៅសូវៀត ។ ឯប្អូនពីរនាក់ទៀតម្នាក់ទៅសូវៀតដែរ និងម្នាក់ទៀតទៅអាល្លឺម៉ង់ខាងកើត ។ ឯអ្នកនៅស្រុកខ្មែរ រៀនផងធ្វើការផង ។

រយៈពេលប្រាំឆ្នាំនៅសូវៀត ខ្ញុំនឹកឪពុកខ្ញុំជាញឹកញាប់ជារាល់ថ្ងៃ ។ ខ្ញុំចេះតែចង់ដឹងថាតើគាត់ស្លាប់របៀបណា? យប់មួយខ្ញុំបានយល់សប្តិឃើញគាត់ ។ ខ្ញុំឃើញគាត់តែមួយកំណាត់ខ្លួនវិលវល់នៅលើអាកាស នៅក្បែររានហាលដែលគាត់ធ្លាប់ឈរនិយាយ និងឈរសម្រាកនៅក្បែរអង្រឹងដែលគាត់ធ្លាប់តែសម្រាកជារៀងរាល់ថ្ងៃរសៀល ។ គាត់អណ្តែតវិលវល់ ហើយស្រែកហៅខ្ញុំ គាត់ថា អូលេ ប៉ាស្លាប់ហើយ ។ ខ្ញុំភ្ញាក់ទាំងកណ្តាលយប់ក្តុកក្តួលក្នុងចិត្ត ខ្ញុំស្ទុះខ្ញុំយកដៃស្ទាបជញ្ជាំង ខ្ញុំឃើញព្រហ្មខ្ញុំដឹងថា ខ្ញុំឈប់នៅស្រុកខ្មែរហើយ ខ្ញុំនៅសូវៀតទេ ខ្ញុំបានរួចខ្លួនហើយ ។ ប៉ុន្តែ ឪពុកខ្ញុំមានរឿងអ្វីកើតឡើងនៅពេលនោះ? ពេញមួយយប់ខ្ញុំគេងលែងលក់ ទៀតខ្ញុំនឹកគាត់ណាស់ ខ្ញុំចង់ដឹងណាស់ ខ្ញុំចង់មកវិញ ខ្ញុំចង់មកមើលស-២១វិញ តែខ្ញុំមកមិនបាន ។ ខ្ញុំនឹកស្រមៃរាល់ពេលរសៀល ពេលដែលអ្នកដាំបាយកាប់ដូងរួច ខ្ញុំលើកកែវដាក់ទឹកដូងទៅជូនគាត់រាល់ ពេលរសៀលនៅក្បែរអង្រឹងដែលគាត់សម្រាក ។

យល់សប្តិនោះ គឺដូចជាពិព័ណ៌ក្នុងចិត្តគឺនៅកន្លែង ដែលខ្ញុំធ្លាប់លើកទឹកដូង ឬទឹកតែដាក់ជូនគាត់រាល់ថ្ងៃ ។ ទោះបីជាទម្ងន់នៃការឈឺចាប់មានទំហំនិងជម្រៅប៉ុនណាក៏ដោយដែលធ្លាក់មកលើគ្រួសារខ្ញុំ តែពួកខ្ញុំនៅតែខិតខំប្រឹងប្រែងស្តារឡើងវិញបន្តិចម្តងៗ ឲ្យផែនគ្រឹះនៃជីវិតថ្មីរបស់ពួកយើងរឹងប៉ឹងក៏ប៉ុន្តែ ការបាត់បង់ឪពុកខ្ញុំ គឺជាការឈឺចាប់មួយដែលគ្មានអ្វីយកមកបំបាត់បានឡើយ ។ ផ្នែកមួយនៃបេះដូងរបស់ខ្ញុំដែលធ្លាប់ដាក់ក្តីស្រលាញ់ទៅគាត់ ផ្នែកនោះវាផ្ទុកទៅដោយការឈឺចាប់ក្តុកក្តួលខ្លោចផ្សា ហើយជាដំបៅដែលមើលមិនជា ។ វានៅតែចំហ ។

លោកប្រធានខ្ញុំនៅតែនឹងឪពុកខ្ញុំរហូតដល់សព្វថ្ងៃនេះ ។ ខ្ញុំកាន់តែចាស់ ខ្ញុំកាន់តែនឹកទៅរូបគាត់ ខ្ញុំនឹកគាត់ណាស់ ។ ពេលដែលខ្ញុំមានកូន កូនខ្ញុំហាមួយម៉ាត់ ប្រាប់ខ្ញុំថាធ្មេញគេជិតបាក់ហើយ ខ្ញុំនឹងភ្លាមទៅដល់អតីតកាលរបស់ខ្ញុំដែលពេលឪពុកខ្ញុំត្រឡប់មកពីធ្វើការវិញខ្ញុំហាមាត់ប្រាប់គាត់ថា ប៉ាធ្មេញខ្ញុំជិតបាក់ហើយ ។ គាត់ក៏ជូនខ្ញុំទៅពេទ្យ ឌី ផុន ទៅដកធ្មេញ ។ ក្រោយមកទៀត ច្រើនខែកន្លង មកខ្ញុំសើចញ៉ឹមញ៉ែមដាក់គាត់ ប៉ាធ្វើម៉េចទៅបើធ្មេញខ្ញុំនៅតែជាធ្មេញរណារដដែល ធ្វើម៉េចឲ្យបានធ្មេញរាបស្មើដូចប៉ា? គាត់សើចញ៉ឹមៗ ។ ពេលដែលកូនខ្ញុំបង្ហាញធ្មេញ ហាមាត់ឲ្យខ្ញុំ ខ្ញុំនឹកទៅដល់រូបខ្ញុំជាមួយ

ឪពុកខ្ញុំ ។

លោកប្រធានម៉ោងជិតដប់ពីរហើយ នាងខ្ញុំនៅជាងពាក់កណ្តាលទៀត តើនាងខ្ញុំថ្លែងការណ៍តទៅទៀត ឬក៏យ៉ាងដូចម្តេច?

**ប្រធានអង្គជំនុំ៖**

ឥឡូវ ដោយសារសេចក្តីថ្លែងការណ៍នៅវែងតទៅទៀត ហើយពេលវេលាក៏ត្រូវដល់សម្រាកពិសាអាហារថ្ងៃត្រង់ហើយ អ៊ីចឹងទេ គឺមិនអាចដំណើរការបានទេពីព្រោះនឹងតជាងដែលនោះ ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកនៅពេលនេះដើម្បីពិសារអាហារថ្ងៃត្រង់ ហើយទន្ទឹមនឹងនេះអង្គជំនុំជម្រះក៏សូមជម្រាបដល់ភាគី និងសាធារណជនបានជ្រាបផងដែរថា នៅរសៀលនេះយើងនឹងបន្តស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយតាមកាលវិភាគដែលបានសម្រេចកែប្រែពីម្សិលមិញ គឺយើងនៅបានត្រូវស្តាប់នូវសេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត គឺស៊ាង វ៉ាន់ឌី ។ ប៉ុន្តែ ដោយសារហេតុផលបច្ចេកទេសផ្នែកខាងសោតទស្សន៍ និងប្រព័ន្ធព័ត៌មានវិទ្យាដែលអង្គជំនុំជម្រះតម្រូវឱ្យអ្នកបច្ចេកទេសរៀបចំដើម្បីស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ឈ្មោះ អ៊ូ សាវរិត ដែលត្រូវធ្វើការចូលរួមពីចម្ងាយដែលនឹងប្រព្រឹត្តទៅនៅថ្ងៃស្អែកវេលាម៉ោងចាប់ពីម៉ោងមួយនិងសាមសិបនាទី ដោយមានព័ត៌មានថាហេតុផលបច្ចេកទេសនៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាមានបញ្ហាត្រូវចំណាយពេលវេលា ដើម្បីត្រួតពិនិត្យឡើងវិញ ។ អ៊ីចឹងទេ គឺរសៀលនេះអង្គជំនុំជម្រះសម្រេចថា នឹងបន្តស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភឹង ហ្គុតស៊ុនថារី ជាបន្តទៀត ហើយប្រសិនបើមានពេលវេលាសមល្មមអង្គជំនុំជម្រះនឹងស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ាង វ៉ាន់ឌី ។ តែប្រសិនបើពេលវេលានោះនៅខ្លីពេក គឺអង្គជំនុំជម្រះមិនធ្វើទេដោយសារអង្គជំនុំជម្រះស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅរសៀលនេះត្រឹមតែម៉ោងបីនិងសាមសិបនាទីប៉ុណ្ណោះ ។ ហេតុនេះសូមភាគី និងសាធារណជនជ្រាប ។

អនុរក្សមន្ទីរឃុំឃាំង ឱ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឱ្យនាំគាត់មកកាន់សាលសវនាការវិញនៅរសៀលនេះនៅមុនម៉ោងមួយនិងសាមសិបនាទី។ សម្រាក ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីនៅម៉ោង ១២:០២នាទីដល់ម៉ោង ១៣:៣៤ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសូមផ្តល់វេទិកាទៅលោកស្រី ភីង ហ្គុតស៊ុនថារី ដើម្បីថ្លែងការណ៍បន្ត ។ សូមអញ្ជើញបាទ ។

**លោកស្រី ភីង ហ្គុតស៊ុនថារី៖**

ចាំ, នាងខ្ញុំសូមអរគុណលោកប្រធាន។ នាងខ្ញុំសូមបន្តសេចក្តីថ្លែងការណ៍របស់នាងខ្ញុំតទៅទៀត។

ខ្ញុំឈានចូលមកដល់វគ្គទីប្រាំនៃសេចក្តីថ្លែងការណ៍របស់ខ្ញុំ គឺការស្រាវជ្រាវរបស់ខ្ញុំពីការវិលត្រលប់របស់ឪពុកខ្ញុំទៅដល់ការឃុំឃាំងនៅស-២១ ។ នៅពេលណាដែលគេមានធ្វើសន្និសីទស្តីពីខ្មែរក្រហមតាមរយៈអ្នកប្រវត្តវិទូ អ្នកកាសែត ឬអ្នកស្រាវជ្រាវ ខ្ញុំ និងប្តីខ្ញុំបានចូលរួមដើម្បីទទួលបាននូវព័ត៌មានផ្សេងៗ គឺអ្វីដែលបានកើតឡើងនៅប្រទេសខ្ញុំនេះ ។ ថ្ងៃមួយអ្នកនិពន្ធម្នាក់បានសុំសម្ភាសន៍នៅលើវិថីជីវិតរបស់ខ្ញុំសម្រាប់ឧទ្ទិសដល់ថ្ងៃ៨ មីនា ទិវាស្ត្រីអន្តរជាតិ ។ បទសម្ភាសន៍ដែលគេបានជ្រើសរើសស្រីចំនួនមួយរយនាក់គ្រប់ស្រទាប់ជាន់ថ្នាក់នៃរាជាណាចក្រកម្ពុជា ។ ក្នុងបទសម្ភាសន៍នេះ បានធ្វើឲ្យខ្ញុំរំជួលចិត្តយ៉ាងខ្លាំង ។ អ្វីៗដែលបានកប់ទុកការឈឺចាប់ ភាពក្តុកក្តួលបានធ្វើឲ្យខ្ញុំរឹតតែមានសន្ទុះកាន់តែចង់ដឹង ចង់ឮរឿងរ៉ាវដែលបានកើតឡើងទៅលើឪពុកខ្ញុំ ។

ក្រោយមកយើងបានដឹងពីការបង្កើតសាលាក្តី ដើម្បីកាត់ទោសអ្នកទទួលខុសត្រូវខ្មែរក្រហម ។ ប្តីខ្ញុំ និងខ្ញុំក៏ចាប់ផ្តើមធ្វើការស្រាវជ្រាវ យើងបានទៅជួបអ្នកកាសែត ប្រវត្តិវិទូ អ្នកស្រាវជ្រាវដែលធ្វើការសិក្សាលើបញ្ហាខ្មែរក្រហមនេះ ។

បន្តិចម្តងៗយើងប្រមូលបានព័ត៌មានទាំងនោះ ទាំងនៅស្រុកខ្មែរនិងស្រុកបារាំង គឺផ្នែកទាំងអស់នេះហើយ ដែលធ្វើឲ្យយើងរួមផ្សំផ្គុំគ្នាឡើងជាខ្សែជីវិតរបស់ឪពុកនាងខ្ញុំនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ ។

*អេលីម៉ង់* ដែលបានពីការស្រាវជ្រាវនេះ បានដាក់បញ្ចូលទៅក្នុងសំណុំរឿងដូចជា ឪពុកខ្ញុំបានមកដល់ប្រទេសខ្មែរនៅថ្ងៃទី២៥ ធ្នូ ឆ្នាំ១៩៧៥ ។ ចេញពីប៉ារីសនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ៧៥ ដោយឆ្លងកាត់ប៉េកាំងជាមួយក្តីសង្ឃឹមយ៉ាងមុតមាំថា នឹងបានជួបជុំប្រពន្ធកូនវិញ ទោះបីជាមានឧបសគ្គយ៉ាងណាក៏ដោយ ។ គឺជាជើងហោះហើរទីមួយដែលបានដឹកពួកបញ្ញវន្តមកពីបារាំង ដូចជាលោក ថៅ សេង ឯកអគ្គរាជទូតនានា លោក ឈួក មឹងម៉ៅ និងបណ្ណានិស្សិតឯទៀត ។

[១៣:៣៧:១៧]

ផ្ទុយពីបញ្ញវន្តដែលរស់ប្រទេសបារាំង ដែលបានបណ្តោយខ្លួនឲ្យលង់លោះ ទៅលើការឃោសនា និងនៅលើសុន្ទរកថារបស់ថ្នាក់ដឹកនាំនៃរបបខ្មែរក្រហមនៅកម្ពុជា ។ ឪពុកនាងខ្ញុំ ពុំដែលមានជំនឿទៅលើអ្នកដឹកនាំខ្មែរក្រហមទាល់តែសោះ ភស្តុតាងមាននៅលើលិខិតដែលគាត់ផ្ញើជូនទៅ *មីស្មី* ហ្គូ ដែលថា “ខ្ញុំមានគ្រួសារដែលមានសមាជិកច្រើន ដែលខ្ញុំមិនអាចទុកឲ្យពួកគេរស់ទៅតាមយថាកម្មគេនោះឡើយ សូម្បីតែពេលណាបន្តិចណាក៏ដោយ វាជាបទឧក្រិដ្ឋមួយចំពោះខ្ញុំ ។ ដំណឹងពីរឿងជម្លៀសប្រជាជនទាំងបង្ខំ ក្រោមបញ្ជារបស់ខ្មែរក្រហមទាំងកណ្តាលយប់ បានធ្វើឲ្យខ្ញុំរំជើបរំជួលក្តុកក្តួលក្នុងចិត្តខ្ញុំណាស់ ។ លោកអាចនឹងស្រមៃទៅលើសភាពនៃការជម្លៀសមនុស្សនេះ ជាមួយនឹងភាពតានតឹងកំពុងតែកើតមានឡើងក្នុងចិត្តខ្ញុំ” ។

ឪពុកនាងខ្ញុំបានបន្តទៀតថា “ចំពោះខ្លួនខ្ញុំ ខ្ញុំនៅតែប្រកាន់ជំហរថានឹងត្រឡប់ទៅនៅជាមួយគ្រួសារនិងចែករម្លែកភ័ព្វវាសនាជាមួយពួកគេ ទោះបីជាថ្នាក់ដឹកនាំកំពុងកាន់អំណាចថ្មីចាប់ខ្លួនខ្ញុំឃុំឃាំង ឬក៏សម្លាប់ខ្ញុំក៏ដោយ ខ្ញុំក៏មិនគិត គិតតែធ្វើម៉េចឲ្យតែខ្ញុំបានវិលទៅជួបប្រពន្ធខ្ញុំនិងកូនខ្ញុំវិញ” ។

ពេលដែលមកកាន់កម្ពុជាភ្លាមរូបគាត់ ក៏ដូចជាអ្នកត្រឡប់មកឯទៀតដែរ ត្រូវបានគេដឹកជញ្ជូនទៅក-១៥ បន្ទាប់មកក៏ត្រូវបញ្ជូនទៅក-៦ តាខ្មៅ និងបឹងត្របែកដូចជា អ៊ុង ថុងហឿង បានបញ្ជាក់ក្នុងសៀវភៅរឿងរបស់គាត់ដែលមានចំណងជើងថា *“ហែលត្រុយអូខ្មែររួស”* ព្រមទាំងជាមួយអ្នកផ្សេងៗទៀត ដែលបានជួបគាត់ ។ នៅថ្ងៃទី១២ ធ្នូ ឆ្នាំ៧៦ ក្រោមការសម្រេចចិត្តរបស់អង្គការ រូបគាត់ត្រូវពួកសមាជិកនៃមន្ទីរសន្តិសុខបញ្ជូនមកដល់ស-២១ គឺជាគុកដែលពុំមានអ្នកទោសណាម្នាក់បានចេញមកវិញដោយមានជីវិតរស់នោះទេ ។ អ្នកលត់ដំនៅបឹងត្របែកខ្លះ ត្រូវបានបញ្ជូនទៅដីក្រហមដែលនៅទីនោះមានអ្នកនៅសេសសល់ជីវិត ក៏ប៉ុន្តែការសម្រេចចិត្តបញ្ជូនឪពុកនាងខ្ញុំមកស-២១ គឺជាការសម្រេចចិត្តបញ្ជូនមកឲ្យស្លាប់ ។

ក៏ប៉ុន្តែ អ្នកណាអ្នកចេញបញ្ជាទៅលើការឃុំឃាំងខ្លួននៅស-២១ បន្ទាប់ពីមានការឆ្លងកាត់លើវគ្គរៀនសូត្រនយោបាយនៅសាលាផ្សារដើមថ្កូវ? ការស្រាវជ្រាវរបស់យើងបានអនុញ្ញាតឲ្យយើងឃើញពន្លឺទៅលើសំណួរខ្លះៗ ។ ហេតុអ្វីបានជាគាត់ត្រឡប់ពីបារាំង ដែលទីនោះគេបានស្នើឲ្យគាត់នៅធ្វើការនៅសាកលវិទ្យាល័យប្រទេសស្វីស ឬនៅបារាំង?

ចម្លើយលើសំណួរនេះ មាននៅលើសំបុត្រឯទៀតដែលបានផ្ញើរទៅមិត្តគាត់លោក ហ្គូ ដែលជាបណ្ឌិតច្បាប់ និងជាសាកលវិទ្យាធិការនៃសកលវិទ្យាសាស្ត្រសង្គមនៅទូលូ ។ ឪពុកខ្ញុំបានសរសេរថា

"ខ្ញុំបានជួបមិត្តភក្តិខ្មែរជាច្រើននាក់ ហើយស្ទើរតែគ្រប់គ្នាបានឲ្យយោបល់ខ្ញុំឲ្យចូលជាមួយហ្វុង ។ ខ្ញុំបានដើរតាមគំនិតនេះ នឹងបានធ្វើលិខិតសុំចូលទៅលើការប្រមូលផ្តុំនេះ ខ្ញុំគ្មានជម្រើសទេ ដូចលោកជ្រាបស្រាប់ហើយ" ។

[១៣:៤១:០៩]

ក្នុងលិខិតចុងក្រោយរបស់គាត់ សរសេរនៅថ្ងៃ២៣ ធ្នូ ៧៥ បានបញ្ជាក់ថា "ខ្ញុំមិនដឹងថា អ្វីដែលនៅរង់ចាំខ្ញុំឯស្រុកខ្ញុំនោះទេ ក៏ប៉ុន្តែខ្ញុំមានកាព្វកិច្ចមួយនឹងត្រូវត្រឡប់ទៅវិញ ទោះបីជាបានត្រឹមតែថាអាចនឹងជួបជុំគ្រួសារខ្ញុំ ដែលខ្ញុំបាត់ដំណឹងប្រាំបួនខែហើយ" ។ ទាំងអស់នេះ បង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ការវិលត្រឡប់ទៅជួបជុំគ្រួសារវិញ វាមានសារសំខាន់ជាងគ្រោះថ្នាក់ដែលធ្វើឲ្យរូបគាត់ជាប់ឃុំឃាំង ។

តើគាត់ពិតជាបានមកជាប់នៅស-២១ មែនឬ? នៅពេលណាទៅ?

ឯកសារជាច្រើនដែលមាននៅស-២១ ឯកសារដែលនាងខ្ញុំដាក់មកសាលាក្តី បង្ហាញឲ្យដឹងថា ឪពុកនាងខ្ញុំត្រូវបានចុះបញ្ជីនៅថ្ងៃទី១២ ធ្នូ ឆ្នាំ១៩៧៥ ។ ឯកសារដែលមានលេខ ERN 00188857 និង 00188860 ជាភាសាបារាំង លើទំព័រ ដែល ស្ទួស ធី បានទទួលស្គាល់ថា បានសរសេរនោះមានការភាន់ច្រឡំទៅលើឆ្នាំ--

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

នៅក្នុងការបកប្រែជាភាសាអង់គ្លេស ខ្ញុំបានឮថា ចុះថ្ងៃ១២ ធ្នូ ឆ្នាំ១៩៧៥ ចំណុចនេះមិនត្រឹមត្រូវទេ ហើយលោកស្រី ស៊ុនថារី មិនមែននិយាយដូច្នោះទេ គឺវាជាថ្ងៃ១២ ខែធ្នូ ឆ្នាំ៧៦ មិនមែន ៧៥ នោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោកស្រីអញ្ជើញបន្ត ថ្លែងការណ៍បន្ត ។

**លោកស្រី ភឹង ហ្គុតស៊ុនថារី៖**

សូមបញ្ជាក់តទៅទៀតថា សួស ធី បានទទួលស្គាល់ថា ការសរសេរនោះមានការខុសឆ្គងទៅលើឆ្នាំ ពីព្រោះគាត់បានសរសេរថា ថ្ងៃ១២ ធ្នូ ឆ្នាំ៧៥ តាមពិតនៅថ្ងៃទី១២ ធ្នូ ឆ្នាំ៧៦ គឺជាភាន់ច្រឡំ ពីព្រោះឪពុកនាងខ្ញុំបានមកដល់ភ្នំពេញនៅថ្ងៃទី២៥ ខែធ្នូ ៧៥ ។ ចំណែកឯ ថ្ងៃទី១២ ខែ១២ ឆ្នាំ៧៥ គឺគាត់នៅប៉ារីសនៅឡើយ ។

[១៣:៤៤:០២]

តើគាត់ត្រូវបានឃុំឃាំងនៅស-២១ អស់រយៈពេលប៉ុន្មាន?

ចម្លើយសារភាពរបស់ឪពុកនាងខ្ញុំពុំត្រូវគេបានរកឃើញទេ តែវាមិនមានមន្ទិលសង្ស័យណាមួយដែលថា គាត់មិនបានសរសេរនោះឡើយ ។ ឪពុកនាងខ្ញុំបានជាប់ឃុំឃាំងជិតប្រាំពីរខែនៅស-២១ ដូច្នេះពុំមានអ្នកណាមួយដែលជាប់ឃុំឃាំងយូរប្រភេទនេះ ដោយមិនបានសរសេរចម្លើយសារភាពនោះទេ ។ តាមរយៈសក្ខីកម្មរបស់ផ្នែកសួរចម្លើយបានថា ជាទូទៅអ្នកទោសអាចរស់នៅបានប្រហែលជាពីរខែនឹងត្រូវបានគេសម្លាប់ បន្ទាប់ពីបានសរសេរចម្លើយសារភាពរួច ។ នៅឆ្នាំ១៩៨១ ប្អូននាងខ្ញុំបានទៅទទួលប្រវត្តិរូបសរសេរផ្ទាល់ដៃរបស់គាត់ ដែលគេរកឃើញនៅក្រសួងការបរទេសរបស់ អៀង សារី ដែលចាប់ពីក្រោយមកក្រសួងនេះ បានក្លាយជាទីស្តីការគណៈរដ្ឋមន្ត្រី ។

ក្នុងប្រវត្តិរូបនោះឪពុកនាងខ្ញុំសរសេរថា ខ្ញុំមានសំណូមពរជួបជុំប្រពន្ធកូនខ្ញុំ ដែលខ្ញុំបានបែកដប់ខែមកហើយ ។ ដូច្នេះ ការអះអាងនេះ ត្រូវបានសរសេរនៅពេលដែលគាត់មកដល់ប្រទេសខ្មែរ ពីព្រោះក៏បានចាកចេញទៅហ្សឺណែវ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ៧៥ ។ ប៉ុន្តែ នាងខ្ញុំសូមបញ្ជាក់ថា ប្រវត្តិរូបនេះមិនមែនបានមកពីស-២១ទេ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឲ្យយើងនូវឯកសារដែលមានបួនសន្លឹក គឺជាការសួរចម្លើយដែលសរសេរដោយ ម៉ម ណៃ ។ ជាឯកសារដែលយើងទទួលបានពីលោក អ៊ឹង ប៊ុចក្នុងចុងឆ្នាំ៧៩ ។ ឯកសារនេះ មានជាទម្រង់ជាប្រវត្តិរូបសួរចម្លើយបឋម ដែល ម៉ម ណៃ ត្រូវចោទសួរ ប៉ុន្តែ គាត់ពុំបានបញ្ជាក់ពីការស្លាប់របស់ឪពុកនាងខ្ញុំ ដោយសារតែមានការភ័យខ្លាចពីការឃុំចាប់ខ្លួនដូចមេធាវីការពារក្តីបានគំរាមនិងបន្លាចគាត់នៅថ្ងៃនោះ ។

ការគំរាមនេះ វាជាការប្រឆាំងមួយទៅលើឆន្ទៈរបស់ប្រជាជនខ្មែរដែលត្រូវតែឲ្យដឹងពីការពិត អ្វីដែលកើតឡើងដើម្បីសរសេរទុកក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសខ្ញុំ ទោះបីវាស្ថិតនៅក្នុងកាលៈទេសៈមួយជាសម័យមួយដែលធ្វើឲ្យប្រជាជាតិខ្មែរធ្លាក់ចុះយ៉ាងជ្រៅនៅក្នុងមហាសោកនាដកម្មក៏ដោយ។ ឯកសារ

ចុងក្រោយរបស់ស-២១ បានបញ្ជាក់ឲ្យដឹងថា ឪពុកខ្ញុំនៅរស់រានមានជីវិតនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ៧៧ វាគឺជាការពិនិត្យជំងឺដែលមានចំណងជើងថា របាយការណ៍ស្តី ពីសភាពជំងឺរបស់ខ្មាំង ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ៧៧ ។ ក្នុងឯកសារនេះ បានសរសេរនិងកត់ត្រាលើសភាពជំងឺរបស់ឪពុកខ្ញុំ ស្គីក រាកមួល ថប់ដង្ហើម ស្គម ។ ក្នុងលក្ខខណ្ឌនៃការឃុំឃាំងអ្នកទោសនៅស-២១ នៅពេលដែលជនរងគ្រោះមានការរាកមួល និងថប់ដង្ហើម ព្រមទាំងស្គីកលែងដឹងឈឺចាប់ទៅហើយ វាច្បាស់ណាស់ដែលថា អ្នកទោសដែលមានឋានៈដូចជាឪពុកនាងខ្ញុំនោះ របាយការណ៍ជំងឺត្រូវតែធ្វើ និងរាយការណ៍ជាបន្ទាន់ទៅឲ្យជនជាប់ចោទ ។ ជនជាប់ចោទខ្លួនឯងផ្ទាល់ ដែលជាអ្នកគ្រប់គ្រងនិងដឹងអ្វីៗទាំងអស់ដែលបានកើតឡើងនៅស-២១ ។ ជនជាប់ចោទ ជាមនុស្សហ្មត់ចត់ម៉ឺងម៉ាត់របៀបនេះតើត្រូវសម្រេចធ្វើអ្វីខ្លះ? តើគាត់ត្រូវរាយការណ៍ទៅអ្នកណាខ្លះ? ក្នុងឯកសារបញ្ជីអ្នកទោសនៅខែកញ្ញា ឆ្នាំ៧៧ ពុំឃើញមានឈ្មោះឪពុកខ្ញុំ ភឹង តុន ទៀតឡើយ ។

ជនជាប់ចោទតែងមានទម្លាប់វិភាគទៅតាមរបៀបជាអ្នកគណិតសាស្ត្រ គាត់យល់ឃើញដូចជាយើងផងដែរថា ឪពុកនាងខ្ញុំ ដែលបានជាប់ឃុំឃាំងនៅស-២១ នៅថ្ងៃទី១២ ខែធ្នូ ៧៦ បានដឹងថា នៅមានជីវិតរស់នៅជាចុងក្រោយនៅថ្ងៃទី០៦ ខែកក្កដា ៧៧ ពុំបានរស់ជាប់ឃុំឃាំងត្រឹមតែពីរខែ ដូចជាអ្នកទោសឯទៀតទេ ឬក៏ពុំបានជាប់ឃុំឃាំង ដូចជាជនជាប់ចោទបានប្រកាសថា ម្តែខែ ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវរបស់គាត់ឡើយ ។

[១៣:៤៨:៣៣]

នាងខ្ញុំសូមចូលទៅដល់វគ្គទី៦ ដើមបណ្តឹងរដ្ឋប្បវេណី ហេតុអ្វី និងអ្វីដែលខ្ញុំរង់ចាំ ។ តាំងពីអង្គសវនាការដេញដោលចាប់ផ្តើម នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ខ្ញុំមានវត្តមានជារៀងរាល់ថ្ងៃនៅបន្ទប់សវនាការ ។ នាងខ្ញុំបានឃើញ បានឮសាក្សីអតីតជនល្មើស ឬជនរងគ្រោះ អ្នកស្រាវជ្រាវ អ្នកឯកទេស ខ្ញុំបានឮចម្លើយរបស់ជនជាប់ចោទ ភាពបញ្ញាស់ផ្ទុយគ្នាចុះឡើង ការភូតកុហក ខ្ញុំបានឃើញការរំជួលចិត្តដែលអាចជាការពិត ឬក្លែងបន្លំរបស់ជនជាប់ចោទ ។ តែរហូតដល់ថ្ងៃនេះ ខ្ញុំគ្មានបានទទួលចម្លើយណាមួយឲ្យបានច្បាស់លើការស្លាប់របស់ឪពុកខ្ញុំទេ ។ លោក ម៉ម ណៃ បានទទួលស្គាល់ជាមួយការរំជួលចិត្តដែលថា ពិតជាគាត់បានសរសេរចម្លើយរបស់អ្នកទោស ភឹង តុន ។

លោក សួស ធី បានបញ្ជាក់ថា បានចុះបញ្ជីឈ្មោះ ភឹង តុន នៅលើលេខរៀង៥៦ ។ គ្មានសមាជិកស-២១ ណាមួយដូចជា ម៉ម ណៃ, សួស ធី, ប្រាក់ ខន, ហ៊ីម ហ៊ុយ ឲ្យបានដឹងសូម្បីតែបន្តិច

បន្តួច លើការឈឺចាប់លើទារុណកម្មដែលបានកើតឡើងលើឪពុកខ្ញុំ និងលក្ខខណ្ឌនៃការស្លាប់របស់គាត់។ ក៏ប៉ុន្តែពួកគេបានដឹងបានដឹងទាំងអស់ ជាពិសេស ម៉ម ណៃ ។

នៅក្នុងជំនួបមួយជាមួយ ប្រាក់ ខន, ហ៊ឹម ហ៊ុយ, ញោប ហូ បានបញ្ជាក់ ប្រាប់ខ្ញុំថា អ្នកដឹងថា អ្វីៗដែលបានកើតឡើងលើរូបឪពុកនាងខ្ញុំ គឺមានតែជនជាប់ចោទម្នាក់គត់។ ជនជាប់ចោទ គឺជា *ឌីរិកទ័រ* នៅក្នុងមន្ទីរឃុំឃាំងរបស់អ្នកស្លាប់។ សម្រាប់ថ្នាក់ដឹកនាំខ្មែរក្រហមស-២១ គឺជាឧបករណ៍សម្រាប់កម្ទេចទៅតាមតម្រូវការរបស់ពួកគេ និងជនជាប់ចោទ គឺជាពេជ្ឈឃាដដែលមានភក្តីភាព ។ បន្ទាប់ពីបានភូតកុហកជាច្រើនលើក ជនជាប់ចោទ បានសារភាពថា ឪពុកនាងខ្ញុំពិតជាបានមកស-២១ គាត់ផ្ទាល់ថែមទាំងបានសូត្រទ្រឹស្តីឲ្យ ម៉ម ណៃ និយាយការពិតនៅអ្វីៗដែលបានកើតឡើងចំពោះឪពុកខ្ញុំ ។ គាត់ស្លាប់នៅឯណា? ប៉ុន្តែ ខ្លួនជនជាប់ចោទផ្ទាល់ពុំដែលបានផ្តល់ការពិតជាក់លាក់ណាមួយ ព្រមទាំងទទួលស្គាល់ការទទួលខុសត្រូវទៅលើការសម្លាប់រូបឪពុកខ្ញុំឡើយ ។

នាងខ្ញុំសូមបញ្ជាក់ម្តងទៀតថា ជនជាប់ចោទ ជាសាស្ត្រាចារ្យគណិតសាស្ត្រ អ្វីៗវាបញ្ជាក់ឲ្យដឹងថា គេជាមនុស្សដែលចេះគិតល្អិតល្អន់ណាស់ និងមានស្មារតី *មេតូឌិក* គិតគូសពង្រគ្រប់ទាំងអស់ ។ ក៏ប៉ុន្តែនៅចំពោះមុខអង្គសវនាការជនជាប់ចោទភូតកុហកជាច្រើនសា។ នៅថ្ងៃទី១០ កក្កដា ២០០៨គាត់បានសរសេរបញ្ជាក់មកខ្ញុំថា កាលពីមុន ខ្ញុំតែងតែប្រកែកថា សាស្ត្រាចារ្យ ភឹង តុន មិនបាចូលស-២១ទេ ។ បន្ទាប់ពីបានទៅស-២១និងដើងឯក ខ្ញុំក៏លើកបញ្ហានេះមកគិតឡើងវិញ គាត់ក៏សរសេរបន្ទាប់ទៀតថា លោកគ្រូពិតជាបានមករងទុក្ខវេទនា យ៉ាងអមនុស្សធម៌នៅស-២១ ដោយទទួលស្គាល់ឧក្រិដ្ឋ-កម្មទាំងអស់ ដែលស-២១ ប្រព្រឹត្តទៅលើលោកគ្រូ ។

[១៣:៥២:០០]

នៅលើឯកសារបញ្ជាក់របស់ជនជាប់ចោទដដែលបានថា គ្មានទារុណកម្មនៅពេលសួរចម្លើយបឋមទេ ខ្ញុំស្គាល់បង ម៉ម ណៃ គាត់កម្រធ្វើទារុណកម្មណាស់ ។ ឯកសារបង្ហាញថា ហ៊ី បានសរសេរដោយនិយាយពីឪពុកនាងខ្ញុំថាពីរថ្ងៃឈប់ ។ ជនជាប់ចោទ ហូបបាយទឹកជាមួយ ហ៊ី រាល់ថ្ងៃ ។ ហ៊ី ត្រូវបានគេទទួលស្គាល់ថា ជាមនុស្សម្នាក់ដែលមានចិត្តសាហាវ តែក៏ជាទំនុកចិត្តរបស់ ឌុច ដែលជាឧបករណ៍ដ៏ស្មោះត្រង់របស់ជនជាប់ចោទ និងដែលតែងតែចាំស្តាប់បង្គាប់របស់ជនជាប់ចោទ មុននឹងសម្រេចធ្វើអ្វីមួយ ។ ដូច្នេះ គឺជាការពិតណាស់ដែល ឌុច បានបញ្ជាទៅលើ ហ៊ី ចំពោះករណីឪពុកខ្ញុំឲ្យធ្វើអ្វីៗនោះ ។

ឌុច បាននិយាយនៅក្នុងអង្គសវនាការជាចំហថា គាត់ជាមនុស្សជោរ គាត់ និងជា *ប៉ែកហ្សេ* ជាមួយនេះដែរ គាត់ក៏ជាឧបករណ៍ផ្ដាច់ការ ជាប៉ូលិសសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ដូច្នេះ រឿងអ្វីៗមិនរំលងគាត់បានទេ ករណីឪពុកខ្ញុំ គឺ ឌុច ដឹងទាំងអស់ ទាំងការឃុំឃាំង ការធ្វើទារុណកម្ម និងការកម្ទេច ។

លោកប្រធាន នាងខ្ញុំសូមលើកបីសំណួរទៅកាន់ជនជាប់ចោទ តាមរយៈលោកប្រធាន ប៉ុន្តែមុននឹងលើកសំណួរនេះ នាងខ្ញុំសូមនិយាយបន្តបន្តិចទៀតសិន ។

នាងខ្ញុំមិនទទួលត្រឹមតែជាការឆ្លើយតបទៅលើរចនាសម្ព័ន្ធនៃកម្ពុជាប្រជាធិបតេយ្យមាគ៌ាបក្សកុម្មុយនីស្តកម្ពុជានោះទេ ឬអ្នកទទួលខុសត្រូវដែលស្ដាប់ផុតទៅហើយ វាស្រួលពេក ។

ជនជាប់ចោទបង្ហាញខ្លួនថា មានការការសោកស្ដាយ ប្រាថ្នាចង់សហការជាមួយ ព្រមទាំងមានកង្វល់ចំពោះជនរងគ្រោះ ចំពោះខ្ញុំ ដែលចាប់ផ្ដើមមកតាមដាននៅសវនាការតាំងពីដើមដំបូង ។ ប៉ុន្តែ ខ្ញុំបានយល់ពីល្បែងនេះ ពីយុទ្ធវិធីលាក់ក្រចក នាងខ្ញុំមិនជឿទាល់តែសោះថា ជនជាប់ចោទខិតខំអស់ពីសមត្ថភាពក្នុងការស្វែងរកការពិតនោះឡើយ ។ ផ្ទុយទៅវិញ គេបានធ្វើអ្វីៗឲ្យតែបានរាំងកុំឲ្យតែការពិតផ្លាយចេញបាន ទាំង ម៉ម ណៃ ក៏មិនបានជ្រោមជ្រែងជួយ ដើម្បីទម្លាយអាថ៌កំបាំង ដែលការភ័យខ្លាចការតាមដានចាប់ខ្លួន ។

ជនជាប់ចោទ ដឹងចម្លើយដែលត្រូវឆ្លើយតបទៅសំណួរខ្ញុំទាំងអស់ ប្រសិនបើគាត់នៅតែប្រកាន់ថាគាត់មិនដឹងអ្វីទាំងអស់ តើគាត់អាចជាមេដឹកនាំប៉ូលីសសម្ងាត់ ដូចដែលគេបានរៀបរាប់យ៉ាងដូចម្ដេចទៅ? មេដឹកនាំស-២១ ត្រឹមតែជាអាយ៉ង ឬក៏ជាជនកំសាក?

[១៣:៥៥:២៨]

ប្រសិនជាជនជាប់ចោទនៅតែមិនឆ្លើយក្នុងករណីនេះ សូមកុំឲ្យជនជាប់ចោទនិយាយឲ្យសោះថាមានវិប្បដិសារី ឬក៏សុំទោសដល់វិញ្ញាណក្ខន្ធរបស់ឪពុកខ្ញុំ ឬក៏សុំរំលែកទុក្ខពីគ្រួសារខ្ញុំ ។ នាងខ្ញុំមកទីនេះ មិនមែនមកសងសឹកទេ គឺមកស្វែងរកការពិត ក៏ប៉ុន្តែ ជនជាប់ចោទបដិសេធឆ្លើយនឹងសំណួរខ្ញុំ ។ ខ្ញុំបិទទ្វាជារៀងរហូតមិនឲ្យជនជាប់ចោទចូលសុំទោសក្នុងករណីណាដែលមិនទម្លាយការពិតទៅដល់វិញ្ញាណក្ខន្ធឪពុកនាងខ្ញុំ ។ ជនជាប់ចោទមិនអាចបោកបញ្ឆោតវិញ្ញាណក្ខន្ធគាត់បានទេ ។ នាងខ្ញុំសូមឲ្យជនជាប់ចោទរស់នៅឲ្យបានយូរនិងសុខភាពល្អ ដើម្បីទុកឲ្យដំណាក់កាលចុងក្រោយនៃជីវិតរបស់គាត់ឈរនៅលើសម្បជញ្ញៈ ហើយមើលទៅអតីតកាលដែលគាត់បានប្រព្រឹត្តយ៉ាងអមនុស្សធម៌ និងដើម្បី

បានវិលត្រឡប់មកភាពជាមនុស្សត្រឹមត្រូវិញ និងមើលឲ្យបានដឹងខ្លួនថា អ្វីដែលខ្លួនបានប្រព្រឹត្តទៅលើឪពុកខ្ញុំ និងទៅលើជនរងគ្រោះឯទៀតដែលប្រឆាំងនឹងមនុស្សជាតិ ក៏ជាបទឧក្រិដ្ឋប្រឆាំងទៅលើកូនគាត់ និងចៅគាត់ដែរ ដែលពួកគេក៏ជាផ្នែកមួយនៃមនុស្សជាតិ ។

លោកប្រធាន មុននឹងបញ្ចប់នាងខ្ញុំចង់និយាយទៅកាន់ប្រជាជនខ្ញុំថា អ្វីៗដែលកើតឡើង ដែលធ្វើឲ្យយើងឈឺចាប់ ព្រាត់ប្រាស ក្តុកក្តួលរំជួលចិត្ត និងប្រេះស្រាំរហូតមកដល់ថ្ងៃនេះ អ្វីដែលកើតឡើងនៅរបបកម្ពុជាប្រជាធិបតេយ្យ វាគ្មានអ្វីទាក់ទងនៅលើបញ្ហាកម្មផលទេ ។ នាងខ្ញុំក៏ជាពុទ្ធសាសនិកជនដែរ ក៏ប៉ុន្តែរបបបាតដៃប្រឡាក់ឈាមនេះ វាដឹកនាំដោយមនុស្សមួយក្រុមដែលផ្អែកទៅលើមនោគមន៍វិជ្ជានៃការកាប់សម្លាប់ ។ ការប្រើប្រាស់គោលការណ៍ និងជំនឿពុទ្ធសាសនា ឬក៏សាសនាដទៃទៀត ដើម្បីសម្រាលកំហុសអ្នកដឹកនាំនៃរបបនេះ វាជារឿងដែលយើងគ្រប់គ្នាមិនទទួលយកបានទាល់តែសោះ ។

ខ្ញុំក៏ចង់និយាយទៅកាន់យុវវ័យគ្រប់រូបនៃប្រទេសខ្ញុំថា ទោះបីជានៅពីក្រោយភាពខ្មៅអន្ធការ ក៏នៅតែមានមនុស្សដែលអាចផ្តល់នៅពន្លឺត្រចះត្រចង់ តាមភាពអង់អាចរបស់គេ តាមជំនឿមោះមុតរបស់គេ តាមកេរ្តិ៍ឈ្មោះ និងកិត្តិសព្ទរបស់គេ ។ ឪពុកនាងខ្ញុំ ភឹង តុន ក៏ជាមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងនោះដែរនៅក្នុងអង្គសវនាការនេះ យើងទាំងអស់កំពុងតែបំពាក់ជូនគាត់ឡើងវិញនៅភាពជាមនុស្សជាតិ ដែលពួកឧបករណ៍ផ្តាច់ការនៃអំណាចរបស់កម្ពុជាប្រជាធិបតេយ្យបានប្លន់ជីវិតគាត់ ក៏ប៉ុន្តែពួកអស់នោះមិនអាចប្លន់ និងកម្ទេចឧត្តមគតិគាត់ដែលមានរហូតដល់សព្វថ្ងៃនេះបានទេ ។

នាងខ្ញុំសូមចប់ការថ្លែងសេចក្តីថ្លែងការណ៍ និងសុំលើកសំណួរទៅកាន់ជនជាប់ចោទ ។

[១៥:៥៨:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយជនជាប់ចោទសូមត្រងត្រាប់ស្តាប់នូវ សំណួរដូចជាយើងបានធ្វើពីរថ្ងៃរួចហើយ គឺសំណួរនេះពិតមែនតែសួរឆ្លងរយៈ តាមរយៈប្រធាននៃអង្គជំនុំជម្រះសាលាដំបូងមែនប៉ុន្តែ គឺប្រធានអាចលទ្ធភាពក្នុងការធ្វើការរំឭកឡើងវិញអំពីសំណួរ ឬក៏បញ្ជូនទូវសំណួរនោះទៅជនជាប់ចោទ ដើម្បីឲ្យជនជាប់ចោទឆ្លើយតែម្តង ដើម្បីចៀសវាងនូវការបាត់បង់នូវខ្លឹមសារនៃសំណួរ ។

សូមអញ្ជើញ ។

**លោកស្រី ភឹង ហ្គុតស៊ុនថារី៖**

ចាំ, សូមអរគុណលោកប្រធាន ។ នាងខ្ញុំសូមតាំងសំណួរតាមរយៈលោកប្រធាន ។

សំណួរទីមួយ តើអ្នកណាជាអ្នកសម្រេចសម្លាប់ឪពុកនាងខ្ញុំ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ៧៧ ឬក៏ពេលក្រោយបន្តិច? នៅស-២១ គេមិនទុកឱ្យអ្នកទោសស្លាប់ខ្លួនឯងទេ ជាពិសេសអ្នកទោសដូចជាឪពុកខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទយើងបញ្ជូនសំណួរនេះ ដើម្បីជនជាប់ចោទអាចឆ្លើយតបនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

សូមអញ្ជើញ ។

[១៤:00:00]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន ។ កាលដែលខ្ញុំវិភាគឯកសារទាំងប៉ុន្មាន ហើយរាយការណ៍ជូនដើមបណ្តឹងរដ្ឋប្បវេណី វាអស់ពីចំណេះរបស់ខ្ញុំហើយ ។ ដូច្នេះ ដល់ទៅសួរថាអ្នកណាសម្រេចឱ្យសម្លាប់ ខ្ញុំមិនទាន់មានឯកសារស្អីឱ្យស្រាវជ្រាវលើសពីនោះតទៅទៀតបានទេ ។ ដូច្នេះ សូមទោសចុះ ខ្ញុំមិនអាចបំពេញការចង់ដឹង ចង់ជ្រាបរបស់អ្នកស្រីបានទេ ។ ថ្វីត្បិតតែ ខ្ញុំមានការគោរពយ៉ាងជ្រាលជ្រៅចំពោះវិញ្ញាណក្ខន្ធលោកគ្រូក៏ដោយ ក៏ខ្ញុំមិនដឹងជានឹងឆ្លើយយ៉ាងម៉េច ។ ព្រោះរឿងពិត គឺវត្តមានរបស់លោកមកនៅស-២១ ខ្ញុំនៅតែរកនឹកមិនឃើញថា ខ្ញុំដឹង ហើយមិនទាន់មានឃើញភស្តុតាងអីដែលថាខ្ញុំដឹង ។ នេះសូមជម្រាបបញ្ជាក់ដោយស្មោះត្រង់ប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញតាំងសំណួរបន្ត ។

**លោកស្រី ភឹង ហ្គុនស៊ុនថារី៖**

សំណួរទីពីរ តើប្រភេទទារុណកម្មបែបណាខ្លះ ដែលគាត់បានទទួលសម្រាប់មនុស្ស ដែលមានគំនិតជឿនលឿន ដែលឱ្យតម្លៃទៅលើសច្ចធម៌ ភាពត្រឹមត្រូវ ការពិភាក្សាតាមបែបផែនប្រជាធិបតេយ្យ ដែលជាគំនិតផ្ទុយគ្នាពីមនោគមន៍វិជ្ជាកាប់សម្លាប់ខ្មែរក្រហម?

**ប្រធានអង្គជំនុំ៖**

យើងបញ្ជូនសំណួរនេះទៅជនជាប់ចោទ ដើម្បីឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! បើនិយាយអំពីទារុណកម្មដែលលោកគ្រូទទួល ខ្ញុំនៅតែជឿថា សេចក្តីដែលខ្ញុំបានវិភាគលើឯកសារដែលអ្នកស្រីប្រគល់ឲ្យខ្ញុំ ខ្ញុំនៅតែជឿថា លោកគ្រូមិនត្រូវបានធ្វើទារុណកម្មក្នុងពេលសួរចម្លើយ ហើយដើម្បីយកចម្លើយទេ ។

រឿងដែលខ្ញុំតក់ស្លុតបំផុតចំពោះវិញ្ញាណក្ខន្ធលោកគ្រូ គឺរឿងផ្សេងទៅវិញ ។ គឺរឿងខ្ញុំមិនបានដឹង មិនបានឧបត្ថម្ភលោកគ្រូ ប្រហែលខ្ញុំឧបត្ថម្ភ ចៅ សេង ហើយនិង វ័ត្ន គត់ ទេ ហ្នឹងជារឿងធំដែលខ្ញុំនៅសោកស្តាយ ។ ត្រង់ដែលថា ទារុណកម្មដោយ ម៉ម ណៃ អត់មានទេ ។ មនុស្សនោះមិនងាយនឹងធ្វើទារុណកម្មទេ ហើយសំណួរបឋមបែបនេះ បានចម្លើយប៉ុណ្ណេះ មិនមែនជាចម្លើយដែលបានមកដោយទារុណកម្មទេ ។ ហើយទន្ទឹមនេះ ខ្ញុំក៏សូមឆ្លៀតបញ្ជាក់ជូនអ្នកស្រី ភឹង ហ្គុនស៊ុនថារី ដែលជាបុត្រីច្បងរបស់លោកគ្រូផងដែរ ។ ពីរឿងដែលខ្ញុំមិនដឹង ។ អ្នកស្រីមើលចុះ ឯកសារទាំងប៉ុន្មាន ដែលស-២១ បញ្ជូនទៅលើសុទ្ធតែមានចំណារខ្ញុំ ។ ប្រសិនបើខ្ញុំដឹង ពិតជាមានចំណារ យ៉ាងហោចណាស់ក៏ខ្ញុំត្រូវបង្ខំឲ្យបង ម៉ម ណៃ សួរប្រវត្តិលោកគ្រូ ក្នុងករណីដែលគាត់ទៅធ្វើការជាមួយកម្ពុជបុត្រ ។ ខ្ញុំស្គាល់មជ្ឈ-ដ្ឋានរបស់សាលាកម្ពុជបុត្រនេះច្បាស់។ ខ្ញុំមុនដំបូង ខ្ញុំអត់ដឹងថា លោកគ្រូទៅនៅធ្វើការនៅសាលាកម្ពុជបុត្រទេ ។ ដល់ឃើញខ្ញុំដឹងថា អ៎! ប៉ុល ពត សង្ស័យណាស់ហើយ ពីរឿងលោកគ្រូទៅធ្វើការនៅសាលាកម្ពុជបុត្រ ។ លោកស្រីជ្រាបហើយកម្ពុជបុត្រមាន ហ៊ូ យន់ ធ្វើប្រធានសមាគម លោកតា ម៉ៃ ម៉ាន់ *ប្រូសហ្វេស័រ* នាយកវិទ្យាល័យកម្ពុជបុត្រ, សួស នៅ ហៅ ឈូក អគារនុរក្ស ។ ដូច្នេះ មជ្ឈដ្ឋាននេះគឺមជ្ឈដ្ឋានប្រឆាំងនឹង ប៉ុល ពត ។ សួស នៅ ហៅ ឈូក ក្រោយមកធ្វើជាលេខាតំបន់២៤ សុន សេន ទូរស័ព្ទមកសួរខ្ញុំថា មិត្តឌុច មើលឲ្យច្បាស់ណាស់ មិត្តឯងតាមដានឲ្យច្បាស់ណាស់ សួស នៅ ហៅ ឈូក មានយកលោកតា ម៉ៃ ម៉ាន់ ទៅធ្វើការទេ? ខ្ញុំតាមដានទៅថា អត់ទេ ។

ដូច្នេះ រឿងទាំងអស់នេះបើសិនជាខ្ញុំដឹងថា លោកគ្រូទៅនៅទុំង ខ្ញុំបើគេបញ្ជាឲ្យសួរខ្លាំងពេកត្រង់ហ្នឹងហើយដែលខ្ញុំត្រូវឲ្យ ម៉ម ណៃ សួរតទៅទៀត ត្រង់កន្លែងកម្ពុជបុត្រ ។ ដល់គ្មានចំណារហើយបញ្ជាឲ្យទេ គឺនេះជាភស្តុតាងមួយទៀត ដែលខ្ញុំសូមបញ្ជាក់ថា ខ្ញុំអត់មានដឹងទេ ។ នេះ គឺខ្ញុំវិភាគដោយស្មោះត្រង់ថា វាអ៊ីចឹងមែន ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

សូមលោកស្រីបន្តសំណួរ ។

**លោកស្រី ភីង ហ្គុនស៊ុនថារី៖**

សំណួរទីបី ជាសំណួរចុងក្រោយ អ្នកណាសម្រេចបញ្ជូនគាត់ទៅស-២១? គេបានបញ្ជាក់ថា មានរថយន្តពីស-២១ ទៅចាប់គាត់ពីផ្សារថ្កូវ ជាភស្តុតាងរបស់លោក ឆាន់យ៉ាណូ និង លោក ហាំ ហេងខេង ដែលមានវត្តមាននៅទីនោះដែរ នៅសាលាផ្សារដើមថ្កូវ វេលាម៉ោងដប់ព្រឹក ថ្ងៃទី១២ ខែ១២ ឆ្នាំ៧៦ ។

**ប្រធានអង្គជំនុំ៖**

យើងបញ្ជូនសំណួរនេះទៅជនជាប់ចោទ ដើម្បីឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ ។

[១៤:០៦:១៤]

**ជនជាប់ចោទ៖**

សូមបញ្ជាក់ថា កាលដែលចាប់លោកចូលមក ស-២១ ឬក៏ខាងបឹងត្របែក ឬខាងណាគេបញ្ជូនមក ខ្ញុំក្ដាប់មិនបានទេ ។ ហើយសូមបញ្ជាក់ថា រថយន្តស-២១ ក៏មិនមានលេខទេ ។ ខ្ញុំមិនបដិសេធសក្ខីកម្មរបស់លោកស្អីអំមិញនោះ ហើយនិង ហេង ហាំខេង ទេ ព្រោះអា ហេង ហាំខេង វានៅនុ៎ងមែន ពួកម៉ាកខ្ញុំអានោះ ។ ក៏ប៉ុន្តែ ខ្ញុំបញ្ជាក់ថា ប្រវត្តិសាស្ត្ររបស់មន្ទីរស-២១ វាមានប្រធានពីរដំណាក់ ។ ដំណាក់ទីមួយ គឺ ណាត គេធ្វើចាប់តាំងពីការកកើតមក រហូតមកដល់ចាប់កំណើតស-២១ ជាផ្លូវការ ថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៥ រហូតដល់ខែបី គឺខែមីនា ១៩៧៦ បានខាងលើដកណាតចេញ ដាក់ខ្ញុំ ។

ដូច្នេះ ខ្ញុំជឿថា ឯកសារទាំងឡាយណាដែលបង ម៉ម ណៃ សួរចម្លើយ ហើយគ្មានចំណារខ្ញុំគឺឯកសារនេះនៅស្ថិតនៅក្នុងរយៈកាល ណាត ធ្វើលេខា ។ ដូច្នេះអាច ណាត ឲ្យកម្លាំងទៅតាមសេចក្ដីរបស់អចិន្ត្រៃយ៍ក៏ថាបាន ។ ពីព្រោះអចិន្ត្រៃយ៍ជាអ្នកសម្រេចពីខាងលើមកស-២១ នេះ វានៅខាងក្រោមបញ្ជារបស់អចិន្ត្រៃយ៍ ។

ដូច្នេះ អារឿងយើងយកអ្នកប្រតិបត្តិការចាប់ អាហ្នឹងវាម្យ៉ាងហើយ ក៏ប៉ុន្តែខ្ញុំមិនឆ្លើយហួសទៅទៀតទេ ។ អ្នកស្រីអត់បានសួរខ្ញុំថា តើអ្នកណាអ្នកសម្រេចឲ្យចាប់ទេ? ខ្ញុំជឿថាអ្នកស្រីយល់ហើយ ។ ដូច្នេះខ្ញុំសូមមិនបញ្ជាក់អីទៀតទេ ខ្ញុំគ្រាន់តែថា អាចរថយន្តស-២១ ទៅយកលោកគ្រូមក ក៏ថាបាន ពីព្រោះពេលនោះ ណាត គេនៅធ្វើលេខា ។ ហើយខ្ញុំជឿជាក់ថា លោកគ្រូមកនៅពេលដែល ណាត គេធ្វើលេខា ខ្ញុំធ្វើអនុលេខា ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ ។ សូមគោរព ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្ទូតហ្វ៊ីនស្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីបន្ថែម ប្រសិនបើមានសំណួរ។ លោកស្រីមេធាវីអាចសម្រាកបន្តិចសិន មានបញ្ហាលោកចៅក្រម ហ្សង់ម៉ាក គាត់ចង់មានយោបល់ ។ អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ។ ព្រឹកមិញនេះ លោកស្រីបានបង្ហាញរូបថតមួយចំនួន តើអាចផ្តល់ឲ្យនូវរូបថតហ្នឹងមានបញ្ជី ថាតើមួយៗ មានន័យដូចម្តេច? តើយើងអាចដាក់តម្កល់ចូលក្នុងសំណុំរឿង? បើមិនអ៊ីចឹងទេ យើងមិនមានព័ត៌មានអំពីរូបថតទាំងនោះទេ ។

ខ្ញុំមិនចង់និយាយថា ឲ្យបង្ហាញម្តងទៀតទេ គឺគ្រាន់តែជម្រាបប្រាប់យើងថា តើបង្ហាញរូបហ្នឹងរូបអ្វីខ្លះ? តើរូបថតហ្នឹងជារូបថតអ្នកណា? ហើយថតនៅពេលណា? ដើម្បីយើងកត់ត្រាចូលប្រតិចារិកសម្រាប់អង្គជំនុំជម្រះ ។

**លោកស្រី ភីង ហ្គុនស៊ុនថារី៖**

ចាស, សូមអរគុណទៅចំពោះលោកចៅក្រម ។ រូបថតពីរនាក់ធំៗ មួយកំណាត់ខ្លួន គឺជារូបថតឪពុកម្តាយខ្ញុំ ។ រូបថតមួយទៀត ប្រាំនាក់នេះ គឺបងប្អូនខ្ញុំទាំងប្រាំពីរនាក់ ។ រូបថតមួយទៀត គឺរូបថតឪពុកម្តាយខ្ញុំពេលដែលគាត់ទៅលេងស្រុកបារាំង ។ រូបថតមួយទៀត គឺរូបថតឪពុកខ្ញុំថតនៅរដូវក្តៅឆ្នាំ៧៥ ពេលភ្នំពេញបែកហើយ គឺថតប៉ុន្មានខែមុនដែលគាត់វិលត្រឡប់មកប្រទេសខ្មែរវិញនៅចុងឆ្នាំ៧៥។ ឯរូបមួយ គឺជាសំបុត្ររៀបអាពាហ៍ពិពាហ៍របស់ឪពុកម្តាយខ្ញុំ ។ រូបចុងក្រោយ គឺជារូបឪពុកខ្ញុំ ដែលថតនៅមន្ទីរឃុំឃាំងស-២១ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ប្រសិនបើមានសំណួរអ្វីចង់សួរបញ្ជាក់ទៅបន្ថែមដល់ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្តី៖**

សូមអរគុណលោកប្រធាន ។

**ស៖** ខ្ញុំមានសំណួរតែមួយទេ បន្ទាប់ពីបានពិនិត្យមើលនូវចម្លើយរបស់ជនជាប់ចោទ ទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់សុំឱ្យដើមបណ្តឹងរដ្ឋប្បវេណីបំភ្លឺបន្ថែម ថាតើលទ្ធផលនៃការស្រាវជ្រាវរបស់លោកស្រីនោះបានអ្វីខ្លះហើយកាលបរិច្ឆេទដែលឪពុករបស់លោកស្រីបានចូលទៅស-២១ ទួលស្លែង។ ថាតើអ្នកណាជាប្រធាននៅពេលដែលឪពុករបស់លោកស្រីចូលទៅដល់ស-២១? ពីព្រោះតាមចម្លើយរបស់ជនជាប់ចោទនោះ យើងឃើញមានការព័ត៌មានច្រលូកច្រឡំបន្តិច ។ ថាតើនៅពេលដែលឪពុកលោកស្រីចូលទៅដល់ស-២១ ថាតើអ្នកណាជាប្រធាននៅពេលនោះ? ដើម្បីឱ្យអង្គសវនាការបានជ្រាបច្បាស់ផងដែរ ។

**ស៖** ចាស, អរគុណ ចំពោះសំណួរលោកស្រីមេធាវី ។ ខ្ញុំក៏មានការភ្ញាក់ផ្អើលដែរ ពីព្រោះជនជាប់ចោទបាននិយាយថា គាត់-- ការចាប់ឪពុកខ្ញុំចូលស-២១ មិនស្ថិតនៅក្រោមការដឹកនាំរបស់គាត់ជាមេស-២១ ទេ ។ តាមពិតគាត់បានឡើងមកកាន់នៅ ស-២១ នៅខែមីនា ឆ្នាំ៧៦ ។ ដូច្នេះការចាប់ឪពុកខ្ញុំនៅថ្ងៃទី១២ ខែ១២ ឆ្នាំ៧៦ គឺពិតជានៅក្រោមការដឹកនាំរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ពិតមែន ។

**លោកស្រី ស៊ីលឃីស្វត ហ្សីនស្គី៖**

សូមអរគុណចំពោះចម្លើយនេះ ប្រហែលនៅពេលក្រោយជនជាប់ចោទអាចនឹងផ្តល់ការបំភ្លឺដែលគាត់ជាអ្នកដឹងយ៉ាងច្បាស់អំពីព័ត៌មាននោះ ។ គឺថាអាចនឹងទាក់ទងទៅនឹងការផ្តល់ចម្លើយទៅអង្គជំនុំជម្រះ ឬក៏បំភ្លឺ ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។ សូមអរគុណចំពោះដើមបណ្តឹងរដ្ឋប្បវេណី ចំពោះកិច្ចប្រឹងប្រែងធ្វើសេចក្តីថ្លែងការណ៍ ហើយដែលធ្វើបានយ៉ាងល្អ ពោរពេញទៅដោយមនោសញ្ចេតនា អារម្មណ៍ទុក្ខសោក ហើយជូនអង្គជំនុំជម្រះ ហើយនិងពលរដ្ឋកម្ពុជាផងដែរ ។ សូមអរគុណ ។

[១៤:១៥:00]

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្គេកអ៊ាវ អញ្ជើញក្រោកឈរ ។ លោកអាចបញ្ជាក់នូវចំណុចនេះបានទេ ពីព្រោះបញ្ហានេះភាគីដើមបណ្តឹងរដ្ឋប្បវេណីហាក់ដូចជាគ្រាន់តែចង់ច្បាស់លាស់តែប៉ុណ្ណោះទេ ។ ចំណែកឯការដែលឪពុករបស់គាត់បានទៅជួប ទៅដល់មន្ទីរសន្តិសុខស-២១ ហើយបានត្រូវស្លាប់ ឬក៏សម្លាប់នៅទីនោះ វាជាការពិតហើយ ។ ឥឡូវហ្នឹងនៅតែហេតុផលមួយចំនួនដោយសារព័ត៌មាន ដែលគាត់បានទទួលគឺថាឪពុករបស់គាត់ បានចូលទៅដល់មន្ទីរសន្តិសុខស-២១ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ ។ ហើយលោកបានផ្តល់ចម្លើយជាច្រើនលើក ជាច្រើនសា ហើយក៏ដូចអម្បាញ់មិញបញ្ជាក់សាជាថ្មីថែមទៀតថា

លោកកាលដំបូងឡើយធ្វើជាអនុប្រធាន ហើយឬក៏អនុលេខា ហើយចាប់ពីខែមីនា ឆ្នាំ១៩៧៦ ថ្នាក់លើដក ណាត ចេញ ហើយដំឡើងលោកធ្វើជាលេខា ឬក៏ជាប្រធានមន្ទីរ ស-២១ ។ នេះហើយ ដល់ពេលកាលបរិច្ឆេទនៃការចាប់ខ្លួន ភឹង តុន ថ្ងៃទី១២ ខែធ្នូ ៧៦ ។ ហើយអម្បាញ់មិញនេះ គឺយើងបានស្តាប់ច្បាស់លាស់ គឺលោកបានធ្វើការវិភាគទៅតាមឯកសារនានាដែលមាននៅក្នុងស-២១ ហើយមាននៅក្នុងសំណុំរឿង ប៉ុន្តែគ្មានចំណាររបស់លោក ។

សំណួរសួរថា តើមានបញ្ហាខុសគ្នារវាងកាលបរិច្ឆេទនៃការចាប់ខ្លួន ហើយនិងការដែលលោកធ្វើប្រធានតាំងពីខែបីរហូតដល់ខែដប់ពីរ ទើបចាប់ឪពុករបស់គាត់មក អានេះនាំឲ្យមានបញ្ហា ។ តើលោកអាចបញ្ជាក់អំពីបញ្ហានេះបានដែរឬទេ?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព ។ រឿងនេះវែងបន្តិច ខ្ញុំក៏មានបំណងចង់បញ្ជាក់ជូនអ្នកស្រី ជូនអ្នកបងឲ្យច្បាស់អំពីបញ្ហានេះផងដែរ ។ មុនឆ្នាំ១៩៧០ ខ្ញុំមានទឹកចិត្តគោរពកោតខ្លាចមនុស្សប្រាំមួយនាក់ ប៉ុន្តែ ខ្ញុំមិននិយាយពីរនាក់ទៀតទេ ។ ពីរនាក់នោះ គឺជាលោកសង្ឃ មួយអង្គ គឺសម្តេចព្រះសង្ឃរាជ ជួន ណាត ព្រះអង្គទ្រង់សោយទិវង្គតនៅឆ្នាំ១៩៦៩ រួចទៅហើយ ។ មួយអង្គទៀត គឺលោកគ្រូមេកុដិខ្ញុំ ខ្ញុំគោរពខ្លាំងណាស់ តែក៏លោកសុគតនៅឆ្នាំ១៩៦៩ដែរ ។ មនុស្សទី៣ ដែលខ្ញុំគោរព គឺដុកទ័រ វ័ន្ន គត់ ដែលខ្ញុំទុកជារៀមច្បង ជាកូនសិស្សកុដិលេខបីដូចគ្នា ជារៀមច្បង ។ ហើយសូមបញ្ជាក់ថា ពួកកូនសិស្សកុដិលេខបីវាគោរពគ្នាតគ្នាតាមជំនាន់អ៊ីចឹង ។ រៀមច្បងគេ គេគោរពច្រើនគ្នា សូមបញ្ជាក់ថែមថា មិត្ត ប៉ុន ដែលនៅជាមួយនឹងខ្ញុំនេះ ក៏ជាកូនសិស្សកុដិលេខបីដែរ ។

ដូច្នេះ ខ្ញុំនិយាយត្រឡប់មកវិញ បុគ្គលទីបី ដែលខ្ញុំគោរព គឺដុកទ័រ វ័ន្ន គត់ ដែលខ្ញុំចាត់ទុកជារៀមច្បង ។ បុគ្គលទីបួន ដែលខ្ញុំគោរពគឺ ចៅ សេង ។ ចៅ សេង នេះ ដែលខ្ញុំគោរពគាត់ មកពីទីមួយគាត់បានកែប្រែកម្មវិធីសិក្សាមធ្យមសិក្សា គេហៅថា កម្មវិធីសិក្សាឆ្នាំ១៩៥៨ ។ ទីពីរ ចៅ សេង បានតទល់ជាមួយ លន់ នល់ នៅសមាជជាតិម្តង ។ គាត់ថា “គេមានស្លាបប៉ាកា គេអត់កាំភ្លើងទេ គេសរសេរ” នេះ ចៅ សេង ។

ហើយទីបី ដែល ចៅ សេង ធ្វើល្អ ដែលឲ្យខ្ញុំគោរព គឺគាត់បង្កើតវិទ្យាស្ថានជាតិគរុកោសល្យខាងត្បូងសម្រាប់កសាងសាស្ត្រាចារ្យនេះ ដែលធ្វើឲ្យខ្ញុំចូលទៅរៀនសាស្ត្រាចារ្យនេះ វាមានការបានរៀនសូត្រចិត្តសាស្ត្រគរុកោសល្យ នេះ ចៅ សេង ដែលខ្ញុំគោរព ។ បន្ទាប់មកខ្ញុំមានការគោរពចំពោះ

ខៀវ កុមារ ឆ្នាំ១៩៦៣ និង៦៤នេះ ពោរពេញណាស់ បាតុកម្មនៅលីសេស៊ីសុវត្ថិ ។ លោកគ្រូ ខៀវ កុមារ យកខ្លួនរាំង ការពារពួកសិស្សចំរើននៅនោះ ដែលធ្វើការប៉ះបោរ ។

[១៤:១៩:៣៥]

ហើយដល់វិទ្យាស្ថានជាតិគរុកោសល្យខ្ញុំ ជនចំរើនថ្មីនេះ មានខ្ញុំ មាន ជុំ ណារិទ្ធ អីជាដើម ។ ត្រូវបាន កៅ លន់ គាត់ធ្វើទុក្ខ ធ្វើបាប ខ្ញុំឃើញបានលោកគ្រូគាត់ទប់ ។ ដូច្នេះ ខ្ញុំមានចិត្តគោរពកោត ខ្លាចបុគ្គលម្នាក់នេះ ដោយសារតែគាត់បានជួយទប់ទល់កុំឲ្យគេធ្វើបាបពួកជនចំរើននៅចិត្តសាស្ត្រគរុ-កោសល្យ ។ មនុស្សទាំងអស់នេះ ខ្ញុំដឹង លោកគ្រូ ខៀវ កុមារ ដឹងថាគេជម្លៀសគាត់ទៅតាមផ្លូវលេខ៤ ខ្ញុំថា អ៎! បើទៅខាងជើងផ្លូវ តាស៊ី យកគាត់ទៅវៃចោលបាត់ហើយ បើទៅតាមត្បូងផ្លូវ តាម៉ុក ។ នេះ លោកគ្រូ ខៀវ កុមារ ខ្ញុំបានតម្រុយខ្លះ ។ ដោយឡែកបង រ័ត្ន គត់ ទៅនៅជាមួយនឹងខ្ញុំ ខ្ញុំការពារ ។ បន្ទាប់មក ចៅ សេង បក្សកុម្មុយនីស្តកម្ពុជារុញទៅឲ្យខ្ញុំ ខ្ញុំមិនបានធ្វើម៉េចកើតទេ គ្រាន់តែការពារដោយ ឲ្យម្ហូបអាហារ ហើយការរស់នៅសមរម្យ ។ ខ្ញុំស្តាយដែរ បើលោកគ្រូបានទៅ ហើយខ្ញុំបានដឹង ខ្ញុំពិតជា មិនអាចសុំគេឲ្យគាត់រួចជីវិតបានទេ ក៏ប៉ុន្តែគ្រាន់តែឲ្យគាត់បានរស់នៅដោយខ្ញុំបានឧបត្ថម្ភឲ្យអស់ចិត្តខ្ញុំ ជាការតបស្នងសងគុណគាត់ប៉ុណ្ណឹងឯង ។

ដូច្នេះហើយបានជាក្រោយមក ខ្ញុំសូមនិយាយឲ្យវែងទៅទៀត នៅឆ្នាំ១៩៩៣ វិទ្យុអាមេរិកវា ផ្សាយអំពីផលិតកម្មឆ្លងដែន ប្រធានអាផលិតកម្មឆ្លងដែននេះ ឈ្មោះ ធីង សុន ។ ខ្ញុំឮអាំងខេន ឃោសនា ពី ធីង សុន ខ្ញុំភ្ញាក់ ខ្ញុំថា ចំ! ភីង តុន ណាធ្លាក់ទៅធ្វើមេភ្លេងម៉េចអ៊ីចឹង ខ្ញុំតាមដានស្តាប់ជាលើកទីពីរ អ៎! ធីន សុន ទេ ។ ដល់មកអយ្យការយោធា គេសួរខ្ញុំ "ថាលោកគ្រូ ភីង តុន ហ្នឹងផ្ទះខ្ញុំអត់? នេះបង ការ សារុត្ត នេះប្រាប់ថាទៅ ខ្ញុំថាអត់ គាត់ថា អេ៎! អ៊ុំង ប៊ិច យកឆ្អឹងលោកគ្រូ ទៅឲ្យកូនចៅខ្ញុំថា អឺ! អ៊ុំង ប៊ិច បោកទៅយកលុយកូនចៅ ។

ដល់ ហ្វ្រង់ស្វ័រ រូ មកធ្វើជាមេធាវីខ្ញុំទៀត ខ្ញុំនៅតែនិយាយអ៊ីចឹង ឥឡូវឲ្យកូនចៅក្រុមលោកគ្រូ យកអាឆ្អឹងហ្នឹងទៅធ្វើ *អាន់ណាលីស* ADN ឲ្យច្បាស់ ។ ដល់មែនទែន ពេលដែលខ្ញុំទៅជើងឯង ឃើញ រូបថតចប់ ។ ខ្ញុំស្តុតបណ្តោយ ចប់អត់ប្រកែកទៀតកើតទេ ។

ដល់ពេលដែលអ្នកស្រី ភីង ហ្គុតស៊ុនថារី ឲ្យឯកសារទៅខ្ញុំ បានឲ្យខ្ញុំឃើញ កាលបរិច្ឆេទមានបី ខុសគ្នា មិនមែនតែពីរទេ ។ ប៉ុន្តែ មួយទៀតមិនដឹងស្អី ខ្ញុំឮតែកាលបិរច្ឆេទបី ខុសគ្នាអ៊ីចឹង ហើយខ្ញុំ សន្និដ្ឋានទៀតថា បញ្ជីស-២១ ថ្ងៃខែមិនកំណត់ច្បាស់ទេ ។ ព្រោះលោកចៅក្រម ម៉ាកសែល ឡឺមុងដ៏

បានសួរមិត្ត ធី ហើយ ថាពេលខ្លះចូលទៅកន្លែងហ្នឹងសម្ងាត់ទៅ ដល់ក្រោយមកបានគាត់ដឹង គាត់ចុះថ្ងៃខែ ។ ដូច្នេះថ្ងៃខែអាចច្រឡំ មនុស្សមិនច្រឡំទេ ។ នេះខ្ញុំវិភាគអំពីថ្ងៃខែចូល ។ ក៏ប៉ុន្តែ ពេលនុ៎ង ខ្ញុំមិនបានដឹងថា បង ម៉ម ណៃ មានការទាក់ទងស្គាល់អ្នកបងច្បាស់លាស់ ស្គាល់លោក តាទុយ ច្បាស់លាស់ ។ ខ្ញុំអត់ដឹងទេ ទើបតែពេលសវនាការនេះ បានខ្ញុំដឹង ។ បានតែថា រឿងរ៉ាវវានៅកប់នៅឡើយទេ តើរឿងពិតវាយ៉ាងម៉េច?

សូមនិយាយដោយស្មោះត្រង់ចំពោះជនរងគ្រោះទាំងអស់ អ្នកដែលខ្ញុំចង់សងគុណនោះមានបី ។ ឥឡូវពីរនោះ គឺខ្ញុំសងគុណនៅតែមួយហ្នឹងឯងទេ ខ្ញុំផ្តោយ គឺលោកគ្រូ ភឹង តុន ហ្នឹងឯង ដែលខ្ញុំផ្តោយ។ ដូច្នេះ ដែលខ្ញុំខំនិយាយហ្នឹង គឺមិនបានសងគុណគាត់ឲ្យវាបានពេញចិត្ត ពេញថ្លើម បានប្រហែល ចៅសេង ឬបានប្រហែល វ័ត្ន គត់ តែប៉ុននុ៎ងទេ ។ ត្រង់ដែលបដិសេធ គឺអត់ទេ ដូច្នេះថ្ងៃខែ វានៅលើយើងពិភាក្សាគ្នាតទៅទៀត ។

[១៤:២៣:៤០]

រឿងបង ម៉ម ណៃ អាចដឹងច្បាស់ជាងគេ ។ អានេះវានៅលើស្មារតីរបស់បង ម៉ម ណៃ តើភ្ញាក់រឭកវាយការណ៍ជូនគ្រូទាំងអស់គ្នាថ្ងៃណា? ហើយដើម្បីយើងរកហេតុផលតទៅទៀត ។

ដូច្នេះពេលនេះ សូមអ្នកស្រីរក្សាទុកគោលជំហរខ្លួនឯងក្នុងបញ្ហាយល់ឃើញអំពីខ្ញុំទៅចុះ ហើយយើងនាំគ្នាតទៅទៀត រកតទៅទៀត ។ ហើយខ្ញុំសូមបញ្ជាក់ថា ខ្ញុំជឿជាក់ហើយថា អ្នកស្រីប្តឹងនេះគឺមិនមែនដោយគំនុំទេ ដូចក្នុងពាក្យបណ្តឹងរបស់អ្នកស្រីសរសេរអ៊ីចឹង ថាពាក្យបណ្តឹងរបស់ខ្ញុំមិនមែនកើតឡើងដោយគំនិតសងគំនុំ សងសឹកទេ តែឧក្រិដ្ឋកម្មនេះ គឺវាមិនត្រូវនៅស្ងាត់ស្ងៀមតទៅទៀត ហើយក៏មិនត្រូវផ្ទេរទម្លាក់ទៅលើអ្នកណាដែរ ហើយក៏មិនត្រូវផ្ទេរទៅលើរបបដែលមើលមិនឃើញអ្នកណាទេ ។ ដូច្នេះ ខ្ញុំជឿថាអត់មានប្រាថ្នាសងសឹកអីទេ គឺដើម្បីរកតែការពិត ។ ឥឡូវយើងទាំងអស់គ្នាឈរនៅមុខសភាពការណ៍មួយដែលមិនទាន់ឃើញការពិតច្បាស់នៅឡើយ ។ សូមអ្នកស្រីរក្សាការវិភាគរបស់អ្នកស្រីតទៅទៀតចុះ ខ្ញុំក៏ខិតខំឲ្យអស់សមត្ថភាពតទៅទៀតដើម្បីនឹងរៀបបង្ហាញការពិតជូន ។ ហ្នឹងខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ជាតទៅនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា តើមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ ។

**លោក សេង ប៊ុនឃាង៖**

អរគុណលោកប្រធាន ។ តំណាងអយ្យការមិនមានសំណួរអ្វីទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំទើបតែបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ដែលបានសួរ អម្បាញ់មិញនេះ ខ្ញុំមិនច្បាស់ប្រាកដថា ខ្ញុំយល់គ្រប់ចំណុចទាំងអស់ទេ គឺមានការបញ្ជាក់ឈ្មោះ ចៅ សេង ហើយលោកបាននិយាយថា ជននោះត្រូវបានបញ្ជូនទៅស-២១ ។ តើលោកចង់មានន័យថា បញ្ជូនមកលោក ឬក៏បញ្ជូនមក ស-២១?

ចំណុចមួយទៀត ខ្ញុំមិនប្រាកដថា ខ្ញុំយល់ច្បាស់ទេ ដែលលោកនិយាយថា លោកមានការព្រួយបារម្ភ ហើយមានបានយកចិត្តទុកដាក់ បានសងគុណទៅគាត់ ហើយចង់បញ្ជាក់ឲ្យច្បាស់ថា តើគាត់ទទួលបានម្ហូបអាហារគ្រប់គ្រាន់ដែរឬទេ? តើលោកចង់និយាយថាលក្ខខណ្ឌនៃការឃុំខ្លួននៅស-២១ ឬក៏តើការទទួលត្រឹមត្រូវលើអ្នកទោសណាម្នាក់ ដែលគោរពហ្នឹង គឺថាលោកមានសិទ្ធិមានអំណាចដែលអាចផ្តល់អំណាច ផ្តល់អាហារគ្រប់គ្រាន់ទៅឲ្យអ្នកទោសណាម្នាក់ដែលលោកចង់ផ្តល់ការតបស្នងសងគុណនោះដែរឬទេ?

**ជនជាប់ចោទ៖**

សូមអរគុណលោកចៅក្រម ដែលលើកសំណួរនេះឡើង ។ ចៅ សេង គាត់ជា*លីហ្សង់*-- គាត់ជាអ្នកបានបរិញ្ញាបត្រខាងចិត្តសាស្ត្រគរុកោសល្យ ។ ដំបូងមក ធ្វើជារដ្ឋលេខាធិការក្រសួងអប់រំជាតិ ។ នៅក្នុងករណីនេះហើយដែលយើងខ្ញុំនិយាយថា គាត់បាន-- ដែលខ្ញុំបាទបាននិយាយថា គាត់បានរៀបចំសិក្សាមធ្យមសិក្សាឆ្នាំ១៩៥៨ បានចាប់ផ្តើមបង្កបង្កើតវិទ្យាស្ថានជាតិគរុកោសល្យ ផ្នែកខាងត្បូង ហើយគាត់បានតទល់ជាមួយនឹង លន់ នល់ នៅក្នុងសមាជជាចំហ ។

ដល់ក្រោយមក ប៉ុល ពត បញ្ជាឲ្យគេចាប់ ចៅ សេង ទៅឲ្យ ស-២១ ហើយបានទាំងបញ្ជាថាឲ្យ ស-២១ ប្រែឈ្មោះ ចៅ សេង ទៀត កុំដាក់ក្នុងបញ្ជី ចៅ សេង ដាក់ថា ចិន ស្នួន ។ បញ្ជី ស-២១ នេះ មានឈ្មោះ ចិន ស្នួន ហៅ សាន ។ បណ្ឌិតគរុកោសល្យចិត្តសាស្ត្រនៅក្នុងហ្នឹង ។ ដូច្នេះ ចៅ សេង ពិតជាធ្លាក់ទៅដល់ស-២១ ហើយដល់ក្រោយពីគេសួរចម្លើយស្រួលបួល ខ្ញុំឲ្យគេរក្សាទុក ដោយឡែក

ជូនបាយទឹកគាត់សមរម្យ មានកន្លែងសម្រាកសមរម្យ ខ្ញុំមិនដឹងជាកន្លែងសម្រាកត្រង់ណាទេ ខ្ញុំអត់បានទៅមើលទេ គ្រាន់តែប្រាប់គេឲ្យធ្វើ ។ ហើយប៉ុន្មានថ្ងៃមុននេះ ខ្ញុំក៏បានបញ្ជាក់ថា យូរៗខ្ញុំទៅអើត ចៅ សេង ម្តង ម្តងនោះ ចៅ សេង គាត់ប្រាជ្ញពីរឿងបារាំងរបស់សម្តេចនរោត្តម សីហនុ មិនពូកែដូចបារាំងរបស់ស្តេច អារ៉ាប់ប៊ីសាអូឌីត នេះទេ ។ នេះខ្ញុំបានរឭករឿងនេះនៅក្នុងអង្គសវនាការ ដើម្បីបញ្ជាក់ថា ខ្ញុំបានឧបត្ថម្ភ ចៅ សេង តាមគោលគំនិតរបស់ខ្ញុំ ដែលចង់សងគុណគាត់ ។ ខ្ញុំបានឧបត្ថម្ភ រ័ត្ន គត់ តាមគោលគំនិតរបស់ខ្ញុំ ដែលចង់សងគុណគាត់ ឯចំណែកលោកគ្រូ ខ្ញុំអត់បានដឹង ខ្ញុំអត់បានឧបត្ថម្ភទេ ប៉ុន្តែដោយតារ៉ាន់តារ៉ែ អត់បាយ អត់ដឹង មិនដឹងជាអ្នកជេរ គាត់យ៉ាងម៉េច ស្អីយ៉ាងម៉េចទេ ខ្ញុំមិនដឹងទេ ។ ដូច្នេះហើយ ដែលខ្ញុំមានការក្តុកក្តួលខ្លាំង នេះខ្ញុំចង់និយាយប៉ុណ្ណេះ សូមគោរពជូនលោកចៅក្រម បើលោកនៅមានការឆ្ងល់អីទៀត សូមមេត្តាសួរបញ្ជាក់ដោយគោរព ។

[១៤:៣០:០៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើមានអ្វីកើតឡើងចំពោះ ចៅ សេង?

**ជនជាប់ចោទ៖**

លោកចៅក្រមជាទីគោរព! ខ្ញុំបានបញ្ជាក់យូរច្រើនដងហើយថា អ្នកណាដែលគេបញ្ជូនទៅស-២១ គេទុកជាខ្មាំង ។ ពាក្យថាខ្មាំងត្រូវតែកម្ទេច ។ ដល់ក្រោយមក ពូនួន និយាយឲ្យច្បាស់ឲ្យចំមុខទៅគាត់ដឹងខ្ញុំទុក ចៅ សេង គាត់បញ្ជាឲ្យខ្ញុំកម្ទេច ។ ដូច្នេះ ចៅសេង គឺខ្ញុំកម្ទេច ។ ឯចំណែកដុកទ័រ រ័ត្ន គត់ គេយកទៅកម្ទេចជាមួយ ទិព្វ ម៉ម នៅពេលដែលខ្ញុំសុំណាត ដល់ក្រោយមក ណាតប្រើមិត្ត ហ៊ី ឲ្យកម្ទេច ។ នេះគឺពិតជាកម្ទេចហើយ ចៅសេង ក៏ដោយ រ័ត្ន គត់ ក៏ដោយ ។ ហើយចំណែកលោកគ្រូវិញ ខ្ញុំមិនទាន់ជាប៊ានថាយ៉ាងម៉េចទេ ឬក៏គាត់ឈឺស្លាប់ ឬក៏គាត់ត្រូវគេយកទៅកម្ទេចដែរ ខ្ញុំអត់ដឹងទេ ។ នៅបញ្ហាច្របូកច្របល់ណាស់ក្នុងអារម្មណ៍ខ្ញុំ ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ្វីដែលលោកជម្រាបនេះគឺអ៊ីចេះ គឺថា លោកមិនមែនជាអ្នកបញ្ជាឲ្យសម្លាប់ចៅសេងទេ ឬក៏ជាលោក?

**ជនជាប់ចោទ៖**

សុំទោសលោកចៅក្រម ខ្ញុំនិយាយអំមិញនេះច្របូកច្របល់ពេលវេលា ។ ណាត បញ្ជាឲ្យគេ

កម្មេចដុកទ័រ វ័ត្ន គត់ និងអាំងគ្រីហ្សេ ទិព្វ ម៉ម ។ ឯចំណែក ខ្ញុំទទួលបញ្ជាពី នួន ជា ឲ្យកម្ទេច ចៅ សេង ខ្ញុំបញ្ជាឲ្យគេកម្ទេចតាមបញ្ជា ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមិនមានសំណួរបន្ថែមទៀតទេលោកប្រធានសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាចអង្គុយបាន ។ អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមានសូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

មេធាវីការពារក្តីពុំមានសំណួរសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ លោកប្រធាន ។ សូមអរគុណ ។

[១៤:៣៣:១៤]

**ប្រធានអង្គជំនុំ៖**

ជាបន្ត អង្គជំនុំជម្រះផ្តល់ឱកាសទៅជនជាប់ចោទអាចឡើងធ្វើការកត់សម្គាល់ទៅនឹងសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបគឺ អ៊ឹម ស៊ុន្នី និង ភឹង ហ្គុតស៊ុនថារី ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបដល់ជនជាប់ចោទផងដែរ ថានេះជាសិទ្ធិជនជាប់ចោទដែលអង្គជំនុំជម្រះផ្តល់ឱកាសក្នុងការធ្វើការកត់សម្គាល់ហើយបានន័យថា ជនជាប់ចោទអាចធ្វើការកត់សម្គាល់ក៏បាន មិនធ្វើក៏បានដែរនេះជាសិទ្ធិ ។

សូមអញ្ជើញ ប្រសិនបើលោកមានបំណងក្នុងការធ្វើការកត់សម្គាល់ទៅលើសេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ម្តាយកូនដែលមានជនរងគ្រោះនៅទួលស្លែងគឺលោក ភឹង តុន ។

**ជនជាប់ចោទ៖**

ខ្ញុំសូមធ្វើការកត់សម្គាល់យ៉ាងខ្លីដូចតទៅ ។

សេចក្តីថ្លែងការណ៍របស់អ្នកបង ក៏ដូចជាសេចក្តីថ្លែង ការណ៍របស់អ្នកស្រី ភឹង ហ្គុតស៊ុនថារី ដែរ។ ខ្ញុំសូមយល់ស្របជាមូលដ្ឋាន ។ ការដែលអ្នកស្រីក៏ដូច អ្នកបងដែលមិនទាន់អស់ចិត្ត ខ្ញុំនឹងខំពុះពារតទៅទៀត ដើម្បីជួយឲ្យឃើញការពិតតើវាយ៉ាងម៉េច ដោយឥតប្រកែកទេ ។ លទ្ធភាពដែលខ្ញុំធ្វើបានតទៅទៀតដើម្បីអ្នកបង ហើយនិងអ្នកស្រីលើកសំណូមពរឡើងខ្ញុំនឹងជូនតាមលទ្ធភាពដែលខ្ញុំអាចមាន

តទៅទៀត ។ ខ្ញុំអត់ប្រកែកទេ ។ ខ្ញុំសូមបញ្ចប់ត្រឹមនេះ ។

**ប្រធានអង្គជំនុំ៖**

នីតិវិធីសវនាការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម ស៊ុន្ធី ហើយនិង ភឹង ហ្គុតស៊ុនថារី ឃើញថាដល់ទីបញ្ចប់ហើយ ។ លោកស្រីអាចត្រឡប់ទៅកាន់ទីកន្លែងសម្រាប់រៀបចំទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលសវនាការនេះ ។

ជាកិច្ចបន្ត អង្គជំនុំជម្រះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង វ៉ាន់ឌី អញ្ជើញមកកាន់កៅអីដែលបានរៀបចំទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ។ អញ្ជើញលោកស្រីមេធាវី ។

[១៤:៣៧:៣០]

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន មុនពេលដែលយើងចាប់ផ្តើមជាមួយនឹងលោក ស៊ាង វ៉ាន់ឌី ដែលជាដើមបណ្តឹងរដ្ឋប្បវេណីខ្ញុំសូមការបំភ្លឺមួយចំនួនអំពីដំណើរការនីតិវិធីរបស់យើង ។ តាមអ្វីដែលខ្ញុំយល់សវនាការយើងនឹងបញ្ចប់នៅម៉ោងបីនិងសាមសិប ហើយនៅពេលនេះតើលោកប្រធានចង់ឈប់សម្រាកសិន ឬក៏យើងយើងត្រូវដឹងថាតើយើងអាចបន្តនីតិវិធីត្រឹមកម្រិតណាដោយសារតែខ្ញុំបានស្តាប់លោកប្រធាន កាលពីមុនឈប់សម្រាកនោះថាយើងនឹងបញ្ចប់នៅមុនម៉ោងបីសាមសិបនាទី ។

**ប្រធានអង្គជំនុំ៖**

ដោយហេតុថាអង្គជំនុំជម្រះបានសម្រេចថា ធ្វើសវនាការរហូតដល់ម៉ោងបីនិងសាមសិបនាទីដោយហេតុមូលហេតុនេះហើយទើបអង្គជំនុំជម្រះមិនសម្រេចថា មិនសម្រាកទេ គឺដំណើរការនឹងប្រព្រឹត្តទៅរហូតដល់ម៉ោងបីនិងសាមសិបនាទីទើបសម្រាកតែម្តង ដើម្បីទុកឱកាសជូនអ្នកបច្ចេកទេសព័ត៌មានវិទ្យា ដើម្បីធ្វើការត្រួតពិនិត្យ និងការសាកល្បងអំពីប្រព័ន្ធភ្ជាប់ទៅនឹង*វីដេអូខនហ្វើរិន*នៅកម្ពុជា និងប្រទេសបារាំង ដើម្បីដំណើរការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលគ្រោងធ្វើពីចម្ងាយនៅរសៀលថ្ងៃស្អែក ។

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តី លោក ស៊ាង វ៉ាន់ឌី ។ តើលោកឈ្មោះ ស៊ាង វ៉ាន់ឌី អ៊ីចឹងពិតមែនទេ?

**ឆ៖** បាទ, លោកប្រធានពិតប្រាកដ ។

**ស៖** លោក ស៊ាង វ៉ាន់ឌី ចេះអក្សរទេ?

**ឆ៖** បាទ, ចេះ ។

**ស៖** ត្រកូល ស៊ាង ហ្នឹងសរសេរយ៉ាងដូចម្ដេច? លោកអាចប្រកបត្រកូល ស៊ាង បានដែរឬទេ?

**ឆ៖** បាទ, ស៊ាង គឺ សត្រីសាប់ដាក់ស្រះអា និង ង (ស៊ាង)។

**ស៖** តើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** បាទ លោកប្រធាន ខ្ញុំអាយុ ៦៣ឆ្នាំ ។

**ស៖** ទីកន្លែងកំណើតរបស់លោកនៅឯណាដែរ?

**ឆ៖** បាទ លោកប្រធាន ភូមិកំណើតខ្ញុំគឺនៅ ភូមិខ្សាច់ទប់ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

**ស៖** ចុះសព្វនេះ តើលោកមានទីលំនៅ នៅទីណាដែរ? ហើយប្រកបមុខរបរអ្វីដែរ?

**ឆ៖** បាទ, លោកប្រធាន! សព្វថ្ងៃ គឺនៅក្នុងភូមិស្រុកកំណើតដដែល ហើយកន្លងមកគឺធ្វើគ្រូបង្រៀនសាលាបឋមសិក្សា ប៉ុន្តែបច្ចុប្បន្នចូលនិវត្តន៍ ។

**ស៖** ឪពុកបង្កើតរបស់លោកគាត់ឈ្មោះអ្វី? ហើយសព្វថ្ងៃនេះ តើគាត់នៅរស់ ឬក៏គាត់ទទួលមរណភាពហើយ?

**ឆ៖** បាទ, លោកប្រធាន ឪពុកខ្ញុំឈ្មោះ ស៊ាង ផន សព្វថ្ងៃស្លាប់ ។

**ស៖** ចុះម្ដាយរបស់លោកវិញ គាត់ឈ្មោះអ្វីដែរ? ហើយសព្វថ្ងៃនេះគាត់នៅរស់ ឬក៏គាត់ទទួលមរណភាពហើយ?

**ឆ៖** បាទ, លោកប្រធានម្ដាយឈ្មោះ ខាត់ យិន ស្លាប់ដែរ ។

**ស៖** លោក វ៉ាន់ឌី តើលោកមានបងប្អូនប៉ុន្មាននាក់? ចូរលោករៀបរាប់ឈ្មោះ បងប្អូនបង្កើតរបស់លោក ។

**ឆ៖** បាទ,លោកប្រធាន! ខ្ញុំបាទមានបងប្អូនប្រាំបួននាក់ ប្រុសប្រាំមួយ ស្រីបី ។ ខ្ញុំទីមួយ ។ ទីពីរគឺឈ្មោះ ស៊ាង ផាត ។ ទីបីគឺឈ្មោះ ស៊ាង ផុន ។ ទីបួនគឺឈ្មោះ ស៊ាង ឆុន ។ ទីប្រាំគឺឈ្មោះ ស៊ាង យឿន ។ ទីប្រាំមួយគឺឈ្មោះ ស៊ាង ម៉ៅ ។ ទីប្រាំពីរគឺឈ្មោះ ស៊ាង មីន ។ ទីប្រាំបីគឺឈ្មោះ ស៊ាង តឿ ។ ទីប្រាំបួន គឺឈ្មោះ ស៊ាង ឡោក ។

**ប្រធានអង្គជំនុំ៖**

មេធាវី ស្ទួតហ្សីនស្គី តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនមេធាវីដើម្បីធ្វើសេចក្ដីថ្លែងការណ៍សង្ខេបបង្ហាញអំពីអត្តសញ្ញាណរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ហេតុដែលនាំឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះប្ដឹងទាមទារសំណង ទំនាក់ទំនងនៃការប្ដឹងទាមទាររបស់ ដើមបណ្ដឹងរដ្ឋប្បវេណីទៅលើបទឧក្រិដ្ឋដែលចោទប្រកាន់ទៅលើជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធទៅនឹងអង្គហេតុកើតឡើងនៅមន្ទីរសន្តិសុខស-២១ ក្នុងអំឡុងពេលកម្ពុជាប្រជាធិប-តេយ្យ ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ព្រមទាំងភស្តុតាងនានាដែលដើម្បីគាំទ្រដល់ការប្ដឹងទាមទារសំណងរបស់អ្នកដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ។ សូមអញ្ជើញ ។

[១៤:៤៣:៤៧]

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ លោក ស៊ាង វ៉ាន់ឌី គឺខ្ញុំសូមជូនព័ត៌មានដូចតទៅ គឺវាពាក់ព័ន្ធទៅនឹងរឿងក្ដីចំពោះមុខអង្គសវនាការរបស់យើង ។ លោក ស៊ាង វ៉ាន់ឌី បានបាត់បង់យ៉ាងហោចណាស់ប្អូនរបស់គាត់មួយរូបគឺ ស៊ាង ផុន នៅមន្ទីរស-២១ ។ នៅពេលថ្មីៗនេះគឺលោកគាត់បានដឹងថា ប្អូនរបស់គាត់ជាប់គុកនៅស-២១ ហើយប្អូនរបស់គាត់បានផ្ដល់ចម្លើយសារភាព ។ ហើយចម្លើយសារភាពនោះគឺវាបញ្ជាក់ថា ប្អូនរបស់គាត់ត្រូវបានគេសម្លាប់ ។ ប្អូនមួយទៀតរបស់ លោក ស៊ាង វ៉ាន់ឌី គឺស៊ាង ផាត បានបាត់ខ្លួនតាំងពីពេលនោះមក ។ ហើយចំពោះជោគវាសនារបស់លោក ស៊ាង ផាត គឺមិនដឹងនោះទេ ។

លោក ស៊ាង វ៉ាន់ឌី គឺលោកនឹងផ្ដោតរៀបរាប់អំពីការឈឺចាប់និងទុក្ខសោករបស់គាត់ ក្នុងរយៈពេលសាមសិបឆ្នាំ ពាក់ព័ន្ធទៅនឹងប្អូនរបស់គាត់ ស៊ាង ផុន ដែលចាត់ទុកថា ប្អូន ស៊ាង ផុន នេះត្រូវបានបាត់ខ្លួន ហើយក៏មិនដឹងអំពីជោគវាសនារបស់ប្អូនរបស់គាត់ ។ ដូច្នេះ ទាំងអស់នេះគឺជាការធ្វើសេចក្ដីថ្លែងការណ៍របស់ ស៊ាង វ៉ាន់ឌី ។ មូលហេតុដែលតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក គឺដើម្បីសូមស្វែងរកយុត្តិធម៌ ហើយនិងសូមទាមទារសំណង ។ លោក ស៊ាង វ៉ាន់ឌី ទោះបីជាយ៉ាងនោះក៏ដោយ គឺគាត់ទុកសិទ្ធិទាមទារសំណងជាអ្នកទាមទារជំនួស ។ ហើយមូលហេតុមួយទៀត ក្នុងការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយចូលខ្លួនចំពោះមុខសវនាការ គឺរំឭកដល់វិញ្ញាណក្ខន្ធរបស់ប្អូនប្រុសរបស់

គាត់ គឺ ស៊ាង ផុន ។

សេចក្តីថ្លែងការណ៍របស់ ស៊ាង វ៉ាន់ឌី នឹងគាំទ្រដោយឯកសារមួយ គឺឯកសារនេះបានដាក់នៅក្នុងសំណុំរឿងរួចហើយ គឺជាចម្លើយសារភាពរបស់ប្អូនរបស់គាត់ឈ្មោះ ស៊ាង ផុន ដែលលេខ ERN អង់គ្លេសមិនទាន់បានជូនដំណឹងកាលពីម្សិលមិននោះទេ ។ ហើយនៅពេលនេះ វាគ្រាន់តែជាសេចក្តីសង្ខេបនៃចម្លើយសារភាពនោះប៉ុណ្ណោះនៅក្នុងសំណុំរឿង ។ ខ្ញុំធ្វើការកត់សម្គាល់តូចមួយនៅក្នុងទំព័រទីមួយនៃចម្លើយសារភាពនៃមន្ទីរស-២១ យើងឃើញមានភាពខុសគ្នាបន្តិចអំពីឈ្មោះនោះ គឺវាសរសេរ SIENG តាមពិតឈ្មោះនោះគួរតែសរសេរ SEANG ដែលវាត្រូវនឹងឈ្មោះនាពេលបច្ចុប្បន្ន ។ ហើយលោក ស៊ាង វ៉ាន់ឌី អាចស្គាល់នូវចម្លើយសារភាពនោះថា ពិតជាឆ្លើយដោយប្អូនប្រុសរបស់លោកពិតមែន ។ ហើយយើងយោងទៅលើឯកសារនេះ ខ្ញុំនឹងផ្តល់លេខយោង គឺមានលេខ ERN ជាភាសាខ្មែរ គឺ 00004558 រហូតដល់លេខ 00004777 ។ ហើយមានលេខ E1.1 ហើយលេខ ERN 00063590 ដល់លេខ 00363605 ហើយក៏យើងឃើញមានចំណារនៅក្នុងទំព័រទី១ ដែលមានចារនៅលើចម្លើយសារភាព ។ ហើយយើងនឹងយោងទៅលើឯកសារនោះ នៅពេលដែលយើងនិយាយអំពីចំណុចនុ៎ង គឺលេខ ERN 00173881 ដល់លេខ 82 ហើយចំពោះភាសាខ្មែរ គឺដល់លេខ 00221765 ។

ហើយខ្ញុំជូនក៏ចង់ជម្រាបជូនអង្គសវនាការផងដែរ យើងខ្ញុំចង់ដំណើរការនីតិវិធីរបស់យើងខ្ញុំដូចតទៅ៖

[១៤:៤៩:១៧]

លោក ស៊ាង វ៉ាន់ឌី បានរៀបចំនូវសេចក្តីថ្លែងការណ៍របស់លោក ហើយលោកនឹងធ្វើការថ្លែងជូនអង្គសវនាការ ហើយបន្ទាប់មកខ្ញុំនឹងតាំងសំណួរមួយចំនួនជូនលោក ហើយនៅទីបញ្ចប់លោកនឹងមានសំណួរចំនួនបួន ដើម្បីសួរជនជាប់ចោទតាមរយៈលោកប្រធាន ។ ដូច្នេះ នៅពេលនេះ គឺខ្ញុំសូមអនុញ្ញាតពីលោកប្រធានហើយផ្តល់ទុកវេទិកានេះទុកឲ្យលោក ស៊ាង វ៉ាន់ឌី ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោក ស៊ាង វ៉ាន់ឌី ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីថ្លែងការណ៍រៀបរាប់ជូនដល់អង្គសវនាការអំពីហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលមានការប៉ះពាល់ចំពោះ

លោកនៅក្នុងអំឡុងពេលនៃការបង្កើតនិងប្រតិបត្តិការមន្ទីរសន្តិសុខស-២១ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ៧៩ ដែលនាំឲ្យលោកសម្រេចចិត្តក្នុងការដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណង និងអំពីព្យសនកម្មដែលមានចំពោះរូបលោក ជាអាទិ៍ការខូចខាតសម្ភារៈផ្លូវចិត្ត និងជាផលប្រយោជន៍ដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតឡើងពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ន ។ សូមអញ្ជើញ ។

**លោក ស៊ាង វ៉ាន់ឌី៖**

បាទ, សូមអរគុណលោកប្រធាន ។ ខ្ញុំបានសូមរាយការណ៍ក្នុងសវនាការអំពីជីវប្រវត្តរបស់ក្រុមគ្រួសារខ្ញុំ ដែលបានរងទុក្ខវេទនាជាងសាមសិបឆ្នាំ ហើយពិសេស គឺការទទួលឧក្រិដ្ឋកម្មរបស់ប្អូនខ្ញុំ ។

គ្រួសារឪពុកម្តាយខ្ញុំបាទជាកសិករក្រីក្រធ្វើស្រែ និងស៊ីឈ្នួលគេកាប់ឧសឡផ្សងពីសង្គមរាស្ត្រនិយម ដើម្បីបំពេញជីវភាពក្នុងគ្រួសារ ។ នាសម័យនោះ ខ្ញុំបាទ និងប្អូនខ្ញុំឈ្មោះ ស៊ាង ផុន បានរៀនខ្លះៗកន្លងមក ។ ខ្ញុំលើកយកប្រវត្តិរបស់ប្អូនខ្ញុំឈ្មោះ ស៊ាង ផុន មុនពេលចូលបដិវត្តន៍មកបង្ហាញ៖

ឈ្មោះ ស៊ាង ផុន ភេទប្រុស ជាប្អូនទីពីរ កើតនៅឆ្នាំមមី ត្រូវនឹងឆ្នាំ១៩៥៣ នៅភូមិខ្សាច់ទុក ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។ ពីសង្គមបានរៀនត្រឹមថ្នាក់ ៨ចាស់ នៅសាលាបឋមសិក្សាភូមិកែងកំពង់ដរ ក្នុងឃុំតែមួយ ដោយរស់នៅជាមួយឪពុកមាឈ្មោះ គាវ វួច ឬ ស៊ាង វួច ក្នុងភូមិកែងកំពង់ដរ ។ ប្អូននេះវាមានអត្តចរិតស្លូតបូតស្មោះត្រង់ សុភាពរាបសា គោរពឪពុកម្តាយ គោរពចាស់ទុំ ចេះស្រឡាញ់បងប្អូន ចេះជួយការងារក្នុងគ្រួសារ ទឹកចិត្តម៉ឺងម៉ាត់នៅក្នុងគ្រួសារ ហើយក៏ជាប្អូនដែលធំជាងគេអាចជំនួសដៃជើងឪពុកម្តាយបាន ។

[១៤:៥៣:២០]

ឯប្អូនម្នាក់ទៀត ឈ្មោះ ស៊ាង ផាត ភេទប្រុស កើតនៅឆ្នាំថោះ ត្រូវនឹងឆ្នាំ១៩៥០ ជាប្អូនទីមួយ។ ប៉ុន្តែ នៅឆ្នាំ១៩៧១ ប្អូនរូបនេះបានបួសជាសង្ឃក្នុងវត្តពោធិ៍អណ្តែតនៅក្នុងភូមិឃុំស្រុកកំណើតរបស់ខ្លួន ។ លុះដល់ឆ្នាំ៧២ ដោយមានអង្គការរណៈសិរ្សរួបរួមជាតិ ដោយមានសម្តេចព្រះបាទនរោត្តម សីហនុ ជាប្រធាន បានប្រកាសតាមវិទ្យុឲ្យបងប្អូនទាំងអស់រួបរួមគ្នាចូលព្រៃម៉ាគី ដើម្បីរំដោះជាតិពីរបបគ្រប់គ្រងដោយ លន់ នល់ ។ សូមបញ្ជាក់នៅឆ្នាំ១៩៧០ ក្រោយបាតុកម្មភូមិឃុំស្រុកខេត្តរបស់ខ្ញុំបាទ គឺជាតំបន់រំដោះ គឺជាតំបន់ដែលខ្មែរក្រហមគ្រប់គ្រង ។ ត្រង់នេះ ខ្ញុំសូមបញ្ជាក់ពីឆ្នាំ៧០ បន្តិចក្រោយរដ្ឋប្រហារ ហើយក្នុងនាមជាតំបន់រំដោះក្រោយការប្រកាសរបស់សម្តេចព្រះបាទ សីហនុ ខ្ញុំបាទ

ក៏បានចូលធ្វើឈ្លបក្នុងភូមិឃុំ ។ ក្រោយមកទៀតនៅឆ្នាំ៧២ អង្គការក៏តម្រូវឲ្យខ្ញុំបាទទៅនៅអង្គភាពរៀនថតរូប ផ្ដើរូប ។ លុះដល់ឆ្នាំ៧៣ អង្គការក៏បាននៅក្នុងអង្គភាពបានធ្វើស្រែចម្ការ ដើម្បីឧបត្ថម្ភក្នុងអង្គភាព ។

លុះដល់ក្រោយ១៧ មេសា ១៩៧៥ ថ្នាក់លើបានប្រមូលកម្មាភិបាល ដែលតស៊ូនៅភាគខាងជើងវៀតណាម ដោយចូលរួមជាមួយ ប៉ុល ពត ដែលក្នុងនាមទទួលខុសត្រូវក្នុងអង្គភាពនោះ ក៏ប្រមូលយកទៅភ្នំពេញអស់ ។ ឯពួកខ្ញុំបាទ ដែលជាយុទ្ធជនធម្មតា ក៏អង្គការតម្រូវឲ្យមកនៅអង្គភាពនេសាទតំបន់៤២ ក្នុងឃុំខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមវិញ ក្នុងនាមលត់ដំខ្លួន ។

ខ្ញុំនិយាយសាដើមឡើងវិញនៅក្នុងពេលដែលខ្ញុំចូលជួរ ពេលខ្ញុំបានរៀបចេញដំណើរមកចូលជួរបដិវត្តន៍ ឪពុកម្ដាយខ្ញុំ និងប្អូនៗ មិនចង់ឲ្យខ្ញុំបែកទេ ។ ប៉ុន្ដែ ឪពុកម្ដាយខ្ញុំបាទ បានណែនាំនឹងផ្ដែផ្ដាំខ្ញុំថា “កូនទៅត្រង់ណាត្រូវប្រព្រឹត្តតែអំពើល្អ ចេះគោរពចាស់ទុំ ចេះជួយគ្នា ចេះរាប់អានមិត្តភក្តិឲ្យបានល្អជានិច្ច ដូចពាក្យស្លោកពោលថា “នៅផ្ទះទីទៃ ទៅព្រៃម្ដាយតែមួយ” ។ រីឯប្អូនខ្ញុំតូចៗវិញ ក៏វាមកតោងដៃ តោងជើងខ្ញុំទាំងទឹកមុខក្រៀមក្រំ ខ្លះយំខ្សឹកខ្សួលហាក់បីដូចជាមិនចង់ឲ្យខ្ញុំបែកចេញពីវា ។ ខ្ញុំបាទបានផ្ដែផ្ដាំប្អូនវិញថា ឲ្យចេះស្រឡាញ់គ្នា កុំឈ្លោះគ្នា ពិសេសគឺប្អូនទីពីរ ព្រោះប្អូនទីមួយទៅបួសហើយ ។ ដូច្នេះ នៅប្អូនទីពីរ ស៊ាង ផុន តែម្ដង ដែលធំជាងគេ គឺត្រូវមើលថែទាំប្អូនឲ្យបានល្អ ជួយធ្វើការជំនួសពុកម៉ែ ព្រោះពុកម៉ែគាត់កាន់តែចាស់ៗអស់ហើយ ។ ប្អូនទីពីរនេះ ក៏ទទួលនូវការផ្ដែផ្ដាំពីខ្ញុំទាំងទឹកមុខក្រៀមក្រំ ។ លុះមកដល់ឆ្នាំ៧៣ ដោយអង្គការតម្រូវប្រមូលយុវជន យុវនារី ធ្វើទ័ព ប្អូនខ្ញុំម្នាក់ដែលនៅបួសជាសង្ឃក៏ត្រូវអង្គការផ្សឹកវិញទាំងបង្ខំ ហើយបញ្ជូនប្អូនទាំងទីមួយ ទាំងទីពីរ នេះមកធ្វើទ័ពទុកឲ្យពុកម៉ែខ្ញុំ ដែលចាស់ៗគ្រប់គ្រងចិញ្ចឹមក្នុងគ្រួសារបន្តទាំងវេទនា ។

[១៤:៥៩:១២]

បន្តមក នៅក្រោយថ្ងៃទី១៧ មេសា ១៩៧៥ តាមសម្ដីឪពុកខ្ញុំបាទប្រាប់ ពេលខ្ញុំមកលេងផ្ទះខ្ញុំមិនបានចាំឆ្នាំទេ គាត់ថាប្អូនទាំងពីរនាក់នេះ បានមកលេងផ្ទះដែរ ហើយពួកគាត់ក៏បានប្រាប់អំពីការធ្វើទ័ព ប៉ុន្ដែគាត់មិនចាំថានៅកងណាជាកងណាដែរ ។ លុះមកដល់ថ្ងៃ៧ មករា ១៩៧៩ កូនចៅអ្នកស្រុកទាំងឡាយដែលបានទៅចូលជួរក្នុងរបបខ្មែរក្រហម ក៏វិលត្រឡប់មកផ្ទះរកឪពុកម្ដាយ រកបងប្អូនជាគ្រួសារបន្តបន្ទាប់ ។

ចំណែកប្អូនខ្ញុំទាំងពីរនាក់វិញ គឺគ្មានដំណឹងអ្វីសោះ ធ្វើឲ្យក្រុមគ្រួសារខ្ញុំទន្ទឹងមើលផ្លូវ និងព្រួយ

បារម្ភជានិច្ចពីវាសនារបស់ប្អូន ព្រោះនៅក្នុងរបបខ្មែរក្រហមនោះ ឮតែចាប់កាប់សម្លាប់តាមខ្សែជាហូរហែ ។ ក្រោយមកនៅដើមទសវត្សឆ្នាំ៨០ មានឈ្មោះ ឯម សៀត ជាកូនអ្នកស្រុកនៅភូមិផងរបងជាមួយ បានមកដល់ផ្ទះ ហើយធ្លាប់ធ្វើទ័ពជាមួយ-- ធ្លាប់ធ្វើទ័ពបានត្រឡប់មកផ្ទះវិញ សព្វថ្ងៃគាត់មានអាយុ៦១ឆ្នាំ ប៉ុន្តែអាពាធ បានប្រាប់កាលណោះថា គាត់បានឃើញសន្តិសុខ ហៅប្អូនឈ្មោះ ស៊ាង ផាត យកទៅបាត់ ហើយពុំឃើញមកវិញរហូតមក ។

**ប្រធានអង្គជំនុំ៖**

ម៉ោងសម្រាក-- ។

មន្ត្រីខាងសោតទស្សន៍ ដើម្បីឲ្យគាត់រៀបចំប្តូរនូវ *ឌីវីឌី* ពីព្រោះអស់ មន្ត្រីខាងសោតទស្សន៍រៀបចំចាត់ចែងផ្លាស់ប្តូរ ឌីវីឌី ហើយពេលរួចពេលណា គឺផ្តល់ព័ត៌មានមកឲ្យយើង ។

លោក ស៊ាង វ៉ាន់ឌី អាចអញ្ជើញថ្លែងការណ៍បន្តទៀត ។

**លោក ស៊ាង វ៉ាន់ឌី៖**

បាទ, សូមអរគុណលោកប្រធាន ។

ខណៈនោះក្រុមគ្រួសារឪពុកម្តាយខ្ញុំ ព្រមទាំងខ្ញុំ មានការតក់ស្លុតអស់សង្ឃឹមថា ប្អូនមុខជាគេសម្លាប់ តាមខ្សែប្រាកដ ក៏បានមូលមតិគ្នាធ្វើបុណ្យឧទ្ទិសកុសលជូនប្អូនតាមលក្ខណៈប្រពៃណីខ្មែរ ។ កាលណោះពុំទាន់មានលោកសង្ឃត្រឹមត្រូវទេ មានតែចាស់ៗដែលចេះធម៌អាចារ្យ បួនប្រាំនាក់ ហើយថែមទាំងមិនមានលុយចាយផង គឺប្រើតែស្រូវ អង្ករ យកទៅដោះដូរជាសម្ភារៈសម្រាប់ធ្វើបុណ្យ ។ ហើយការធ្វើបុណ្យនោះ ឧទ្ទិសកុសលឲ្យប្អូនទាំងពីរ គឺធ្វើជារៀងរាល់ឆ្នាំ ពិសេសនៅពេលបុណ្យភ្ជុំបិណ្ឌ និងបុណ្យចូលឆ្នាំ ។ ការធ្វើបុណ្យនេះ គឺធ្វើទាំងសង្ឃឹមតិចណាស់ ពីព្រោះសម័យនោះឋិតនៅក្នុងខ្មែរក្រហមច្របូកច្របល់មិនទាន់ចូល គេហៅ ចូលភូមិនិវត្តន៍ មិនទាន់ទេ ។ អ៊ីចឹងអាការសង្ឃឹងថា រស់ គឺនៅតិច អាការស្លាប់ហ្នឹង គឺអស់ អស់ច្រើន អ៊ីចឹងចេះតែធ្វើបុណ្យបាទ សូមជម្រាប ។ ចំពោះឪពុកម្តាយខ្ញុំ ដែលគាត់ចាស់ៗ បានអស់សង្ឃឹមក្នុងការបាត់កូន និងបានដឹងក្នុងរបបឃោរឃៅ ធ្វើឲ្យពួកគាត់កើតទុក្ខសង្រេងរហូតដល់មានជំងឺប្រចាំកាយទាំងអស់គ្នា ។ ហើយពួកគាត់ ក៏បានទទួលអនិច្ចកម្មជាបន្តបន្ទាប់ ។

[១៥:០៥:១៧]

លុះដល់ចុងឆ្នាំ២០០៧ ឬដើមឆ្នាំ២០០៨ មានឈ្មោះ ងឹម អុន ជាអនុភូមិរការធំ ក្នុងឃុំជាមួយ

គ្នាបានយកទស្សនាវដ្ដីស្វែងរកការពិតមកបង្ហាញខ្ញុំបាទ ប៉ុន្តែខ្ញុំបាទពុំបានចាប់អារម្មណ៍នឹងលេខឆ្នាំចេញរបស់ទស្សនាវដ្ដីនោះទេ ។ បានយកមកបង្ហាញខ្ញុំ ខ្ញុំបាទក៏ឃើញឈ្មោះ ស៊ាង ផុន ភេទប្រុស រស់នៅភូមិសន្ទុក ឃុំជ្រោយបន្ទាយ ស្រុកព្រៃកប្រសព្វ ខេត្តក្រចេះ មានអាយុ២៥ឆ្នាំ ត្រូវគេចាប់ខ្លួនកាលពីថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៧ ។ ពេលខ្ញុំអានចប់ ខ្ញុំបាទតក់ស្លុតយ៉ាងខ្លាំង ទន់ដៃទន់ជើង ព្រោះខ្ញុំនឹកឃើញពីឆ្នាំ៨៣ ខ្ញុំបាននឹកឃើញ ខ្ញុំបានមកភ្នំពេញម្តង គឺវះភ្នែកឡើងបាយ ហើយបងប្អូនបាននាំខ្ញុំទៅអើតនៅសារមន្ទីរគុកទួលស្លែង ដើម្បី-- នៅគុកទួលស្លែងឃើញសំណល់ព្រឹត្តិការណ៍ទារុណកម្មជាក់លាក់យ៉ាងព្រៃផ្សៃបំផុត ។

ខ្ញុំបាទបានដំណឹងនេះ ក៏យកទៅប្រាប់ប្អូនៗទាំងអស់គ្នា ប្អូនៗក៏មានអារម្មណ៍សង្វេគឈឺចាប់បំផុតលើមហាសែនទារុណកម្មចំពោះប្អូន ស៊ាង ផុន ។ ម៉្យាងវិញទៀត អារម្មណ៍របស់ខ្ញុំដេកក៏ពុំស្វូវបាន មមីមមើមើលឃើញតែប្អូន ដង្ហោយហៅឲ្យគេឯងជួយ តែខ្ញុំពុំដឹងធ្វើដូចម្តេច ។ ក្នុងនេះធ្វើឲ្យអារម្មណ៍ខ្វល់ខ្វាយពន់ពេក ព្រោះមកពីពន់ពេក ។ ក្រោយមក ក៏មានទីប្រឹក្សាពលរដ្ឋក្នុងឃុំបានចុះផ្សព្វផ្សាយពីការរងទុក្ខវេទនា នៅសម័យរបបខ្មែរក្រហម និងបំផុសដល់បងប្អូនដែលរងគ្រោះដោយបាត់បង់ឪពុកម្តាយ ជីដូនជីតា បងប្អូនមីងមា នៅជំនាន់នោះឲ្យដាក់ពាក្យបណ្តឹងមកសាលាក្តីខ្មែរក្រហមតាមរយៈវិទ្យាស្ថានខ្មែរដើម្បីប្រជាធិបតេយ្យ ហៅកាត់ថា “ឃីត”។ ឃីត ក៏បញ្ជូនមកអង្គភាពជនរងគ្រោះ។ ទន្ទឹមនឹងនោះ ខ្ញុំបាទក៏បានដាក់ពាក្យបណ្តឹងនឹងគេ ហើយអង្គការ ឃីត បានហៅខ្ញុំបាទមកភ្នំពេញ ដើម្បីបំពេញសំណុំបែបបទបន្ថែម និងជូនខ្ញុំទៅរកឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងទៅសារមន្ទីរគុកទួលស្លែង ហើយក៏បានរកឃើញប្រាកដ ។

ពេលរកឃើញ គេសរសេរលើក្របស៊ីមីខាងក្រៅ ដាក់លេខរៀង៥៧៦ ឈ្មោះ ស៊ាង ផុន ហៅ ផា ឈ្មោះនេះ គឺ សៀង ផុន ហៅ ផា ជាជំនួយការវរសេនាតូច៧០១ ក្នុងវរសេនាធំ ៦០១ កងពល ១៧៤ ត្រូវចាប់ខ្លួនពីថ្ងៃទី០២ ខែ១០ ៧៧ ឯខាងក្នុងមានសេចក្តីកំណត់ហេតុពីរច្បាប់ ។ នៅក្នុងសេចក្តីកំណត់ហេតុនេះ ខាងក្រៅក៏សេរសេរឈ្មោះខុសដែរ ។ តែបើកមួយសន្លឹកពីរសន្លឹកទើបគេសរសេរឈ្មោះ ស៊ាង ផុន ហៅ ផា ត្រឹមត្រូវវិញ ។ អ្នកសួរចម្លើយមានបីនាក់ គឺឈ្មោះ មួយឈ្មោះ ខន ពីរឈ្មោះ ហេង បីឈ្មោះ ហុង ។ ធ្វើកំណត់នៅថ្ងៃទី២៨ ខែ១០ ឆ្នាំ៧៧ ហើយរាយការណ៍នៅថ្ងៃទី០៥ ខែ១១ ឆ្នាំ៧៧ ។

តាមការពិនិត្យទៅលើកំណត់ហេតុពីប្អូនខ្ញុំ គឺធ្វើឲ្យមានការពាក់ព័ន្ធរហូតដល់៣៤នាក់ផងដែរ ។

ការឃើញឯកសារជាក់លាក់យ៉ាងនេះ រឹតតែធ្វើឲ្យខ្ញុំមានការឈឺចាប់ខ្លោចផ្សាអាណោចអាធ័មយ៉ាងខ្លាំង និងធ្វើឲ្យខ្ញុំក្តុកក្តួល អួលដើមក ស្រក់ទឹកភ្នែក រកនិយាយមិនចេញ ។

[១៥:១០:១១]

បន្ទាប់មក ទើបខ្ញុំនិយាយស្តែងថា ពិតណាស់ឯកសារនេះ ប្អូនខ្ញុំពិតជាគេយកមកសម្លាប់នៅគុកទួលស្លែងប្រាកដ ។ ក្រោយពីបានចូលរួមនៅក្នុងសវនាការជាច្រើនសា ធ្វើឲ្យអារម្មណ៍របស់ខ្ញុំបានធូរស្រាលខ្លះៗ ដោយយល់ថា ខ្លួនបានរកយុត្តិធម៌ជូនប្អូន ក្នុងតុលាការខ្មែរក្រហម និងឧទ្ទិសឲ្យព្រលឹងប្អូនបានជ្រះស្រឡះ និងឈានទៅរកសុគតិភពដ៏ប្រសើរ ។

ប្អូន ផុន បងសង្ឃឹមថា ពេលនេះប្អូនមុខជាមកចាំស្តាំនៅក្នុងអង្គសវនាការមិនខាន ព្រោះពីល្ងាចមិញបងបានឧទ្ទិសហៅប្អូនឲ្យមកចាំស្តាប់ ។ ដូច្នេះ ពេលនេះប្អូនបានឃើញ និងឮស្រាប់ថា បងប្រឹងប្រែងខំរកយុត្តិធម៌ដោយអំពើឧក្រិដ្ឋកម្មមកលើជីវិតប្អូន ។ ហេតុនេះ សូមព្រលឹងប្អូនទទួលយកការស្ងប់ស្ងៀម និងទៅចាប់សុគតិភពដ៏ល្អប្រសើរចុះ ។ សូមអស់លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវី អ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មានឱកាសដើម្បីតាំងសំណួរ ប្រសិនបើមានសូមអញ្ជើញ ។

**សួរដោយលោកស្រី ស៊ីលឃើស្ទូត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសួរ លោក ស៊ាង វ៉ាន់ឌី សូមអរគុណច្រើន ចំពោះលោកដែលបានធ្វើសេចក្តីថ្លែងការណ៍ដ៏ពិស្តារ ។ ហើយខ្ញុំនឹងសួរសំណួរមួយចំនួនជូនលោក ។

**ស៖** តើលោកអាចរៀបរាប់បានដែរឬទេ ថាតើអារម្មណ៍របស់លោក ដែលលោកបានបាត់បង់សមាជិកគ្រួសារម្នាក់ ហើយទុកឲ្យក្រុមគ្រួសារនៅសល់ដោយគ្មាន ស៊ាង ផុន ហើយនិងម្នាក់ទៀតនោះ?

**ឆ៖** បាទ, ខ្ញុំសូមបញ្ជាក់ពីអារម្មណ៍របស់ខ្ញុំជាមួយប្អូន ។ ធម្មតា បងប្អូនតែងតែស្រលាញ់តែងតែជិតស្និតនឹងគ្នា ។ ដូច្នេះ កាលណាបាត់ប្អូនទាំងពីរនេះ ធ្វើឲ្យអារម្មណ៍ខ្ញុំស្រឡះដៃជើងៗ គ្មានអ្វីដូចថាវាក្នុងនាមបងប្អូនបែកគ្នា ព្រាត់ប្រាសគ្នា វាតឹងទ្រូង វាបាត់រូបភាពប្អូនអ៊ីចឹង ខ្លួនខ្ញុំវាដូចជា វាទន់ដៃទន់ជើង ដូចខ្ញុំលើកឡើងអ៊ីចឹងអារម្មណ៍ខ្ញុំវាដូចពិបាករហូតដល់ ឪពុកម្តាយខ្ញុំដែលជួបប្រទះនូវការបាត់កូនដូច្នេះ ។ អ៊ីចឹង គាត់ក៏មានជំងឺ ហើយអារម្មណ៍គាត់ធ្លាក់ដល់មានជម្ងឺរហូតដល់ទៅស្លាប់បន្តបន្ទាប់ ។

អ៊ីចឹងទុក្ខនេះ មហាទុក្ខខ្លាំងណាស់ចំពោះគ្រួសារខ្ញុំបាទ ។ ម៉្យាងទៀត ខ្ញុំជឿថា ខ្ញុំបានរកយុត្តិធម៌ឲ្យប្អូននេះ ក្នុងនាមជាប្អូនបង្កើត រកយុត្តិធម៌នេះ ខ្ញុំជឿជាក់ថា ព្រលឹងប្អូនមុខជាជឿលើខ្ញុំ ជឿជាក់លើខ្ញុំ ហើយប្អូនមុខតែស្ងប់ស្ងៀមនូវអារម្មណ៍ឈានទៅចាប់ភពថ្មីដ៏ល្អ ។

[១៥:១៥:00]

**ស៖** សូមអរគុណ ។ លោក ស៊ាង វ៉ាន់ឌី លោកបានស្តាប់ឮហើយនៅពេលដែលលោកចូលរួមនៅក្នុងសវនាការនេះ ហើយនិងពាក្យសម្តីរបស់ជនជាប់ចោទមួយចំនួន ។ តាមទស្សនៈរបស់លោកទាក់ទងទៅនឹងទុក្ខសោក តើលោកមានមតិយោបល់ដូចម្តេច អំពីការនិយាយពីរឿងការសូមអភ័យដែលលោកតែងតែបានឮពីជនជាប់ចោទនោះ?

**ឆ៖** បាទ, សូមអរគុណ ។ ខ្ញុំសូមឆ្លើយ រាល់សវនាការ រាល់ចូលសវនាការ ឃើញថាជនជាប់ចោទតែងតែសារភាពមុខមហាជនទាំងអស់ ។ គាត់សុខចិត្តសំពះនៅមុខកញ្ចក់ទូរទស្សន៍ ដើម្បីបង្ហាញនូវពិភពលោក ។ នេះក៏ជាចំណែកមួយធ្វើឲ្យអារម្មណ៍ខ្ញុំ ក៏ដូចជាបងប្អូនទាំងអស់គ្នាប្រហែលជាស្រាកស្រាន្តខ្លះក្នុងការសារភាពរបស់គាត់ ។ ប៉ុន្តែ មិនអាចលើកលែងទោសឲ្យបាន ដោយផ្អែកទៅលើតុលាការវិនិច្ឆ័យ ហើយទទួលតាមក្រិត្យច្បាប់រដ្ឋធម្មនុញ្ញនៃតុលាការ ដែលបានកាត់ទោស ។

**ស៖** តើលោក ស៊ាង វ៉ាន់ឌី លោកចង់បន្តទៅទៀត ឬក៏លោកចប់ហើយសំណួរអំមិញនោះ?

**ឆ៖** បាទ, ខ្ញុំដូចសុំបញ្ចប់ប៉ុណ្ណឹងចោះ ។

**លោកស្រី ស៊ីលឃីស្ទត ហ្សឺនស្តី៖**

សូមអរគុណច្រើន ។ ឥឡូវនេះខ្ញុំមិនមានសំណួរអ្វីទៀតទេ ប៉ុន្តែ អាចជាសំណួររបស់លោក ស៊ាង វ៉ាន់ឌី ដែលត្រូវសួរទៅជនជាប់ចោទ តាមរយៈលោកប្រធាន គឺសំណួរមួយសួរទាក់ទងទៅនឹងទំព័រដំបូងនៃចម្លើយសារភាពដែលសូមអនុញ្ញាតពីលោកប្រធាន អនុញ្ញាតបង្គាប់ឲ្យខាងសោតទស្សន៍បង្ហាញឯកសារលេខ ERN 00173881 ដើម្បីឲ្យលោក ស៊ាង វ៉ាន់ឌី អាចសួរសំណួររបស់គាត់ដែលទាក់ទងទៅនឹងឯកសារនេះ តាមរយៈលោកប្រធាន ទៅជនជាប់ចោទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដូរ ដូរនូវប្រដាប់ស្តាប់សំឡេងដល់ ជូនដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

មន្ត្រីខាងសោតទស្សន៍ដាក់បញ្ចាំងនូវឯកសារ ដែលមានលេខ ERN 00173881 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

អញ្ជើញលោក ស៊ាង វ៉ាន់ឌី ថាតើលោកមានសំណួរយ៉ាងម៉េច ដែលលោកប៉ុនប៉ងក្នុងការសួរទៅជនជាប់ចោទ ដោយលោកផ្ញើសំណួរតាមរយៈយើង ដែលជាប្រធានអង្គជំនុំជម្រះសាលាដំបូង ដើម្បីយើងបញ្ជូននូវសំណួរទៅជនជាប់ចោទ ដើម្បីឲ្យឆ្លើយតបទៅនឹងសំណួររបស់លោក ។ សូមអញ្ជើញ ។

[១៥:២០:២២]

**លោក ស៊ាង វ៉ាន់ឌី៖**

បាទ, អរគុណលោកប្រធាន ។ ខ្ញុំសូមសួរសំណួរទីមួយ ។ តើជនជាប់ចោទបានស្គាល់ឈ្មោះ ស៊ាង ផុន ហៅ ផា នេះជាអ្នកទោសក្នុងគុកទួលស្លែងពិតប្រាកដមែន ឬក៏អត់?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមបញ្ជូនសំណួរនេះទៅជនជាប់ចោទ ដើម្បីឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ឯកសារនេះវាច្បាស់លាស់ហើយ មនុស្សជាងមួយម៉ឺននាក់ ខ្ញុំស្គាល់អត់អស់ទេ ដល់ឃើញឯកសារនេះទទួលស្គាល់ភ្លាម ។ អត់ប្រកែក ។

**ប្រធានអង្គជំនុំ៖**

លោក ស៊ាង វ៉ាន់ឌី សូមតាំងសំណួរទីពីររបស់លោក ។

**លោក ស៊ាង វ៉ាន់ឌី៖**

បាទ, អរគុណលោកប្រធាន ។ សំណួរទីពីរ ទាក់ទងនឹងការសារភាពរបស់ឈ្មោះ ស៊ាង ផុន ហៅ ផា ប្អូនខ្ញុំ ។ តើលោកបានអាន និងចារលើកំណត់ហេតុនោះទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្ទេរ ប្រគល់នូវសំណួរនេះទៅជនជាប់ចោទ ដើម្បីឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សឺនស្តី៖**

សូមអភ័យទោសលោកប្រធាន ។ សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យខាងសោតទស្សន៍បង្ហាញ និងនៅលើកំណត់ហេតុសួរចម្លើយហើយមានចំណារនៅទីនោះ ហើយអញ្ជើញអានបង្គាប់ឲ្យអានផង ។ អរគុណ ។

[១៥:២២:៣១]

**ប្រធានអង្គជំនុំ៖**

ចង់ធ្វើយ៉ាងម៉េចទៅ? និយាយម្តងទៀតមេធាវីការពារក្តី ហើយចង់ឲ្យអាន ហើយអានត្រង់ចំណុចណាខ្លះ?ពីចំណុចណាដល់ត្រឹមណា? ឬក៏អាននៅលើខ្លឹមសារនៃកំណត់ហេតុសារភាពទាំងស្រុង?

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមបញ្ជាក់ ហើយជម្រាបជូនថា គឺជាទំព័រទីមួយ ដែលមានលេខ ERN ខ្ញុំជម្រាបជូននៅក្នុងឯកសារ ដែលបានបង្ហាញនៅលើអេក្រង់ ។ ឥឡូវនេះបានដកចេញវិញនៅទំព័រមួយហ្នឹងមានអក្សរសរសេរដោយដៃ-- សូមទោស មានចំណារ ដែលមានន័យថា មួយច្បាប់ចម្លងជូនបង ។ នៅកណ្តាលទំព័រនោះ មួយច្បាប់ជូនបង នួន ដើម្បីបញ្ជូនទៅភូមិភាគកណ្តាល ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ គប្បីអាននៅផ្នែកចំណារហ្នឹង ដើម្បីដាក់ចូលកំណត់ត្រា ។ អ៊ីចឹងសូមអនុញ្ញាតលោកប្រធាន បង្គាប់ឲ្យជនជាប់ចោទ ឆ្លើយទៅចម្លើយរបស់លោក ស៊ាង វ៉ាន់ឌី ទាក់ទងទៅនឹងខ្លឹមសារចំណារដែលខ្ញុំបានបញ្ជាក់ជូនអំមិញនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ ជនជាប់ចោទបានឆ្លើយយ៉ាងច្បាស់លាស់រួចហើយ ។ ដូច្នេះ អង្គជំនុំជម្រះមិនចាំបាច់ឲ្យជនជាប់ចោទឆ្លើយទៀតទេ ប្រសិនបើត្រឹមតែអានយើងអនុញ្ញាតបាន ប៉ុន្តែ តើសមត្ថភាពក្នុងការអាននូវអក្សរនេះបានដែរឬទេ?

មន្ត្រីតុលាការដាក់បញ្ចាំងនូវឯកសារអម្បាញ់មិញសាជាថ្មីម្តងទៀត ។

ក្រឡាបញ្ជីអានដាក់ឲ្យអស់ខាងលើៗ-- អាននូវសំណេរនេះបញ្ជាក់បន្ថែមពីលើអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយរួចហើយ ដើម្បីបំពេញចិត្តមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។ ហើយចំណុចណាអានមិនកើតរាយការណ៍ប្រាប់យើង ដើម្បីយើងឲ្យទៅមេធាវីជាអ្នកអានម្តង ។

[១៥:២៥:៤៦]

**លោកស្រី សែ កុលវុឌ្ឍី៖**

សេចក្តីកំណត់ហេតុ ចម្លើយ ស៊ាង ផុន ហៅ ផា អតីតធ្វើស្រែមុនចាប់ខ្លួន ។ ជំនួយការវរសេនាតូច៧០១ កព ១៧៤ ភូមិភាគកណ្តាល ។

ចុះមកខាងក្រោមទៀត មើលអត់ដាច់លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី ធ្វើម៉េចអាចមើលដាច់ឥឡូវនេះ ឥឡូវហ្នឹងអានមិនដាច់ទេ ហើយយើងខ្លួនឯងក៏អានមិនដាច់ដែរនូវអក្សរចំណារនេះ ។ តើចង់ធ្វើយ៉ាងម៉េចទៀតឲ្យច្បាស់លាស់លើបញ្ហានេះ? ប៉ុន្តែយើងបញ្ជាក់ហើយ គឺចម្លើយរបស់ជនជាប់ចោទបានឆ្លើយច្បាស់លាស់រួចហើយ ទទួលថាឯកសារនេះគឺជាឯកសារពិតចេញពីមន្ទីរស-២១ ។

**លោកស្រី ស៊ីលយីស្ទត ហ្សីនស្ដី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមបំភ្លឺចំណុចនេះ សំណួរដែលត្រូវសួរពីលោក ស៊ាង វ៉ាន់ឌី ទៅជនជាប់ចោទទាក់ទងនឹងចំណារនេះ ដែលតាមរយៈលោកប្រធាននោះ គឺថាតើជនជាប់ចោទ តើគាត់អាចបញ្ជាក់ប្រាប់ទេ គាត់អានបានទេ ពីចំណារនេះដែលនៅទំព័រនេះ ថាអ្នកណាជាអ្នកធ្វើចំណារផ្ទាល់ដៃនេះដែលថាដែលលោក ស៊ាង វ៉ាន់ឌី ចង់ដឹងនោះដែលចំណារនោះថា ជូនបង នួន មួយច្បាប់សម្រាប់ជូនភូមិភាគកណ្ដាល ។

**ប្រធានអង្គជំនុំ៖**

លោក ស៊ាង វ៉ាន់ឌី តើមានបំណងនេះពិតដែរទេ? ដូចជាបំណងរបស់លោកមិនបានបង្ហាញច្បាស់លាស់ទេ ។ អម្បាញ់មិញនេះ មេធាវីរបស់លោកបែរជាថា នេះជាបំណងរបស់លោក ប៉ុន្តែលោកដែលជាប្រើភាសាខ្មែរ ដូចជាមិនបាននិយាយអំពីបញ្ហានេះប្រាប់យើងទេ ។ ថាតើបំណងនេះលោកមានបំណងយ៉ាងម៉េចក្នុងការអាននូវសំណេរនេះឲ្យច្បាស់លាស់ដោយខ្លួនឯង ចៀសវាងការបំភ្លៃនូវព័ត៌មានដែលទទួលបានពីលោក?

**លោក ស៊ាង វ៉ាន់ឌី៖**

បាទ, លោកប្រធាន មេធាវីខ្ញុំបាទ គាត់មានប្រសាសន៍ត្រឹមត្រូវ ប៉ុន្តែសំណួររបស់ខ្ញុំពាក់ព័ន្ធចូលសំណួរទីបី ។ ទីពីរនេះវាឈានចូលទីបីហ្នឹង ខ្ញុំបាទ ចង់និយាយថា ការចុះហត្ថលេខា និងចារជូនទៅភូមិភាគកណ្ដាលតាមតា នួន ។ តើអក្សរនេះជាអក្សររបស់ជនជាប់ចោទមែនឬទេបាទ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញជនជាប់ចោទឆ្លើយនូវចំណារខាងក្រោមបីបន្ទាត់ រួមទាំងអក្សរពីរបន្ទាត់ដែលមានអក្សរផង ហើយនិងលេខ ១១-១១-៧៧ ហើយនិង ២៨-១០-១៩៧៧ ហើយនិងឆ្លើយតបទៅនឹងសំណួរនេះ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ថ្ងៃ២៨ ខែតុលា ឆ្នាំ១៩៧៧ ជាថ្ងៃខែដែលអ្នកសួរគេសរសេរ ។ ដោយឡែក ចំណារនេះ ខ្ញុំឈប់ចារហើយរយៈនោះចារមិនទាន់ ។ ក៏ប៉ុន្តែ ពូនួន គាត់មិនសួរចង់បាន ចំណារទេពេលនោះ ។ ដូច្នេះ អក្សរនេះខ្ញុំស្គាល់ច្បាស់ណាស់ ក្រឡេកស្គាល់ភ្លាមជាអក្សរមេខ្ញុំលោកគ្រូ សុន សេន ហៅ ខៀវ ។ ចុះថ្ងៃទី១១ ខែវិច្ឆិកា ១៩៧៧ ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ចុះខ្លឹមសារនៃចំណារនេះលោកអាចអានបានទេពីរបន្ទាត់ខាងលើ?

[១៥:៣០:០០]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ជូនបងនួន មួយច្បាប់សម្រាប់ជូនភូមិភាគកណ្តាល ហើយ អក្សរក្រវិចក្រវក់នេះ គ្រាន់តែសរសេរ ដើម្បីបញ្ជាប់កុំឲ្យគេថែមអីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍បង្វែររូបភាពទៅជារូបភាពប្រក្រតីឡើងវិញ ហើយដើមបណ្តឹងរដ្ឋប្បវេ-ណីអាចតាំងសំណួរទីបួនរបស់លោក ។

**លោក ស៊ាង វ៉ានឌី៖**

បាទ, អរគុណលោកប្រធាន ។ ខ្ញុំសូមធ្វើសំណួរតាមរយៈលោកប្រធាន ។ ជនជាប់ចោទច្រើន លើកថា ខ្លួនដើរតាមមាគ៌ាបក្ស ព្រោះខ្លួនស្រឡាញ់និងស្នេហាជាតិ តើស្នេហាជាតិបែបនេះ វាមានន័យ យ៉ាងម៉េច បើជនជាប់ចោទសម្លាប់តែជនជាតិខ្មែរខ្លួនឯង?

**ប្រធានអង្គជំនុំ៖**

លោកអាចឆ្លើយនឹងសំណួរនេះបានទេ យើងបញ្ជូនសំណួរនេះទៅលោក ដើម្បីលោកអាចឆ្លើយ នឹងសំណួរ ។ យើងសូមជម្រាបដល់ជនជាប់ចោទថា ក្នុងករណីលោកមិនចង់ឆ្លើយ ក៏លោកមានសិទ្ធិ នៅក្នុងការមិនឆ្លើយតបនឹងសំណួរដែរ នេះជាសិទ្ធិរបស់លោក ។ មិនមែនយើងតម្រូវថា ដាច់ខាតត្រូវតែ ឆ្លើយនោះទេ ។ សូមអញ្ជើញ ប្រសិនបើលោកអាចឆ្លើយបាននឹងសំណួរនេះ ឬក៏លោកមានបំណងចង់ ឆ្លើយ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំគ្រាន់តែបញ្ជាក់ថា ខ្ញុំមិនដែលបានអះអាងអំពីបញ្ហាស្នេហាជាតិនោះទេ ។ សុំឆ្លើយតែប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណី តើមានសំណួរអ្វីទៀតទេ សូមអញ្ជើញ ។

**លោក ស៊ាង វ៉ាន់ឌី៖**

បាទ, សុំចប់ហើយលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាចអង្គុយចុះបាន ។ អង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា បើសិនជាមានសំណួរចង់សួរ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សូមអញ្ជើញ ។

**លោក វ៉ាំងសង់ ឌឺ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន យើងខ្ញុំពុំមានសំណួរចង់តាំងសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ យើងខ្ញុំគ្រាន់តែមានបំណងចង់ធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសេចក្តីថ្លែងការណ៍របស់លោក។

**ប្រធានអង្គជំនុំ៖**

ជាបន្តអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន ។ សូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

មេធាវីការពារក្តីពុំមានសំណួរចង់តាំងសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ លោកប្រធាន សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះអង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីមានលទ្ធភាពអាចធ្វើការកត់សម្គាល់ចំពោះសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលបានធ្វើសេចក្តីថ្លែងការណ៍កន្លងមក។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមបញ្ជាក់ថា ខ្ញុំយល់ស្របនឹងសេចក្តីថ្លែងការណ៍របស់លោក ស៊ាង វ៉ាន់ឌី ។ ខ្ញុំសូមបញ្ចប់បញ្ហានេះ-- សេចក្តីឆ្លើយតបប៉ុណ្ណេះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ឃើញថាកាលវិភាគនៃការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប សម្រាប់ធ្វើសេចក្តីថ្លែងការណ៍ថ្ងៃនេះ ឃើញថាដល់ទីបញ្ចប់ ហើយក៏ដល់ពេលវេលាដែលត្រូវឈប់សម្រាកផង ដោយសារមូលហេតុ អ្នកបច្ចេកទេស ខាងផ្នែកព័ត៌មានវិទ្យារៀបចំធ្វើការសាកល្បងពាក់ព័ន្ធជាមួយនឹងប្រព័ន្ធព័ត៌មានវិទ្យានៅឯប្រទេសបារាំង ដើម្បីត្រៀមរៀបចំធ្វើសវនាការស្តាប់សេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណី ដែលធ្វើពីចម្ងាយ ឈ្មោះ អ៊ូ សាវរិត ដែលត្រូវធ្វើសេចក្តីថ្លែងការណ៍នៅថ្ងៃស្អែក ពេលរសៀលម៉ោងមួយនិងសាមសិបនាទី ដើម្បីពិនិត្យសមត្ថភាព និងលទ្ធភាព ថាតើអាចធ្វើបានកម្រិតណា ។

ថ្ងៃនេះ ដំណើរការសវនាការគឺចប់ត្រឹមនេះ ។ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែក ចាប់ពីម៉ោងប្រាំបួនព្រឹក ។ ហើយថ្ងៃស្អែកយើងនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវធ្វើសេចក្តីថ្លែងការណ៍ពីចម្ងាយផង ។

លោក ស៊ាង វ៉ាន់ឌី អង្គជំនុំជម្រះបានស្តាប់សេចក្តីថ្លែងការណ៍របស់លោកបានចប់សព្វគ្រប់ហើយ។ ចាប់ពីពេលថ្ងៃស្អែកទៅ គឺសិទ្ធិរបស់លោកក្នុងការចូលរួមក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី អាចបន្តការស្តាប់ ចូលរួមក្នុងការស្តាប់នៅក្នុងដំណើរការសវនាការ ឬក៏លោកវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោកវិញ ឬក៏ទីកន្លែងណាដែលលោកចង់ទៅ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំណត់៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១៥:៣៧នាទី]*